អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-May-2012, 13:58
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី៦៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Miss. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោកស្រី ទី ស្រ៊ីនណា

លោក សំ សុគង់

លោកស្រី ឡូរ៍ ដេសហ្វកស៍

*(Ms.Laure DESFORGES)*

លោក បាណាបេ ណេគ្វី*(Mr. Barnabé NEKU*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក បាណាបេ ណេគ្វី | បារាំង |
| លោក ឡៅ ជុនធី | ខ្មែរ |
| លោក នី កន (TCW-487) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក នី កន** (TCW-487)


សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី៖ ........ ទំព័រ ២

សួរដោយលោក ឡៅ ជុនធី ផ្ដើមពី៖ ........ ទំព័រ៤៦

សួរដោយលោក បាណាបេ ណេគ្វី ផ្ដើមពី៖ ........ ទំព័រ៦២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:២៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីម្សិលមិញថា នៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីឈ្មោះ នី កន ដែលនឹងត្រូវតាំងសំណួរដេញដោលបន្តដោយក្រុមតំណាងសហព្រះរាជអាជ្ញា។

ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងធ្វើរាយការណ៍អំពីស្ថានភាពរបស់ជនជាប់ចោទ អៀង សារី!

**ក្រឡាបញ្ជី៖**

ជម្រាបលោកប្រធាន ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ គាត់បានលះបង់សិទ្ធិមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទរូបនេះបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០៥:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១២ ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់ក្នុងកិច្ចដំណើរការសវនាការផ្ទាល់យូរបាន។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង

សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៧:០៣]

ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពេញមួយថ្ងៃនេះ។

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព និងសហភាគីទាំងអស់ជាទីគោរព។ ជម្រាបសួរលោកសាក្សី។

បាទ ខ្ញុំសូមបញ្ជាក់មួយទៅដល់អង្គជំនុំជម្រះទាក់ទងទៅនឹងការបែងចែកពេលវេលាដែលធ្វើបានសម្រេចរវាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញា យើងនឹងបន្តចោទសំណួរទៅសាក្សីនៅព្រឹកនេះ រហូតដល់ពេលសម្រាកពេលថ្ងៃត្រង់ ហើយបន្ទាប់មកទៀត នៅពេលរសៀលនេះ ខាងដើមបណ្តឹងរដ្ឋប្បវេណីចោទសំណួរបន្តដល់ល្ងាច។

[០៩:០៨:១០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំសូមចោទសំណួរសួរបំភ្លឺមួយទាក់ទងនឹងរចនាសម្ព័ន្ធនៃតំបន់៣២ និងតំបន់១៥ ដែលក្រោយមកក្លាយជាតំបន់៣២ លោកនិយាយថា លោក ចេង អន ជាអនុលេខានៃតំបន់នុ៎ង។ តើលោក ចេង អន ដដែលនេះឬ ដែលក្លាយមកជារដ្ឋមន្ត្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក នី កន៖**

**ឆ៖** សូមគោរព លោកប្រធាន និងអង្គសវនាការទាំងមូល។ ចំពោះសំណួរនេះ ខ្ញុំសូមឆ្លើយគឺខ្ញុំមិនបានយល់ថា ចេង អន ហ្នឹងក្លាយទៅជារដ្ឋមន្ត្រីអីនោះទេ បាទ។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកចោទសំណួរដដែល ម្សិលមិញ ដែលខ្ញុំបញ្ចប់សវនាការកាលពី

ម្សិលមិញ គឺជាសំណួរពាក់ព័ន្ធទៅនឹងកិច្ចប្រជុំផ្សេងៗ ដែលលោកបានចូលរួមនៅក្នុងថ្នាក់សាខា ឬក៏តំបន់។ ឥឡូវនេះខ្ញុំសូមសួរលោក លើសពីការប្រជុំថ្នាក់មូលដ្ឋាននៅក្នុងថ្នាក់សាខា ឬក្នុងតំបន់៣២នេះ តើមានសន្និបាតមួយឆ្នាំម្តង ឬក៏ពីរឆ្នាំម្តង ដែលសំដៅធ្វើឡើងដើម្បីកម្មាភិបាល ឬក៏សមាជិកបក្សដែរឬទេ?

[០៩:១០:០០]

**ឆ៖** សូមឆ្លើយ តាមចាំមិនបានអស់ទេ តែធម្មតាមានសន្និបាត។ បាទ សន្និបាតក្របខ័ណ្ឌភូមិភាគ នេះជាធម្មតា។ តែប៉ុន្មានដង ឬយ៉ាងម៉េចនោះ ខ្ញុំចាំមិនអស់ទេបាទ។

**ស៖** តើសន្និបាតភូមិភាគនេះប្រព្រឹត្តឡើងនៅកន្លែងណា? នៅកន្លែងតែមួយ ឬកន្លែងផ្សេងៗនៅក្នុងភូមិបស្ចិម?

**ឆ៖** ខ្ញុំចាំមានតែកន្លែងមួយ ដែលខ្ញុំបានជម្រាបម្សិលមិញ គេហៅចម្ការដូងបាទ។

**ស៖** តើអ្នកណាចូលរួមសន្និបាតភូមិភាគហ្នឹង? តើសម្រាប់តែកម្មាភិបាលមួយចំនួនទេឬ? ហើយបើអ៊ីចឹងមែននោះ តើកម្មាភិបាលប្រភេទណា?

**ឆ៖** ជាធម្មតាគេប្រមូលច្រើនរហូតដល់សាខាឃុំ វាជាសមាសភាពដែលចូលរួមបាទ។

[០៩:១២:១៥]

**ស៖** អ៊ីចឹងបានន័យថា អ្នកនៅតាមឃុំចូលរួម ហើយថ្នាក់លើគឺថាថ្នាក់ស្រុក ឬក៏ថ្នាក់តំបន់ហ្នឹងក៏ចូលរួមដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹង។

**ស៖** តើរូបលោកផ្ទាល់នោះ លោកបានចូលរួមសន្និបាតនោះប៉ុន្មានដែរ? តើលោកចាំដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេបាទ ហើយខ្ញុំចូលក្នុងសន្និបាតដែលគេប្រើឈ្មោះថា "សន្និបាតបើកទូលាយៗ" បាទ។

**ស៖** តើអ្នកណាជាអ្នកធ្វើជាអធិបតីនៃសន្និបាតថ្នាក់ភូមិភាគហ្នឹង? តើអ្នកណាអ្នកធ្វើកិច្ចការនេះ?

**ឆ៖** អធិបតីជាធម្មតាគឺមេភូមិភាគ នេះជាធម្មតាបាទ។

**ស៖** តើជួនកាលតើមានថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យមកពីទីក្រុងភ្នំពេញ ដើម្បីថ្លែងសុន្ទរកថាក្នុងសន្និបាតបែបនេះដែរឬទេ?

**ឆ៖** ខ្ញុំនៅចាំបានម្ដងដែរ គឺអ្នកអធិបតីទៅពីខាងលើទៅបាទ។ ពេលនោះ គឺឃើញមាន តា នួន ជា បាទ គាត់ទៅម្ដង។

[០៩:១៤:៥១]

**ស៖** ហើយក្រៅពីតា នួន ជា នោះ តើលោកបានឮ ឬក៏ឃើញអ្នកដឹកនាំជាន់ខ្ពស់ផ្សេងទៀតមកដល់ភូមិភាគបស្ចិមហ្នឹង ដើម្បីធ្វើជាប្រធាន ឬក៏ជួយប្រធាន-- អំ លេខាភូមិភាគហ្នឹង ដើម្បីធ្វើសន្និបាតហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានឃើញទេបាទ។

**ស៖** តើលោកចាំដែរឬទេ? តើនៅឆ្នាំណា លោកបានឃើញ នួន ជា នៅក្នុងភូមិភាគបស្ចិមនៅក្នុងឱកាសសន្និបាតនេះ?

**ឆ៖** សូមបញ្ជាក់ គឺខ្ញុំចាំមិនច្បាស់ទេ ជាង៣០ឆ្នាំអីចឹងហើយ ខ្ញុំគ្រាន់តែប៉ាន់ស្មានប្រហែលរវាងចុង១៧៤ អីហ្នឹង មិនច្បាស់ៗលាស់បាទ។ អំ មិនចុង៧៤ សូមបញ្ជាក់ម្ដងទៀត ប្រហែលជាចុង៧៥អីហ្នឹង មិនច្បាស់លាស់ទេ មិនចាំច្បាស់ទេ។

**ស៖** តើលោកអាចនិយាយប្រាប់យើងបានទេ ថាតើប្រធានបទដែលគេពិភាក្សានៅពេលនោះ ពេលសន្និបាតភូមិភាគនោះ ថាប្រធានបទដែលលេខាភូមិភាគនិយាយ ឬក៏ដែលថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យមកនិយាយ?

[០៩:១៦:៥៨]

**ឆ៖** ខ្ញុំចាំច្បាស់តែរឿង ថាក្រោយសង្គ្រាមចប់ហើយ ទាំងអស់គ្នា រួមគ្នាស្ដារសេដ្ឋកិច្ចឡើងវិញ ហើយជាមួយនឹងដើម្បីជំរុញការអនុវត្តនយោបាយខ្លួនឧបត្ថម្ភខ្លួន ឯករាជ្យម្ចាស់ការ ដូចបានជម្រាបពីម្សិលមិញៗបាទ។

**ស៖** តើសន្និបាតនេះ មានរយៈពេលប៉ុន្មានថ្ងៃ? មួយថ្ងៃ ឬក៏ជាច្រើនថ្ងៃ?

**ឆ៖** សន្និបាតនេះ តាមចាំដោយត្រួសៗ គឺប្រហែលជាបីថ្ងៃ។

**ស៖** យើងត្រឡប់មកនិយាយអំពីប្រធានបទដែលយើងបាននិយាយ តើលោកធ្លាប់បានឮគេនិយាយនៅក្នុងឱកាសសន្និបាតទាំងអស់នេះ អំពីប្រធានបទមួយ ដែលទាក់ទងទៅនឹងខ្មាំង ខ្មាំងជាតិសត្រូវជាតិ សត្រូវក្នុង-- ផ្ទៃក្នុង ឬក៏ខាងក្រៅ។ តើលោកធ្លាប់ឮគេនិយាយពីពាក្យ "ជនក្បត់" នៅក្នុងឱកាសសន្និបាតប្រភេទនេះដែរឬទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំឮតែរឿងថា ធ្វើយ៉ាងណាកុំឲ្យមានអ្នករារាំងនូវទិសដៅសម្រុក កសាងប្រទេសរបស់យើង។ ឯខ្មាំងកំណត់ក្នុង ក្រៅ យ៉ាងម៉េច ខ្ញុំអត់ច្បាស់ទេ អត់មានច្បាស់លាស់។

**ស៖** តើលោកធ្លាប់ឮ នួន ជា និយាយអំពីអ្នកដែលប្រឆាំងនឹងចលនាតស៊ូដែរឬទេ?

**ឆ៖** ផ្ទាល់ខ្លួនខ្ញុំអត់បានឮទេបាទ។

[០៩:២០:០៥]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំមានទង់បដិវត្តពីរច្បាប់ដែលមាន-- ដែលនិយាយអំពីសុន្ទរកថារបស់អង្គការបក្ស អ្នកថ្នាក់ដឹកនាំដែលមកភូមិភាគបស្ចិមដែលធ្វើឡើងនៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧។ ខ្ញុំមិនចង់-- គឺឯកសារចុះថ្ងៃទីខែធ្នូ ឆ្នាំ១៩៧-- អ៎! ខែមិថុនា ឆ្នាំ១៩៧៦ និងឯកសារ D234.2.15 ហើយនិង E3/760។ ខ្ញុំចង់បង្ហាញទង់បដិវត្តមួយទៀត ដែលចុះនៅខែសីហា ឆ្នាំ១៩៧៨ ដែលមានលេខកូដ E3/193 និង D199-- 198.2 ចំណងជើងគឺ មានចំណងជើងតែមួយទេ គឺ "សុន្ទរកថារបស់អ្នកតំណាងបក្ស ទាក់ទងនឹងប្រធានបទ សេចក្តីណែនាំមួយចំនួន ទាក់ទងទៅនឹងការកសាង ហើយនិងពង្រឹង និងពង្រីកបក្សដឹកនាំនៅក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចិម ថ្ងៃទី២៥ កក្កដា ឆ្នាំ១៩៧៧"។ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញឯកសារនេះទៅសាក្សី ហើយនិងសូមបញ្ចាំងឯកសារមួយចំនួនផងដែរ។ សូមការអនុញ្ញាតពីលោកប្រធាន។

[០៩:២១:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិជូនទៅសាក្សីពិនិត្យ! ហើយនិងអនុញ្ញាតឲ្យជំនួយការបង្ហាញឯកសារនេះនៅលើអេក្រង់កុំព្យូទ័រ!

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

បាទខ្ញុំសូមទុកពេលឲ្យសាក្សីមើល ពិនិត្យមើលខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្តនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឃើញទង់បដិវត្តនេះទេ ដែលទាក់ទងជាពិសេសគឺភូមិភាគបស្ចិម? តើលោកអាចប្រាប់យើងបានទេ ថាលោកស្គាល់ការប្រកាសផ្សាយនេះទេ ឬក៏ខ្លឹមសារនៃទង់បដិវត្តនេះ ទាក់ទងទៅនឹងសន្និបាតដែលប្រព្រឹត្តឡើងនៅខែកក្កដា ឆ្នាំ១៩៧៧?

**លោក នី កន៖**

**ឆ៖** សូមជម្រាប ខ្ញុំអត់បានឃើញទេ ពីព្រោះឯកសារហ្នឹងគេដកស្រង់យកមកអធិប្បាយរួម ឯផ្ទាល់ខ្ញុំមិនបានឃើញ មិនបានអានទេបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធានខ្ញុំមានសំណួរមួយទៀត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើលោកដឹងអំពីសុន្ទរកថាដែលបានថ្លែងនៅក្នុងភូមិភាគបស្ចិមនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[០៩:២៤:២៦]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អម្បាញ់មិញនេះ សាក្សីបានអះអាងហើយថាលោកអត់ដែលបានឃើញ អត់ដែលបានអានឯកសារនេះទេ។ តើយើងគួរតែអនុវត្តវិធាន ឬវិន័យ ឬមួយគោលការណ៍ដែលលោកប្រធានបានដាក់ដែរឬទេ? សូមមេត្តាពិចារណា សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មន្ត្រីរដ្ឋបាលតុលាការដកឯកសារចេញពីសាក្សីវិញ ហើយនិងបុគ្គលិកជំនួយការដកឯកសារចេញពីអេក្រង់កុំព្យូទ័រ!

[០៩:២៥:២២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នៅក្នុងឱកាសសន្និបាតភូមិភាគ តើលោកធ្លាប់បានឮ ជាពិសេសនោះ ជាងអ្វីដែលខ្ញុំបាននិយាយអម្បាញ់មិញនេះទៀត ឮថាបក្ខជនដែលមកពីទីក្រុងភ្នំពេញ ដូច្នេះគឺថ្នាក់ដឹកនាំជាន់ខ្ពស់និយាយអំពីការដែលនៅក្នុងតំបន់១៥ មានអ្នកពុករលួយច្រើន ហើយមានសុទ្ធតែសាច់ស្អុយរលួយ។ តែឥឡូវនេះសាច់រលាយនេះត្រូវបានដោះស្រាយ ហើយកាត់ចោលអស់ហើយ។ តើលោកធ្លាប់បានឮសុន្ទរកថានៅក្នុងសន្និបាតនៅភូមិភាគបស្ចិមនេះដែរឬទេ? ការប្រើពាក្យពេចន៍បែបនេះនេះ តើលោកធ្លាប់ឮដែរឬទេ?

**លោក នី កន៖**

**ឆ៖** សូមជម្រាប សុន្ទរកថាដែលមានខ្លឹមសារដូចលោកបានបញ្ជាក់អម្បាញ់មិញនេះ ខ្ញុំដូចមិនដែលឮទេ ក្នុងពេលហ្នឹង ពីព្រោះវាជាតួនាទីរបស់ខាងលើ។ ដូច្នេះដូចមិនបានឮទេបាទ។

**ស៖** លោកសាក្សី តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថានៅភូមិភាគបស្ចិមថានៅពេលណាមួយនោះ គឺថាមានការចាប់ខ្លួនមនុស្សជាច្រើន មានការបោសសម្អាតនៅក្នុងចំណោមកម្មាភិបាលរបស់ភូមិភាគ តំបន់ និងស្រុក នៅក្នុងភូមិភាគបស្ចិម?

**ឆ៖** សូមជម្រាប ខ្ញុំឮនិយាយតៗគ្នាតាមរយៈការខ្សឹបខ្សៀវ តែពេលនោះ បើខ្ញុំមិនភ្លេចទេគឺខ្ញុំចេញផុតហើយ។ ចេញផុតមកខាងក្រសួងហើយ បាទ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើលោកចេញពីតំបន់-- ពីភូមិភាគបស្ចិមមកក្រសួងការបរទេសហ្នឹងនៅពេលណា? សូមបញ្ជាក់បាទ។

[០៩:២៨:២៦]

**ឆ៖** ខ្ញុំចេញមកក្រសួងការបរទេសប្រហែលជាដើម ចិត-- ចុង៧៧ ដើម៧៨ ហើយបាទ។ មិនចាំច្បាស់ទេ ប៉ុន្តែប្រហែលប៉ុណ្ណឹង ព្រោះមកធ្វើការនៅក្រសួងហ្នឹងរយៈពេលខ្លីណាស់ មិនហួសពីបីខែប៉ុណ្ណឹងទេ។ ហើយពេលនោះ សភាពការណ៍វាច្របូកច្របល់ដែរ ពីព្រោះសង្គ្រាមចាប់ផ្តើមផ្ទុះសាជាថ្មីហើយ។ ហើយការរឹករវរ ពីការព្រួយបារម្ភ អ្នកនេះទៅនោះ។ ហើយត្រូវប្រមូលផ្តុំកម្លាំងយ៉ាងនេះយ៉ាងនោះអីហ្នឹង នាំឲ្យគ្មានអ្នកណាសាកសួរអ្នកណា ប៊ានសាកសួរអ្នកណា ឬក៏ដេញដោលថាអ្នកណាទៅណាមកណាទេ។ ដូច្នេះមិនច្បាស់លាស់ទេ។ នេះសូមជម្រាបជូនបានប៉ុណ្ណឹងបាទ។

[០៩:២៩:៣៩]

**ស៖** នៅក្នុងតំបន់៣២ នៅពេលដែលលោកនៅទីនោះនៅឡើយនោះ តើពុំដែលមានមនុស្សបាត់ខ្លួនដែរទេឬ នៅក្នុងតំបន់នោះ? លោកមិនដែលសង្កេតឃើញថាមានការបាត់ខ្លួនមនុស្សទេឬ?

**ឆ៖** ជម្រាបជូនបាទ ហៅថាមនុស្សបាត់ខ្លួន ខ្ញុំមិនដឹងទេ។ តែគ្រាន់តែឮថា មានដកហូតទៅទទួលការងារថ្មី។ ឯទៅខាងណា អីខាងណាដូចបានជម្រាប គឺមិនដឹងទេ គ្មានប៊ានសួរប៊ានអីទេបាទ។ គ្រាន់តែដឹងថា ដកទៅធ្វើការងារផ្សេង។

**ស៖** ហើយបុគ្គលទាំងអស់នោះ ដែលគេដកទៅកន្លែងផ្សេង តើលោកធ្លាប់បានឃើញពួកគាត់វិញទេពេលក្រោយមក?

[០៩:៣០:៥៧]

**ឆ៖** សូមបញ្ជាក់ អត់ឃើញទេបាទ ទៅខាងណា ខាងណីអត់ឃើញ ហើយដូចខ្ញុំជម្រាបអំមិញ សភាពការណ៍អ៊ីចឹងហើយ លែងដឹងហើយ បាទលែងដឹង អ្នកណាទៅណាអស់ហើយបាទ។

**ស៖** នៅក្នុងតំបន់៣២ តើលោកស្គាល់ សិទ្ធ ទេដែលធ្វើការនៅក្នុងស្រុកឧដុង្គ? តើលោកស្គាល់ សិទ្ធ ទេ?

**ឆ៖** បាទ អត់ស្គាល់ទេបាទ។

**ស៖** តើលោកស្គាល់ កែវ ទេ ដែលធ្វើការនៅតំបន់៣២ដែរ ដែលសរសេរ "ក"-"ែ"-និង "វ"?

**ឆ៖** ខ្ញុំធ្លាប់ស្គាល់នៅពេលសង្គ្រាម វ៉ៃនៅពាយព្យភ្នំពេញ ម្តងម្កាល ដោយគាត់ទទួលខាងការផ្គត់ផ្គង់ស្បៀងអាហារបាទ។

**ស៖** តើលោកដឹងថា មានរឿងអ្វីកើតឡើងចំពោះគាត់ឬទេ នៅឆ្នាំ១៩៧៧? តើគាត់ជាមនុស្សដែលលោកធ្លាប់ស្គាល់? ហើយដែលត្រូវបានគេ-- ដែលត្រូវបានដូរប៉ុស្តិ៍ ពីកន្លែង-- ពីប៉ុស្តិ៍ទៅប៉ុស្តិ៍ តំណែងមួយទៅតំណែងមួយហ្នឹង?

[០៩:៣៣:០៧]

**ឆ៖** ជម្រាបជូន រឿងនេះខ្ញុំអត់ដឹងទេ។ ពីព្រោះជាតួនាទីរបស់ថ្នាក់លើ បាទ។

**ស៖** តើលោកស្គាល់លោក ស៊ុម ទេ? សរសេរ "ស"-"ុ"-"ិ"-និង "ម" ដែលនៅពញាឮ លោកស្គាល់គាត់ទេ?

**ឆ៖** ឈ្មោះនេះក៏អត់ស្គាល់ដែរបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទ្រាឯល៖**

សូមជម្រាបជូនអង្គជំនុំជម្រះ ហើយនិងដើម្បីប្រតិចារឹក គឺថាមានឈ្មោះទាំងអស់នេះមាននៅក្នុងតេឡេក្រាម ដែលផ្ញើដោយភូមិភាគបស្ចិមទៅមជ្ឈិមបក្ស ដែលជាតេឡេក្រាមដែលមានឯកសារ D369/12.1 ហើយបុគ្គលទាំងអស់នេះ សុទ្ធតែៗ ត្រូវបានរៀបរាប់ថាសុទ្ធតែជាមនុស្សដែលគេធ្លាប់បញ្ជូនទៅមន្ទីរសន្តិសុខមន្ទីរស-២១ទាំងអស់។

[០៩:៣៤:៤០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទ្រាឯល៖**

**ស៖** លោកសាក្សី នៅពេលដែលលោកកាន់តំណែងនៅតំបន់៣២នោះ លោកមិនដែលត្រូវបាន

គេចោទប្រកាន់ ឬក៏សង្ស័យ ទោះបីថាជាការសង្ស័យដោយអយុត្តិធម៌ក៏ដោយនោះ តើលោកមានធ្លាប់ជួបប្រទះបញ្ហាបែបនេះទេ?

[០៩:៣៥:០៥]

**លោក នី កន៖**

**ឆ៖** ចំពោះសំណួរនេះ ខ្ញុំសូមឆ្លើយជូន បុគ្គលខ្ញុំក៏មិនអាច មិនៗអាចវិនិច្ឆ័យថា តើថ្នាក់លើនោះសង្ស័យខ្ញុំយ៉ាងណាក៏មិនដឹងដែរ ចេះតែខំធ្វើការទៅ។ នេះសូមឆ្លើយជូនប៉ុណ្ណឹងបាទ។

**ស៖** លោកបាននិយាយអម្បាញ់មិញថា លោកត្រូវបញ្ជូនទៅក្រសួងការបរទេសនៅចុងឆ្នាំ៧៧ ឬក៏ដើមឆ្នាំ៧៨ តើអ្នកណាជាអ្នកបញ្ជូនគាត់ពីភូមិភាគបស្ចិមទៅក្រសួងការបរទេស?

**ឆ៖** សូមជម្រាបជូនបាទ។ អំណាចនៃការដកហូត ឬការផ្លាស់ប្តូរពីកន្លែងនីមួយៗ គឺមានតែគណៈកម្មការភូមិភាគ គឺគេប្រើពាក្យថា “មេភូមិភាគ” បាទ។ ប៉ុណ្ណឹងបាទ។

**ស៖** តើគណៈកម្មការភូមិភាគបានប្រាប់លោកពីមូលហេតុ ដែលបញ្ជូនលោកទៅក្រសួងការបរទេសដែរឬទេ? ម្សិលមិញលោកនិយាយថា ដោយសារតែលោកជាអ្នកចេះអក្សរ តើមានមូលហេតុផ្សេងទៀតដែរឬទេ ដែលគេប្រាប់លោកនោះ ពេលដែលគេបញ្ជូនលោកទៅក្រសួងការបរទេស?

[០៩:៣៧:១៣]

**ឆ៖** មូលហេតុមានតែមួយដដែល គឺជាមូលហេតុមូលដ្ឋានគឺថាខ្ញុំចេះអក្សរ ចេះលេខច្បាស់លាស់ ពីព្រោះជាគ្រូបង្រៀន ដូច្នេះឲ្យមកទទួលការងារនៅក្រសួងសមស្របជាង។ ឯមូលហេតុដទៃទៀតខ្ញុំមិនដឹងដែរ។ ដែលខ្ញុំបានទទួលពាក្យបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** បាទសូមអរគុណ។ អ៊ីចឹងលោកនិយាយថា ការបញ្ជូនរបស់លោកទៅក្រសួងការបរទេសនុំងពុំមានអ្វីទាក់ទងទៅនឹងការចាប់ខ្លួនមនុស្សជាច្រើន ឬការបោសសម្អាតនៅភូមិបស្ចិមនោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបានបញ្ជាក់ជូនអំមិញច្បាស់ហើយ តែសូមបញ្ជាក់ម្តងទៀត មូលហេតុដទៃខ្ញុំមិនដឹងទេ។ ថ្នាក់លើកនុំងមិនបានបញ្ជាក់ថា មូលហេតុអីទេ បញ្ជាក់តែមូលហេតុថា ចេះប៉ុណ្ណឹងបាទ។

[០៩:៣៨:៤៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតអានសម្រង់មួយនៃឯកសារ ដែលនិយាយយ៉ាងច្បាស់អំពីលោក

សាក្សីនេះ គឺឯកសារដែលអង្គជំនុំជម្រះបានទទួលយកហើយ គឺឯកសារ E3/89 ហើយនិង IS20.6 នេះគឺជាកិច្ចសម្ភាសរបស់លោក អៀង សារី ដោយលោក ស្ទីវ ហេដឌ័រ នៅខែធ្នូ ឆ្នាំ១៩៩៦។ ខ្ញុំសូមអានសម្រង់មួយដែលនៅទំព័រ ERN គឺថា 00062471 រហូតដល់ 72, ជាភាសាអង់គ្លេស 00417313 ដល់ 15, ជាភាសាបារាំងគឺ 00332695 ហើយនិងទំព័រពីរបន្ទាប់ទៅទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

[០៩:៤០:០០]

**លោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោក លោកស្រីចៅក្រមជាទីគោរព។ សូមអរគុណលោកប្រធាន អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងជុំវិញបន្ទប់សវនាការ។ ជាទូទៅខ្ញុំមិនជំទាស់ទេ ប្រសិនបើយើងនៅក្នុងស្ថានភាពធម្មតា យើងប្រើប្រាស់ភស្តុតាងចំពោះសាក្សី។ ហើយយើងមិនជំទាស់ទេ ប្រសិនបើនីតិវិធីយើងតទល់គ្នា។

នៅក្នុងនីតិវិធីនេះ នៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចមួយចំនួនរួចមកហើយ។ សេចក្តីសម្រេចមួយចំនួន ខ្ញុំមិនឯកភាពជាមួយនោះទេ។ ក៏ប៉ុន្តែសេចក្តីសម្រេចទាំងឡាយបានលើកឡើងអំពីការប្រើប្រាស់ចម្លើយរបស់បុគ្គលដទៃមកតទល់សាក្សី ដែលនៅចំពោះមុខតុលាការនេះ។

[០៩:៤០:៤៨]

យើងដឹងហើយ នេះជាការវិវត្តន៍ថ្មីមួយ យើងមិនដែលជួបប្រទះទៅនឹងស្ថានភាពនេះទេ។ សហព្រះរាជអាជ្ញាចាប់ផ្តើមសុំការអនុញ្ញាត ហើយការអនុញ្ញាតនេះមិនទទួលបានផងនោះ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញានឹងគាត់បន្តសួរទៅលើអត្ថបទនេះ។ ដូច្នេះនៅក្នុងចំណុចនេះ ដំណាក់កាលនេះ ខ្ញុំស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាកាលៈទេសៈនៃសក្ខីកម្មមួយនេះ ថាតើអាចប្រើប្រាស់ដើម្បីតទល់សាក្សីរូបនេះដែរឬទេ?

ដូចដែលខ្ញុំបានបញ្ជាក់ហើយ យើងបានជួបប្រទះស្ថានភាពហ្នឹងពីមុននោះរួចមកហើយ។ ប្រសិនបើមានការឯកភាពពីអង្គជំនុំជម្រះនោះ មិនជាការអ្វីនោះទេ។ ដូច្នេះហើយសាក្សីដែលមកផ្តល់សក្ខីកម្ម គឺយើងទាំងអស់គ្នានឹងទទួលបានអនុញ្ញាតការប្រើប្រាស់ឯកសារ ដោយប្រើឯកសារ-- លេខ

យោងបង្ហាញជូនសាក្សី។ ជាពិសេសនៅពេលដែលឯកសារទាំងអស់នោះទាក់ទងទៅនឹងបុគ្គលដែលគាត់មិនមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ យើងខ្ញុំស្នើសុំឲ្យយើងទាំងអស់គ្នាគោរពសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ ហើយឲ្យអង្គជំនុំជម្រះពិចារណាមុនពេលដែលសហព្រះរាជអាជ្ញាបន្តនីតិវិធី។ សូមអរគុណ។

[០៩:៤២:០៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ នៅក្នុងករណីនេះ គឺថា ករណីនេះមិនដែលកើតមានឡើងទេ គឺថាប៉ុន្តែមានទំនាក់ទំនងយ៉ាងច្បាស់រវាងឯកសារ ដែលសម្រង់នេះ ហើយនិងសាក្សី ពីព្រោះថាមានឈ្មោះគាត់នៅក្នុងហ្នឹង។ ហើយមានធ្វើការអធិប្បាយរបស់លោកជនជាប់ចោទ អៀង សារី ដែលនៅក្នុងកិច្ចសម្ភាសរបស់គាត់។ ហើយអង្គជំនុំជម្រះបានទទួលយក ហើយខ្ញុំគិតថាជារឿងធម្មតាទេ ដែលយើងផ្ដល់លទ្ធភាពទៅដល់សាក្សីក្នុងការបញ្ចេញប្រតិកម្ម ទៅនឹងសម្រង់នេះ បើសិនជាអង្គជំនុំជម្រះអនុញ្ញាត។ ហើយសូមឲ្យគាត់អាន ហើយឬក៏យើងសុំឲ្យគាត់-- ឲ្យរំឭកការចងចាំរបស់គាត់វិញ និងរំឭកទៅដល់កាលៈទេសៈ ដែលគាត់បានទៅក្រសួងការបរទេសនោះ។ សូមអរគុណលោកប្រធាន។

[០៩:៤៣:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៥:១៤]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក អៀង សារី លើការលើកយក ដកស្រង់នូវឯកសារ E3/89 មកសួរដេញដោលចំពោះសាក្សីរូបនេះគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអាចយកឯកសារនេះមកប្រើប្រាស់ ដើម្បីសួរដេញដោលចំពោះសាក្សីនេះបាន។ សូមអញ្ជើញ!

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ចំណុចបញ្ចាក់មួយ ខ្ញុំមិនជំទាស់ទេ ខ្ញុំសូមឲ្យចេញសេចក្ដីសម្រេច ដើម្បីឲ្យយើងយល់ឲ្យច្បាស់។ ខ្ញុំមិនជំទាស់ទេ ក៏ប៉ុន្តែឲ្យមានសេចក្ដីសម្រេចឲ្យបានច្បាស់លាស់នៅក្នុងប្រតិចារឹកដល់សាធារណជន។ ការធ្វើដូច្នេះ គឺខ្ញុំសូមសេចក្ដីសម្រេចដើម្បីឲ្យយើងយល់ច្បាស់ទាំងអស់គ្នា កុំឲ្យមានការភិតភ័យសម្រាប់យើងប្រើប្រាស់នៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

មូលហេតុ សំអាងហេតុនៅក្នុងការ ករណីនេះ គឺខុសប្លែកពីករណីដទៃទៀតដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។ ករណីនេះ គឺជាបទសម្ភាសជាមួយនឹងជនជាប់ចោទ អៀង សារី ហើយនៅពេលនេះ អៀង សារី បាន និងកំពុងមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ។ ប្រសិនបើគាត់ស្ដាប់បាន ហើយមានបញ្ហា អាចគាត់ អាចតទល់ជាមួយនឹងសាក្សីរូបនេះបាន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៤៧:២២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ដូច្នេះ ខ្ញុំនឹងអានសម្រង់ដែលខ្ញុំបានផ្ដល់ជូនទូវលេខរួចមកហើយនេះ។ ក្នុងឯកសារនោះ មានសរសេរថា "ស្ទីវ៖ ហើយ នី កន គេបញ្ជូលមកពីពេលណា? គឺបញ្ជូនទៅក្រសួងការបរទេសនុ៎ង។ អៀង សារី ឆ្លើយ៖ ពេលឆ្នាំ៧៨ គឺដើមឆ្នាំ ដើមឆ្នាំ៧៨ អ៊ូ!អត់ទេ ចុងឆ្នាំ៧៧ គឺមកតាំងពីខែកក្កដា ឆ្នាំ៧៧។ បាទ គឺខែកក្កដា ឆ្នាំ៧៧ នៅពេលដែលគេចោទគាត់ហ្នឹងថាមានរឿងរ៉ាវអីទាក់ទងជាមួយ សេ.អ៊ី.អា។ ទាំងអស់ហ្នឹងបានគេដាក់មក ដូចជាបងប្អូនជាមួយ សុន សេន ហ្នឹង។ អ៊ីចឹងគេដាក់គាត់មកខាងក្រសួងការបរទេស។ តើមានអ្នកណាដែលមានគេ-- ដែលមានរឿងគេចោទថា សេ.អ៊ី.អា ឬក៏ចោទថា មានការទាក់ទងអីហ្នឹង អ្នកដែលគេមិនទាន់ធ្វើ មិនទាន់មានអាដែងគេហៅថាភស្តុតាង ឬក៏មិនទាន់មានធ្វើទុក្ខទោសហ្នឹង គេឲ្យមកដាក់ក្រសួងការបរទេសទាំងអស់។ ដូចណាត ហ្នឹងក៏យកមកក្រសួងការបរទេស ហុក ហ្នឹងក៏យកមកក្រសួងការបរទេស"។

[០៩:៤៨:៤៧]

សំណួររបស់ ស្ទីវ ហេដឌ័រ៖ ពីមុន នី កន ហ្នឹងនៅតាមមូលដ្ឋាន តើនៅកន្លែងណាដែរ? ចម្លើយរបស់ អៀង សារី៖ នៅបស្ទិម ស្រុកឧដុង្គ។ សូមបញ្ចប់ការដកស្រង់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើលោក អៀង សារី មិនដែលនិយាយប្រាប់លោកអំពីមូលហេតុពិតប្រាកដនៃការផ្ទេរលោក មកក្រសួងការបរទេសនោះទេ នៅពេលដែលលោកមកដល់នោះ ឬមួយក៏បងប្រុសរបស់លោក សុន សេន តើគាត់ធ្លាប់មានបាននិយាយអំពីមូលហេតុពិតប្រាកដប្រាប់លោកទេ នៅពេលក្រោយមកនោះ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ដូចខ្ញុំបានជម្រាបជូនអង្គសវនាការអម្បាញ់មិញ គឺហេតុផលដែលបញ្ជូនខ្ញុំមកគឺនិយាយតែប៉ុណ្ណឹង។ និយាយថា ខ្ញុំនៅកន្លែងនុ៎ងមិនសមស្រប ព្រោះការងារខាងនុ៎ងមិនទាមទារអ្នកចេះអក្សរ ចេះលេខអីច្បាស់លាស់ទេ។ ដូច្នេះមកខាងក្រសួងសមស្របជាង។ រួចហើយ ក៏មកទៅ។ ដល់មកទៅ ក៏ឲ្យខ្ញុំនៅក្នុងប្រអប់ គេហៅថា ពិធីការ។ រួចហើយ ឲ្យខ្ញុំរត់ការងារជូនភ្ញៀវ ឯរឿងថាប្រាប់ខ្ញុំ ត្រូវគេចោទថា សេ.អ៊ី.អា យ៉ាងនេះ យ៉ាងនោះ គ្មាននរណាប្រាប់ទេ។

[០៩:៥០:៣៤]

ហើយតាមខ្ញុំយល់ ដូចបានជម្រាបលោកប្រធានពីម្សិលមិញ គឺថាលាក់ការណ៍សម្ងាត់ហ្នឹងខ្ពស់ណាស់។ ការចាត់ចែងអី វានៅលើខាងលើទាំងអស់ មិនអាចយកពាក្យពេចន៍ដែលពាក់ព័ន្ធដល់ខ្លួនបុគ្គលអីមកប្រាប់ទេ។ ដូច្នេះ រហូតមកថ្ងៃនេះ ខ្ញុំក៏អត់ដឹង ទើបដឹងតាមលោកសហព្រះរាជអាជ្ញាបានបំភ្លឺតាមថា ខ្លឹមសារអម្បាញ់មិញនេះបាទ។ នេះ សូមឆ្លើយជូនប៉ុណ្ណឹងបាទ។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ អៀង សារី គាត់ចងចាំថា គឺលោកមកដល់ក្រសួងការបរទេស នៅខែកក្កដា ឆ្នាំ១៩៧៧ ហើយលោកអម្បាញ់មិញ លោកនិយាយអំពីចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨។ តើលោកឯកភាពចំពោះសម្ដីរបស់លោក អៀង សារី ទេ ថាលោកបានចូលទៅក្រសួងការបរទេសនោះ គឺថានៅដើម៧៧ តើលោកអាចនឹកឃើញឡើងវិញទេ?

[០៩:៥១:៥១]

**ឆ៖** ខ្ញុំចងចាំមិនច្បាស់ទេ ខ្ញុំប្រើពាក្យថាប្រហាក់ប្រហែល បាទ។ ដូច្នេះ ខ្ញុំចាំបានប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកទៅដល់ក្រសួងការបរទេស តើគឺលោក អៀង សារី ហ្នឹងហើយដែលជាអ្នកសម្រេចឲ្យលោកកាន់មុខងារនៅក្រសួងការបរទេសនោះ មែនទេ?

**ឆ៖** រចនាសម្ព័ន្ធនៅក្រសួងនោះ តួនាទីសំខាន់ គឺប្រធានមន្ទីរ។ ដូច្នេះ ខ្ញុំទទួលការណែនាំផ្ទាល់ពីប្រធានមន្ទីរ បាទ។ ប្រធានមន្ទីរឲ្យនៅត្រង់ណា នៅត្រង់ហ្នឹង។ ឲ្យធ្វើអី ធ្វើហ្នឹង។ ដូច្នេះ មិនបានទទួលផ្ទាល់ទេ គឺបានផ្ទាល់-- អ៊ំ ទទួលៗ បន្តបាទ។

**ស៖** លោកបាននិយាយថា លោកធ្វើការនៅផ្នែកពិធីការ ប៉ុន្តែតើលោកមានមុខងារអី ឲ្យប្រាកដនៅក្នុងផ្នែកពិធីការហ្នឹង?

**ឆ៖** ផ្នែកពិធីការ មុខងារច្បាស់របស់ខ្ញុំ ក្នុងរយៈពេលខ្លី។ គឺមួយ មានភ្ញៀវជាបុគ្គល មិនមែនគណៈប្រតិភូ គឺឲ្យខ្ញុំជូនទៅមើលអង្គរវត្ត។ ហើយទៅមើលអង្គរវត្តម្តងៗ គឺមានយុវជន យុវនារី ពីរទៅបីនាក់ អមដំណើរជាមួយខ្ញុំ។ រយៈពេលប្រហែលមួយអាទិត្យ ម៉ាអាទិត្យលើស ផ្លូវពិបាក។ ក្រៅពីហ្នឹងមានតែបោសសម្អាតផ្ទះ លាងបង្គន់ លាងអីប៉ុណ្ណឹង ជាមួយនឹងយុវជន យុវនារី ហ្នឹងទៅ ដើម្បីទទួលភ្ញៀវ។ មុខងារច្បាស់លាស់ប៉ុណ្ណឹងបាទ ដែលជាមូលដ្ឋាន ហើយក្រៅពីនុំងមិនមានអីទៀតទេ មានតែបើទំនេរ ជួយដាំបន្លែ ជុំវិញកន្លែងក្រសួង។ សូមបញ្ជាក់ជូនប៉ុណ្ណឹង។

[០៩:៥៥:០២]

**ស៖** តើលោកជាប្រធានផ្នែកពិធីការនៅក្រសួងការបរទេសមែនទេ?

**ឆ៖** មិនទាន់មានការប្រកាសជាផ្លូវការទេបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំសូមអានសម្រង់ខ្លីមួយនៃឯកសារដដែលនេះ គឺ E3/89 ឬក៏លេខ ES20.6 ERN ជាភាសាខ្មែរគឺ 00062472 ERN, ជាភាសាអង់គ្លេស 00417314, ERN ជាភាសាបារាំង 00332695។ ខ្ញុំសូមអានជាភាសាបារាំងម្តងទៀតគឺ ERN 00332695។ សំណួររបស់ "ស្ទីវ ហេដឌ័រ៖ ហើយដល់ឲ្យ នី កន មកនៅក្នុងក្រសួងហ្នឹង លោកចាត់ទុក-- ចាត់តាំងឲ្យធ្វើការអ្វីខ្លះ? ទទួលភ្ញៀវអ្ហេះ?" អៀង សារី ឆ្លើយ៖ "មែនទេ! ធ្វើពិធីការ ចាងហ្វាងពិធីការ"។ ស្ទីវ ហេដឌ័រ "អូ៎! ចាងហ្វាងពិធីការ!" បន្ទាប់មក អៀង សារី បន្តមកទៀត "នី កន នៅលើ សែ ប៉ុន្តែ នី កន ហ្នឹង គេហៅថាចាត់ចែងជាង ហុង ច្រើនណាស់"។ ឃ្លាចុងក្រោយហ្នឹងជាភាសាបារាំងបកទៅអត់ស្តាប់អត់បានសោះ។ ដូច្នេះ ខ្ញុំសូមអានសំណៅបកប្រែជាភាសាអង់គ្លេសវិញនៅឃ្លាចុងក្រោយនេះ។ មានបញ្ជាក់ថា "នី កន នៅលើ សូ សែ ប៉ុន្តែ នី កន ហ្នឹង គេហៅថាចាត់ចែងជាង ហុង ច្រើនណាស់"។

[០៩:៥៧:៣៦]

ខ្ញុំមិនដឹងថា តើខ្ញុំត្រូវនិយាយឡើងវិញ ឬក៏ម៉េច? ព្រោះខ្ញុំឃើញថាការបកប្រែដូចជានៅក្រោយឆ្ងាយណាស់។ ឃ្លាចុងក្រោយជាភាសាអង់គ្លេសនោះគឺថា "នី កន នៅលើ សូ សែ ប៉ុន្តែ នី កន ហ្នឹងគេហៅថាចាត់ចែងជាង ហុង ច្រើនណាស់"។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** ជាដំបូងលោកសាក្សី តើលោកឯកភាព ឬក៏យល់ស្របជាមួយ អៀង សារី ទេ ថាលោកជាចាងហ្វាងពិធីការនៅក្នុងក្រសួងការបរទេសពេញអំឡុងពេល ដែលលោកធ្វើការនៅទីនោះៗ?

**លោក នី កន៖**

**ឆ៖** សូមបញ្ជាក់សំណួរ ដែលសួរខ្ញុំពីពិធីការ ហើយចាត់ចែងលើ សែ លើ ហុង អី។ ទីមួយចាងហ្វាងពិធីការ ដូចខ្ញុំបានជម្រាបជូន គឺថាមកដល់ហ្នឹងជាប្រអប់ រួចម្ចាស់ប្រអប់ទៅណាមកណាខ្ញុំមិនដឹងទេ ហើយយកមកដាក់ឲ្យខ្ញុំចាត់ចែងទៅ។ ដូច-- ថាឲ្យខ្ញុំទទួលទៅៗ ទទួលហើយឲ្យភារកិច្ចថាផ្នែកទទួលភ្ញៀវ ជូនភ្ញៀវ។ ប៉ុន្តែទទួលភ្ញៀវហ្នឹងភាគច្រើនគឺជូនភ្ញៀវ ដែលខាងផ្នែកទទួលខុសត្រូវ គេទទួលមកហើយ។ ទីពីរ មិនឯកភាពទេ ព្រោះវាមិនប្រើពាក្យឲ្យវាចំថា ដូចអយុត្តិធម៌ហួសហេតុ។ ខ្ញុំឯណាទៅមានសមត្ថភាពលើគណៈមន្ទីរ លើគណៈកម្មាធិការក្រសួង។ ខ នេះមិនមានទេ បាទ។

[០៩:៥៩:៥៣]

**ស៖** លោកបាននិយាយថា ក្នុងឋានៈជាប្រធានស្តីទីនៃផ្នែកពិធីការ គឺមុខងាររបស់លោកហ្នឹងគឺជាសំខាន់នោះគឺថាជូនគណៈប្រតិភូបរទេស ឬក៏ជូនភ្ញៀវ។ តើមានភារកិច្ចអីផ្សេងទៀតទេ ដែលលោកត្រូវបំពេញនៅក្នុងក្រសួងការបរទេសនោះ? ខ្ញុំមិននិយាយអំពីការដាំបន្លែអីនោះទេ ចង់និយាយអំពីភារកិច្ចរបស់លោកពាក់ព័ន្ធទៅនឹងក្មេងៗ និងកុមារ តើលោកបានធ្វើអីខ្លះចំពោះពួកក្មេងៗទាំងនេះ?

**ឆ៖** ចំពោះក្មេងៗទាំងនេះ ម្តងម្កាលដែលខ្ញុំទំនេរជួយបង្រៀនអក្សរបាទ។ អក្សរ និងលេខ។

**ស៖** តើមានក្មេងៗប៉ុន្មាននាក់ដែលធ្វើការនៅក្រសួងការបរទេសនុ៎ង? តើពួកគេធ្វើអ្វីខ្លះ?

**ឆ៖** ខ្ញុំមិនចាំទេ តែខ្ញុំដឹងជារួមដោយសភាពការណ៍សង្គ្រាមកាន់តែខ្លាំង ហើយបែកខ្ញែកគ្នា។ ភៀសសឹកមិនដឹងនរណាទៅណាទៅណីទេបាទ។

[១០:០១:៤៨]

**ស៖** តើក្មេងៗដែលនៅក្រសួងការបរទេសនេះមកពីណាដែរ?

**ឆ៖** ជម្រាបជូន ដឹងថាមកពីគ្រប់ភូមិភាគ តែលម្អិតមិនដឹងទេបាទ។

**ស៖** តើក្មេងៗទាំងនេះមួយចំនួនធ្វើការក្នុងការទទួលភ្ញៀវ ឬក៏ជួយក្នុងការជូនដំណើរគណៈប្រតិភូឲ្យធ្វើទស្សនកិច្ចក្នុងប្រទេសដែរឬទេ?

**ឆ៖** ចំពោះក្មេងៗគេមិនឲ្យទៅទេ ឲ្យតែយុវជន និងយុវនារីបាទ។

**ស៖** តើអ្នកណាជាប្រធានផ្ទាល់របស់លោកនៅក្រសួងការបរទេស?

**ឆ៖** ប្រធានហ្នឹង គឺប្រធានមន្ទីរហ្នឹងហើយ។ ហើយប្រធានមន្ទីរហ្នឹងតាមខ្ញុំចាំ ដែលមកប្រគល់ការងារឲ្យខ្ញុំហ្នឹង គឺ ពេលនោះហៅឈ្មោះ ជាម បាទ។

**ស៖** តើលោកស្គាល់ឈ្មោះផ្សេងទៀតរបស់ ជាម ទេ តើជាម ហ្នឹង គាត់មានឈ្មោះអីផ្សេងទៀតទេ?

**ឆ៖** បាទ អត់ស្គាល់ទេ។

**ស៖** តើលោកស្គាល់ ជាម តាំងពីមុនមកនោះ តាំងពីសម័យសង្គ្រាមប្រាំឆ្នាំមកនោះមែនទេ?

**ឆ៖** ខ្ញុំស្គាល់ច្បាស់ហ្នឹង គឺនៅពេលមកធ្វើការនៅក្រសួងបាទ។

**ស៖** ប៉ុន្តែតើលោកធ្លាប់ឃើញគាត់ពីមុនមកទេ នៅក្នុងអំឡុងសង្គ្រាមនោះ?

**ឆ៖** ចំពោះលោក ជាម ហ្នឹង គឺគាត់ជាមនុស្សរបស់ខាងលើ។ ដូច្នេះចំពោះខ្ញុំអ្នកមូលដ្ឋានមិនបានជួបទេ។

**ស៖** លោកបាននិយាយថា ជាម ជាមេផ្ទាល់របស់លោក គឺជាប្រធានមន្ទីរ។ តើគាត់កាន់មន្ទីរអីដែរ?

**ឆ៖** មន្ទីរដែលខ្ញុំបញ្ជាក់ជូន ខ្ញុំសំដៅមន្ទីរនៅកន្លែងក្រសួងហ្នឹងតែម្តង តែកាន់មន្ទីរអីទៀតខ្ញុំមិនបានដឹងទេ។

**ស៖** តើ ជាម គាត់មានមុខងារអ្វីខ្លះនៅក្នុងក្រសួងការបរទេសនុ៎ង? គាត់ធ្វើអីជាសំខាន់នុ៎ង?

[១០:០៦:១៥]

**ឆ៖** ខ្ញុំជម្រាបជូន មុខងារដែលខ្ញុំឃើញ ខ្ញុំដឹង គឺឃើញគាត់គ្រប់គ្រងរួមហ្នឹង គ្រប់គ្រងពីរឿងចាត់ចែងការងារតាមផ្នែក អ្នកណាទៅណាៗ ហើយក្រៅពីហ្នឹងរឿងគាត់ផ្គត់ផ្គង់បាយទឹកឲ្យបុគ្គលិកក្រសួង។ ក្រៅពីហ្នឹងយ៉ាងម៉េចទៀត ខ្ញុំមិនដឹងទេ។

**ស៖** តើមានទំនាក់ទំនងអ្វីរវាងផ្នែកពិធីការ ហើយនិងផ្នែកសន្តិសុខនោះ? ឧទាហរណ៍ដូចជាខាងផ្នែកសន្តិសុខរបស់ភ្ញៀវអីជាដើម។

**ឆ៖** ខ្ញុំដូចពិនិត្យទៅមិនឃើញច្បាស់លាស់ ខ្លួនខ្ញុំទេចំពោះការពិតជាក់ស្តែងយ៉ាងម៉េច ខ្ញុំមិនដឹង ប៉ុន្តែចំពោះខ្ញុំដែលខ្ញុំនៅនុ៎ង ខ្ញុំមិនមែនអីជាច្បាស់លាស់ជាផ្លូវការទេ។

**ស៖** តើអ្នកណាជាមេផ្ទាល់របស់ ជាម? ឬមួយក៏ថា តើៗពី ជាម ទៅ អៀង សារី ហ្នឹងមានអ្នកណាខ្លះ? លោកបាននិយាយថា លោក អៀង សារី ជារដ្ឋមន្ត្រី បន្ទាប់មក ជាម ជាប្រធានផ្នែកប្រធានមន្ទីរ។ តើនៅចន្លោះ អៀង សារី ហើយនិង ជាម មានអ្នកទៀតផ្សេងនៅ-- អ្នកណានៅកណ្តាលហ្នឹងទេ?

[១០:០៨:៣៤]

**ឆ៖** ជម្រាបជូន គឺចន្លោះកណ្តាលហ្នឹងក៏មានដែរ តាមដែលខ្ញុំឃើញ។ ប៉ុន្តែឲ្យប្រាកដថាច្បាស់លាស់យ៉ាងម៉េច ខ្ញុំមិនច្បាស់ទេ គ្រាន់ដូចលោកបានបញ្ជាក់ជូនខ្ញុំអំមិញហ្នឹងថា មានសម្ភាសហ្នឹងមាន ហុង, សែ អ៊ីចឹង ប៉ុន្តែខ្ញុំដឹងថា មានតែ ហុង, ជាម ហ្នឹងប៉ុណ្ណឹងបាទ។ រួចក្រៅពីហ្នឹងសុទ្ធតែអ្នកបច្ចេកទេស។ អ្នកបច្ចេកទេសដូចខ្ញុំហ្នឹង គេហៅថា ផ្នែកដែលគេចាត់ចែង។ ដូច្នេះទទួលបទបញ្ជាផ្ទាល់ពី ជាម ហ្នឹងទៅ ចាត់ចែងទៅ។ បាទ ប៉ុណ្ណឹងបាទ។

**ស៖** នៅពេលដែលលោកបំពេញមុខងាររបស់លោកក្នុងនាមជា ចាងហ្វាងពិធីការ តើលោកតែងតែគោរពសេចក្តីណែនាំ និងស្ថិតនៅក្រោមឱវាទថ្នាក់លើរបស់លោកមែនទេ?

**ឆ៖** សូមជម្រាបជូនថា គោរពហើយ ណែនាំម៉េច ធ្វើអ៊ីចឹងហើយបាទ។

[១០:១០:០៨]

**ស៖** តើ ជាម និង ហុង គាត់តែងតែគោរពបញ្ជាដែលចេញមកពីថ្នាក់លើដែរមែនទេ? គឺមានន័យថា គឺចេញមកពីលោក អៀង សារី ដែលជារដ្ឋមន្ត្រីនោះ តើអ៊ីចឹងមែនទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានសូមអធ្យាស្រ័យ។ សំណួរនេះ គឺវាជាសំណួរនាំមុខ ហើយគួរតែផ្តល់ព័ត៌មានដើម្បីឲ្យសាក្សីបានដឹង។ សាក្សីគាត់ប្រាកដជាផ្តល់ព័ត៌មាន។ យើងមិនអាចយកពាក្យដែលពីព្រះរាជអាជ្ញាដាក់ឲ្យសាក្សីនិយាយតាមនោះទេ។ ហើយក៏យើងមិនអាចឲ្យសាក្សីស្មាន ឧបមានោះផងដែរ។ ដូច្នេះយើងគួរតែសួរព័ត៌មាន មួយដំណាក់កាលម្តងៗ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធានខ្ញុំនឹងរៀបចំសំណួរឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាងឈលៈ**

**សៈ** ចាតើលោកស្ដាប់បង្គាប់ថ្នាក់លើផ្ទាល់របស់លោកនោះយ៉ាងម៉េច? តើ ជាម ជាមេផ្ទាល់របស់លោកនោះ ក៏គាត់ធ្វើដូចលោកដែរមែនទេ? គឺថា គាត់ត្រូវស្ដាប់ថ្នាក់លើបន្តរបស់គាត់មកទៀតអ៊ីចឹងមែនទេ?

[១០:១១:៣០]

**លោក នី កនៈ**

**ឆៈ** សូមជម្រាបជូន គឺលំដាប់ដំណើរនៃការប្រតិបត្តិជាទូទៅ គឺអ៊ីចឹង។ ខ្ញុំបើនៅក្រោម ជាមៗណែនាំខ្ញុំស្ដាប់ ហើយ ជាម ក៏យកការណែនាំនុ៎ងប្រាប់ថា ខាងលើប្រាប់មកឲ្យធ្វើអ៊ីចឹង។ ដូច្នេះខ្ញុំមិនអាចប្រកែកអីយ៉ាងម៉េចទេ ពីព្រោះអង្គាល់ណោះជាវិន័យដែកថែប ដូចខ្ញុំនិយាយអ៊ីចឹង គឺទាំងអស់គ្នាដំណើរការតាមវិន័យហ្នឹង។ ហើយតាមមើលខ្ញុំយល់ បើមិនខុសទេក៏ប្រហែលតែគ្នាហ្នឹង ដូចតែគ្នាហ្នឹងបាទ។ បាទសូមជម្រាបជូនប៉ុណ្ណឹង។

**សៈ** អម្បាញ់មិញនេះ លោកនិយាយថា អៀង សារី ជាអ្នកទទួលខុសត្រូវនៅក្នុងក្រសួងការបរទេស។ តើលោកដឹងទេថា គាត់មានកាន់មុខងារអ្វីផ្សេងទៀតទេ នៅក្នុងជួរនៃអង្គភាពដឹកនាំនោះ នៃរបបខ្មែរក្រហមនោះ?

[១០:១២:៤៥]

**ឆៈ** សូមបញ្ជាក់ កិច្ចការអស់នេះវាហួសពីសមត្ថភាពខ្ញុំហើយ។ ខ្ញុំមិនដឹងទេ បាទ។

**សៈ** អម្បាញ់មិញនេះលោកមិនបាន-- បាននិយាយថា លោកមិនដឹងច្បាស់អំពីមុខងាររបស់ហុង និង សូ សៃ ទេ ដែលថាជាមេរបស់ ជាម នោះ។ អ៊ីចឹងតើលោកស្គាល់អំពីមុខងាររបស់អ្នកធ្វើការនៅក្រសួងការបរទេសផ្សេងទៀតទេ? ឧទាហរណ៍ដូចជា សួង ស៊ីគឿន ហៅ គង់ តើលោកស្គាល់គាត់ទេ?

[១០:១៣:៣៤]

**ឆៈ** សូមបញ្ជាក់ ស្គាល់ តែការងារមិនដឹងទេ។ ការងារល្អិតមិនដឹងទេ។ អានេះផ្នែកមួយៗចាត់ចែងតាមផ្នែក។

**សៈ** នៅក្រសួងការបរទេស តើលោកធ្លាប់ជួបជនជាតិបារាំងម្នាក់ដែលឈ្មោះ ឡូរ៉ង់ ពិច ហៅ ផល ដែរឬទេ?

**ឆ៖** ចំពោះបារាំងម្នាក់ជា-- ដែលនៅក្នុងក្រសួងហើយឈ្មោះ ឡូរ៉ង់ ឈ្មោះអីនេះខ្ញុំមិនស្គាល់ឈ្មោះទេ។ ប៉ុន្តែខ្ញុំស្គាល់ថា មានបារាំងស្រីម្នាក់ ហើយនៅក្នុងក្រសួងហ្នឹង។ រួចហើយដឹងថា ជាប្រពន្ធអី! ជាៗប្តីគឺខ្មែរ ខ្មែរហ្នឹងឈ្មោះ គង់។ ខ្ញុំបញ្ជាក់ជូនម្តងទៀត ខ្មែរហ្នឹង ឈ្មោះ គង់។ ខ្ញុំស្គាល់បានប៉ុណ្ណឹង បាទ។

[១០:១៥:០៨]

**ស៖** ក្នុងចំណោមអ្នកធ្វើការនៅក្រសួងការបរទេសហ្នឹង តើលោកស្គាល់ឈ្មោះ ជួន ប្រាសិទ្ធិ ដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់តាមរយៈពិធីទទួលភ្ញៀវ គណៈប្រតិភូ ហើយគាត់អ្នកបកប្រែ ម្តងម្កាល។ ហ្នឹងសូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**ស៖** តើជាញឹកញាប់គាត់ជូនភ្ញៀវទៅ-- ចុះទៅមូលដ្ឋានដែរឬទេ?

**ឆ៖** តាមខ្ញុំឃើញ ដូចមិនសូវទេ មិនសូវទៅទេ ពីព្រោះគាត់ជាអ្នកបកប្រែ ពិធីធំៗ។

**ស៖** តើលោកស្គាល់លោក ឱក សុគន្ធ ហៅ មាន ដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ ឈ្មោះ គន្ធ តែហៅ មាន អីអត់ដឹងទេ ហើយ គន្ធ ហ្នឹងគាត់ធ្លាប់ជាអ្នកបកប្រែដែរ កាលណាមានភ្ញៀវជាតិបារាំងអី គាត់អ្នកបកប្រែ។

**ស៖** សូមអរគុណ។ តើលោកស្គាល់ ឡុង នរិន្ទ ហៅ រិទ្ធ នៅក្រសួងការបរទេសដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ឈ្មោះ រិទ្ធ តែ ឡុង នរិន្ទ មិនស្គាល់ទេ ពីព្រោះឈ្មោះក្នុងពេលសង្គ្រាមក្តី ឈ្មោះក្នុងពេលក្រោយសង្គ្រាមក្តី ឈ្មោះម្នាក់ៗមានច្រើន។ សូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**ស៖** នៅក្នុងក្រសួងការបរទេស បើតាមការហៅរបស់វិទ្យុនោះ ហៅថាជាសមមិត្តលេខាទទួលបន្ទុកខាងទំនាក់ទំនងជាមួយនឹងមិត្តកម្ពុជាប្រជាធិបតេយ្យនៅទូទាំងពិភពលោក។ តើលោកដឹងទេ តើអ្នកណាជាសមមិត្តលេខាគណៈកម្មាធិការទំនាក់ទំនងជាមិត្តនៃកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** អត់ស្គាល់ទេ។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីរយៈពេលដែលលោកទៅធ្វើការនៅក្រសួងការបរទេស ប្រសិនបើខ្ញុំយល់ច្បាស់នេះ គឺថា៧៧ លោកបាននិយាយថា លោកបានធ្វើការបីខែ។ តើលោកនៅតែរក្សាចម្លើយនេះដដែល ឬក៏លោកធ្វើការក្រសួងលើសពីបីខែ?

**ឆ៖** នេះជាការប៉ាន់ស្មានដោយរយៈពេលវែង ហើយមិនបានចាប់អារម្មណ៍កត់សម្គាល់នៃ

E1/77.1

ការងារអីទេ គិតតែខំធ្វើ។ ដូច្នោះ ខ្ញុំមិនប្រាកដប្រជាថា ដែលខ្ញុំបញ្ជាក់ហ្នឹងត្រឹមត្រូវ១០០% ទេ។

**សៈ** សំណួរលោកនៅក្រសួងការបរទេសរហូតដល់វៀតណាមចូលមែនទេ? ព្រោះថានេះជាហេតុការណ៍ដែលងាយស្រួលចងចាំណាស់រឿងរ៉ាវវៀតណាមចូលនេះ។

[១០:២០:០០]

**ឆៈ** បាទ ដល់វៀតណាមចូលដល់ភ្នំពេញហ្នឹង នាំគ្នារត់ទៅលិចទៅ។

**សៈ** ដូច្នេះ ខ្ញុំសង្ខេប-- សន្និដ្ឋានទៅ បើសិនជាខ្ញុំគណនាចំនួនខែពីចន្លោះដើម៧៧ ដល់--ចុង ៧៧ ដល់ដើម៧៨ រហូតដល់ពេលវៀតណាមចូលមកនោះ ខ្ញុំគិតទៅប្រហែលជា១២ ខែ ឬក៏លើសពី ១២ទៀត តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ខ្ញុំមិនបានគិតទេ។ ដូច្នោះខ្ញុំមិនហ៊ានថា ត្រឹមត្រូវ១០០% ក៏មិនហ៊ានថា ប៉ុន្តែខ្ញុំមិនបានកំណត់ដែរ។ ការប្រហាក់ប្រហែល ខ្ញុំមិនបានគិតទាល់តែសោះ រឿងហ្នឹងបាទ។

**សៈ** សូមអរគុណ។ ឥឡូវនេះ យើងនឹងនិយាយអំពីតួនាទីរបស់លោកជាប្រធាន ឬក៏ចាងហ្វាងពិធីការ និយាយអំពីទស្សនកិច្ចរបស់គណៈប្រតិភូបរទេស។ ក្នុងឋានៈជាចាងហ្វាងពិធីការ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេស តើលោកត្រូវទៅព្រលានយន្តហោះពោធិ៍ចិនតុងញឹកញាប់ដែរឬទេ ដើម្បីទទួលគណៈប្រតិភូបរទេស ឬទទួលមេដឹកនាំនៃរបបខ្មែរក្រហមដែលត្រឡប់មកពីបំពេញទស្សនកិច្ចនៅបរទេសវិញនោះ?

[១០:២២:១៤]

**ឆៈ** ចំពោះការទទួលខុសត្រូវ ការទទួលភ្ញៀវបរទេស ឬទទួលដឹកនាំអីនេះ គេចែកជាផ្នែក។ ដូច្នេះ ខ្ញុំបានម្តងម្កាលទេ។ ផ្នែកណាដែលមិនសូវសំខាន់ បានខ្ញុំ។ ផ្នែកណាសំខាន់ គេមានឲ្យតម្លៃទៅអ្នកដែលទៅទទួលហ្នឹងតាមថ្នាក់ តាមជាន់របស់គេ។ ហើយមិនបានញឹកញាប់ទេ។

**សៈ** ខ្ញុំចង់ឲ្យលោក-- ខ្ញុំចង់រំឭកការចងចាំរបស់លោក នៅក្នុងសំណុំរឿងគឺមានអត្ថបទមួយរបស់ហ្វីប៊ីស អេហ្វ.ប៊ី.អាយ.អេស ដែលបានផ្សាយ-- ចុះអំពីការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិប-តេយ្យ។ អត្ថបទនេះមានលេខ E3/1361 ឬក៏ D262.40 ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ៧៨។ យើងមានតែ ERN ជាភាសាអង់គ្លេសនៅពេលនេះ គឺមានលេខ 001680-- សូមទោសម្តងទៀត 00168863។ លោកសាក្សី អត្ថបទនេះគឺបានចុះការផ្សាយរបស់វិទ្យុភ្នំពេញ ដែលនិយាយអំពីការមកដល់របស់លោកឡេអង់ បៀកស្តាំង មកពីបក្សកុម្មុយនីសម៉ាក្ស-លេនីន អាមេរិក នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៨

ហើយនិងនិយាយថា លោក ឡេអង់ បៀកស្តាំង នេះត្រូវបានទទួលស្វាគមន៍ដោយសមមិត្តចាងហ្វាងពិធីការនៃក្រសួងការបរទេសនៅព្រលានយន្តហោះពោធិ៍ចិនតុង។ តើលោកនឹកឃើញថា លោកធ្លាប់បានទទួល ឬក៏បានជួប ឡេអង់ បៀកស្តាំង ដែលជាតំណាងបក្សកុម្មុយនីសម៉ាក្ស-លេនីន អាមេរិកដែរឬទេ?

[១០:២៤:៥៥]

**ឆ៖** ជម្រាបជូន ខ្ញុំមិនចាំទេ។ ហើយភ្ញៀវមានគួរសមដែរ មួយរយៈហ្នឹង។ ដូច្នេះ ឈ្មោះអីៗអ្នកណាអី អ្នកណា ខ្ញុំមិនចាំ ទេ។

**ស៖** ប្រសិនបើថា លោកមិនបានទៅព្រលានយន្តហោះញឹកញាប់ទេ តើអ្នកណានៅក្នុងក្រសួងហ្នឹងទទួលបន្ទុកទៅ? តើរដ្ឋមន្ត្រីផ្ទាល់តែម្តង ឬក៏មានអ្នកណាផ្សេងទៀត ដែលទទួលបន្ទុក ទទួលគណៈប្រតិភូបរទេសនៅព្រលានយន្តហោះពោធិ៍ចិនតុងនោះ?

**ឆ៖** សូមបញ្ជាក់ អ្នកដែលផ្លាស់ប្តូរទៅទទួលនុ៎ង គេគិតតាមតម្លៃ ឬគុណភាពដែលជាមនុស្សចាស់ស្គាល់សកលលោក ចេះភាសា ចេះពិធីការអន្តរជាតិ។ ឯខ្ញុំហ្នឹង ពិធីការវាយរងនៅជនបទហ្នឹងទើបតែមកពីជនបទ។ ដូច្នោះ ខ្ញុំចាំគឺមានលោក ឱក សុគន្ធ អីហ្នឹង លោក សុគន្ធ ហៅគន្ធៗហ្នឹងបាទ។ ខ្ញុំចាំពាក្យអង្គាល់ណោះ គឺ គន្ធ។ ហើយអាចមួយទៀត លោក ប្រាសិទ្ធិ អាហ្នឹងភាគច្រើនឃើញអីចឹង។ ឯខ្ញុំអត់ទេ ទាល់តែភ្ញៀវធម្មតាៗ។

[១០:២៧:០៥]

**ស៖** ពាក់ព័ន្ធទៅនឹង អៀង សារី តើលោកចាំទេថា អៀង សារី ទៅព្រលានយន្តហោះញឹកញាប់ ដើម្បីទទួលគណៈប្រតិភូជាន់ខ្ពស់ហ្នឹង?

**ឆ៖** បើតាមរចនាសម្ព័ន្ធ ធម្មតាតែជាន់ខ្ពស់ ទាល់តែជាន់ខ្ពស់។ ដូច្នេះ គឺគាត់ហ្នឹង តា អៀង សារី ហ្នឹងហើយ គាត់ទៅ ប៉ុន្តែទៅប៉ុន្មានដង ជាមួយភ្ញៀវណា ខ្ញុំមិនចាំទេ។

**ស៖** ក្នុងឋានៈជាចាងហ្វាងពិធីការ តើលោកត្រូវចូលរួមនៅក្នុងពិធីលៀងសាយភោជន៍ ពិធីជប់លៀង ឬកម្មវិធីផ្សេងៗ ឬក៏ការសម្តែងទស្សនីយភាព ការសម្តែងសិល្បៈ ឬក៏ការបញ្ចាំងខ្សែភាពយន្តសម្រាប់គណៈប្រតិភូបរទេស ឬក៏រៀបចំឡើងដោយស្ថានទូតបរទេសនៅទីក្រុងភ្នំពេញ។ តើលោកមានចាំទេ តើលោកធ្លាប់បានចូលរួមទេ? ហើយបើចាំនោះ សូមលោកផ្តល់ជាឧទាហរណ៍ខ្លះៗ?

**ឆ៖** សូមបញ្ជាក់ចម្លើយហ្នឹងម្តងទៀត អើ!សំណួរៗម្តងទៀត ពីព្រោះខ្ញុំយល់មិនទាន់។

**ស៖** ខ្ញុំចង់ដឹងថា ក្នុងឋានៈលោកជាចាងហ្វាងពិធីការ តើលោកធ្លាប់បានចូលរួមក្នុងពិធីសំខាន់ៗ ដូចជាពិធីជប់លៀង ពិធីលៀងសាយភោជន៍ កម្មវិធីនានា ការសម្តែងសិល្បៈ ឬក៏កម្មវិធីបញ្ចាំងខ្សែភាពយន្ត ដែលត្រូវបានរៀបចំឡើងសម្រាប់គណៈប្រតិភូបរទេស ឬក៏ត្រូវបានរៀបចំឡើងដោយគណៈប្រតិភូបរទេស ដែលមកទស្សនៈកិច្ចនៅទីក្រុងភ្នំពេញនោះ។ តើលោកធ្លាប់ចូលរួមទេ?

[១០:២៩:២១]

**ឆ៖** ខ្ញុំធ្លាប់បានតែត្រឹមនាំ បង្ហាញ ចូលត្រង់នេះ ចូលត្រង់នោះ ហើយជួយទៅរៀបចំកៅអីមុនឯរឿងដែលចូលទៅ ចូលរួមក្នុងពិធីជប់លៀងអី ខ្ញុំអត់ទេ អត់បានទទួលទេ អត់បានចូលរួមទេ។ ហើយការបញ្ចាំងភាពយន្តអី ក៏ចងចាំមិនអស់ទេ ប៉ុន្តែភាគច្រើន គឺមានតែភាពយន្តចិនដែលយកមកបញ្ចាំងតាមរោងកុនចាស់ៗនៅភ្នំពេញហ្នឹង ឲ្យកម្មករ ឲ្យអ្នកក្រសួងមន្ទីរមើល។ អាហ្នឹងបានជួយចាត់ចែង។ តែប៉ុណ្ណឹងទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួល និងផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់រង់ចាំរបស់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងកំណត់ គឺម៉ោងដប់ខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកបាននិយាយថា លោកបានចូលរួមនៅក្នុងការរៀបចំការជប់លៀង ឬក៏ព្រឹត្តិការណ៍មួយចំនួន ហើយលោកនិយាយអំពីការបញ្ចាំងខ្សែភាពយន្ត។ល។ ដែលសម្រាប់គណៈប្រតិភូបរទេស។ តើនៅក្នុងឱកាសទាំងអស់នេះ លោកបានជួបជាញឹកញាប់ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១០:៥៣:០១]

**លោក នី កន៖**

**ឆ៖** សូមគោរពលោកប្រធាន និងអង្គសវនាការ។ មុននឹងឆ្លើយនឹងសំណួរនេះ ខ្ញុំសូមលើកសំណូមពរដែលខ្ញុំបានពិគ្រោះជាមួយនឹងលោកមេធាវី បញ្ជាក់ជូននូវពាក្យ "ចាងហ្វាង ពិធីការ"។ ខ្ញុំយល់មិនដល់ទេ តែការពិតជាក់ស្តែងរបស់ខ្ញុំគឺជាអ្នកទទួលផ្នែកមួយនៅក្នុងពិធីការ ហើយមានខាងលើៗទៀត ដូច្នេះខ្ញុំមិនមែនបើសិនជានិយមន័យថាចាងហ្វាងហ្នឹងវាធំ ខ្ញុំមិនមែននៅក្នុង-- ស្ថិតនៅក្នុងន័យហ្នឹងទេ។ នេះចង់បញ្ជាក់ជូនឲ្យច្បាស់ ក្រែងមិនច្បាស់ទៅ ច្រឡំតួនាទីហ្នឹងវាធំពេក។ ហើយខ្ញុំជឿថាអង្គសវនាការច្បាស់ជាយល់ មិនខុសពីខ្ញុំទេ ពីព្រោះបើមានសម្ភាសរបស់តា អៀង សារី ចោទខ្ញុំថា សេ.អ៊ី.អា នោះច្បាស់ជាគេមិនឲ្យខ្ញុំមានតួនាទីអីសំខាន់ទេ។ នេះជាការចង់បញ្ជាក់ ខ(១) ឯ ខ(២) ការកំណត់ពេលវេលា ខ្ញុំមិនចាំ ខ្ញុំចេះតែស្មានដែរទៅ ប៉ុន្តែបើខ្ញុំដឹងខ្លួនខ្ញុំ មិនវែងទេ មិនមានពេលវេលានៅក្នុងក្រសួងហ្នឹងវែងទេ បាទ។ នេះសូមប៉ុណ្ណឹង ហើយសូមឆ្លើយនឹងសំណួរសហព្រះរាជអាជ្ញាថា តើបានជួបអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យញឹកញាប់ទេ ក្នុងពេលធ្វើពិធីបញ្ចាំងកុន ឬពិធីជប់លៀងស្វាគមន៍គណៈប្រតិភូធំៗ? មិនបានញឹកញាប់ដែរទេ ពីព្រោះវាទៅតាមកម្រិតរបស់ភ្ញៀវ។ បើភ្ញៀវណាកម្រិតខ្ពស់អីយ៉ាងម៉េចនោះ កម្រិតខ្ញុំបានតែកម្រិតល្មមទេ។ មានអ្នកដែលខាងលើ ដែលខ្ញុំបានបញ្ជាក់ជូនអីចឹង គឺអ្នកដែលមានសមត្ថភាពភាសា មានសមត្ថភាពខាងយល់ដឹង កម្រិតខាងអន្តរជាតិអីៗហ្នឹង

បានទៅស្វាគមន៍។ បាទ សូមជម្រាបជូនបន្ថែមប៉ុណ្ណឹងបាទ។

[១០:៥៥:៤៧]

**ស៖** បាទ លោកនិយាយថាលោកមិនជួបថ្នាក់ដឹកនាំនៃរបបហ្នឹងញឹកញាប់ទេ។ ក្រៅពីលោក អៀង សារី និងលោក សុន សេន ដែលលោកស្គាល់នោះ តើលោកស្គាល់ ប៉ុល ពត, នួន ជា, ខៀវ សំផន ដែរឬទេ? ឬក៏អ្នកផ្សេងទៀតដែលមានឋានៈស្មើៗគាត់?

**ឆ៖** ក្នុងសភាពជាការរៀបចំរចនាសម្ព័ន្ធនៃរដ្ឋាភិបាលធម្មតាអ្នកដឹកនាំ ខ្ញុំតែងតែស្គាល់ហើយ ស្គាល់តាមរូបភាពក្នុងពិធី ឬក៏ក្នុងការដែលជូន-- ជប់លៀង ដែលខ្ញុំបានជម្រាបអម្បាញ់មិញថា ទៅរៀបចំតុកៅអី ហើយជួយនាំចង្អុលទិសចូលខាងណា ខាងណី អាហ្នឹងខ្ញុំស្គាល់បាទ។ តែការងារអាហ្នឹងដូចខ្ញុំជម្រាបដដែល គឺខាងលើគឺខាងលើហើយ ខ្ញុំមិនដឹងទេបាទ។

[១០:៥៧:២២]

**ស៖** តើលោកស្គាល់ឋានៈពិតប្រាកដរបស់ ប៉ុល ពត, នួន ជា, ខៀវ សំផន ដែរឬទេ?

**ឆ៖** បាទ ស្គាល់តាមរយៈ ដែលទទួលការប្រជុំសន្និបាតបើកទូលាយអីហ្នឹង ស្គាល់បាទ។ ស្គាល់ដូចខ្ញុំបញ្ជាក់អំមិញ គឺតួអង្គអ្នកដឹកនាំសំខាន់ៗអីចឹងមិនងាយបានជួបទេ ពីព្រោះមានថ្នាក់ មានជាន់។ ដូច្នេះ ស្គាល់តាមរយៈនៅពេលដែលមានប្រជុំបើកទូលាយ ឬសន្និបាតបើកទូលាយអីចឹងបានស្គាល់បាទ។

**ស៖** តើលោកអាចបញ្ជាក់ដោយសង្ខេបពីឋានៈបុគ្គល ដែលខ្ញុំបាននិយាយអម្បាញ់មិញនេះទេ ថាឋានៈគាត់ជាក់លាក់នុ៎ងអីទៅ?

**ឆ៖** ឋានៈរបស់-- សុំសួរត្រឡប់ទៅវិញ គឺឋានៈរបស់អ្នកដឹកនាំដែលសួរខ្ញុំអំមិញហ្នឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាគប្បីតាំងសំណួរមួយរូបម្តង ដើម្បីឲ្យបានងាយយល់ ហើយនិងងាយឆ្លើយជាក់ច្បាស់។

[១០:៥៩:១៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

**ស៖** ឋាន: និងមុខងាររបស់ ប៉ុល ពត ហ្នឹង គាត់មានមុខងារអី? ឋាន:អី?

**លោក នី កន៖**

**ឆ៖** ខ្ញុំដឹងតែថា មេដឹកនាំកំពូល។ បាទ ដឹងប៉ុណ្ណឹង។ ឯឋាន:យ៉ាងម៉េច ខ្ញុំមិនដឹងទេ។

[១១:០០:០១]

**ស៖** ចុះ នួន ជា គាត់មានឋាន: ហើយនិងមុខងារគាត់ហ្នឹងអ្វីដែរ? ព្រោះលោកធ្វើការនៅក្នុងពិធីការ ហើយលោកទទួលបន្ទុកក្នុងការ នៅពេលដែលមានប្រជុំហ្នឹង លោកជាអ្នករៀបចំចាត់ចែង។ តើលោកស្គាល់ឋាន: ហើយនិងមុខងាររបស់គាត់ដែរឬទេ លោក នួន ជា?

**ឆ៖** ខ្ញុំសូមជម្រាបជូន គឺក្រៅពី ប៉ុល ពត ដែលខ្ញុំជម្រាបថា មេដឹកនាំកំពូលហ្នឹង ក្រៅពីហ្នឹងគេហៅថា អ៊ំៗខាងលើ។ ដូច្នេះ លម្អិតថា ឋាន:ជាអីច្បាស់អត់មានទេ។

**ស៖** នៅក្នុងឋាន:លោកជាកម្មាភិបាលបក្ស តើលោកធ្លាប់និយាយរឿងអំពីមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ពេលនុ៎ងពាក្យ "មជ្ឈិមបក្ស" អីមិនដែលមាន មិនៗសូវប្រើអីទេ។ គេប្រើតែពាក្យ ៨៧ ដែលខ្ញុំឮ ខ្ញុំដឹងបាទ។

[១១:០១:៥៤]

**ស៖** តើលោកដឹងថា ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យហ្នឹងធ្វើការនៅកន្លែងណាដែរទេ? តើមានកន្លែងពិសេសណាមួយ ឬក៏ដែលគាត់ធ្វើការ ឬក៏គាត់ប្រជុំទេ? ខ្ញុំសំដៅលើ ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន។

**ឆ៖** សូមជម្រាបជូន គឺអត់ដឹងទេ កន្លែងហ្នឹងសម្ងាត់ណាស់។

**ស៖** ឥឡូវខ្ញុំ ត្រឡប់មកពេលដែលលោកអមដំណើរគណ:ប្រតិភូបរទេស ដែលមកទស្សនកិច្ចនៅប្រទេសកម្ពុជា។ លោកបាននិយាយថា លោកទៅចុះតាមមូលដ្ឋានបំពេញបេសកកម្មរយ:ពេលមួយអាទិត្យជួនកាល នេះជាមុខងារសំខាន់របស់លោក។ តើលោកអាចផ្ដល់ឧទាហរណ៍ទាក់ទងទៅនឹងគណ:ប្រតិភូបរទេសដែលលោកនាំដំណើរគាត់ទៅចុះទៅមូលដ្ឋាន គឺថានៅឆ្នាំ១៩៧៨ រហូតដល់ពេលដែលវៀតណាមចូលមកក្នុងប្រទេសកម្ពុជានោះ? លោកអាចផ្ដល់ជាឧទាហរណ៍ខ្លះបានទេ?

[១១:០៣:១៤]

**ឆ៖** ខ្ញុំធ្លាប់ជូន ហើយដែលខ្ញុំចាំ គឺមានភ្ញៀវបែលហ្ស៊ិកប្រហែលជាបីនាក់ ស្រីប្រុស តែឈ្មោះអីមិនចាំទេ។ ហើយជូនទៅហ្នឹង ម្តងមានតែឡានពីរ ឡានដឹកម្ហូបមួយ ហើយឡានដឹកភ្ញៀវមួយ។ រួចហើយមាននារីពីរនាក់វេចបាយវេចទឹកទៅជាមួយ ហើយមានយុវជនបើកឡានម្នាក់ ព្រមទាំងខ្ញុំ ជូនកាលពីរនាក់។ ដូច្នេះកាលជូនទៅហ្នឹង ជូនទៅវា ផ្លូវវាលំបាកណាស់ក្រោយសង្គ្រាម។ អ៊ីចឹងបានខ្ញុំជម្រាបជូនថា រយៈពេលមួយអាទិត្យទាំងទៅ-- ទៅម្តងៗ។ ដូច្នេះ ខ្ញុំចាំបានប៉ុណ្ណឹងបាទ។

**ស៖** ចាតើលោកចាំរយៈពេលដែលជនជាតិបែលហ្ស៊ិកទាំងបីនាក់ហ្នឹងមកទស្សនកិច្ចនៅប្រទេសកម្ពុជាដែរទេ? នៅក្នុងពេលណាដែរ?

**ឆ៖** អត់ចាំទេបាទ។

[១១:០៤:៤៧]

**ស៖** នៅពេលដែលលោកចុះទៅមូលដ្ឋាននោះ តើលោកធ្វើទស្សនកិច្ចអី មើលអីឲ្យជាក់លាក់នោះ? លោកទៅតំបន់ណាជាមួយគណៈប្រតិភូបែលហ្ស៊ិកហ្នឹង? តើសាខាប្រភេទណាដែលលោកបានចុះទៅទស្សនកិច្ចជាមួយពួកគណៈប្រតិភូទាំងបីរូបនោះ?

[១១:០៥:០០]

**ឆ៖** បុព្វសិទ្ធិធំបំផុតនៃការជូនភ្ញៀវបែលហ្ស៊ិកទៅហ្នឹង គឺទៅមើលអង្គរ។ អត់មានធ្វើអីផ្សេងពីនេះទៀតទេ។ មើលអង្គរវត្ត បាទ។

**ស៖** បាទ អរគុណ។ ហើយតាមផ្លូវទៅសៀមរាបនោះ តើលោកបានឈប់នៅកន្លែងណាខ្លះទេដើម្បីធ្វើទស្សនកិច្ចមើល ឧទាហរណ៍ដូចជា រោងចក្រ ឬក៏ សហករណ៍ ឬក៏អង្គភាពណាមួយដែលមានឋានៈប្រហាក់ប្រហែលគ្នានេះ។

**ឆ៖** ជូនទៅហ្នឹងគឺកំណត់ទិសដៅដល់កំពង់ធំ ចូលទៅហូបបាយនៅកណ្តាលបឹងមួយហ្នឹងដែលមានខ្ទមគេសង់យូរហើយ។ ហូបបាយចប់សព្វគ្រប់ហើយ ធ្វើដំណើរទៀត អត់មានទៅកន្លែងណាទេ។ ទៅត្រង់តែម្តង ធ្វើម៉េចឲ្យដល់សៀមរាបហ្នឹងកុំឲ្យយប់ទាន់ បាទ។

[១១:០៦:៥២]

**ស៖** ដើម្បីជាមូលហេតុប្រតិចារឹក ហើយនិងសូមរំឭកនូវការចងចាំរបស់សាក្សីមាន ឯកសារ *ហ្វីប៊ីស* លេខយោង E3/75 និង D262.44 ដែលចុះថ្ងៃ-- នៅខែសីហា ឆ្នាំ១៩៧៨ គឺជាឯកសារដែលធ្វើ-- ដែលយោងទៅនឹងការទស្សនកិច្ចនៃគណៈប្រតិភូនៃសមាគមបែលហ្ស៊ិក-កម្ពុជា នៅឆ្នាំ១៩៧៨។

បើយើងពិនិត្យមើលទំព័រមួយចំនួនដែលជាភាសាអង់គ្លេស 00168938 និង 00168940 ដល់ 42។ គឺថាមានការលើកឡើងដោយវ៉ាដ្យូនៅទីក្រុងភ្នំពេញថា "គណៈប្រតិភូនេះបានធ្វើទស្សនកិច្ចនៅភូមិភាគកណ្ដាល ហើយនិងខាងឧត្តរ ពិនិត្យលើកន្លែងផលិតថ្នាំ រោងចក្រស្ពដែកនៅកំពង់ចាម ហើយរោងចក្រកៅស៊ូនៅចម្ការអណ្ដូង ហើយនិងទស្សនាទំនប់១មករា និងអង្គរវត្ត ហើយនិងរណ្ដៅគ្រាប់បែក។ ហើយបន្ទាប់មកទៀតបើតាមវ៉ាដ្យូនៅទីក្រុងភ្នំពេញនេះ គឺថាមានការបន្តទស្សនកិច្ចនៅភូមិភាគនិរតី នៅតាកែវ ហើយនិងសហករណ៍អង្គតាសោម ហើយបន្ទាប់មកទៅទស្សនកិច្ចនៅកំពង់សោម មុននឹងទៅត្រឡប់មកភ្នំពេញ"។

[១១:០៨:៣១]

តើអ្វីដែលខ្ញុំនឹង-- ទើបនឹងបរិយាយនេះ វាជាដំណើរ ជាសមញ្ញសម្រាប់គណៈប្រតិភូបរទេសដែលមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ថាមានទៅពិនិត្យរោងចក្រ ឬក៏ទំនប់អីជាដើមនោះ? តើអ៊ីចឹងមែនទេ នេះជាដំណើរជាធម្មតាសម្រាប់សម័យនោះ?

**ឆះ** សូមបញ្ជាក់ ក្នុងភ្ញៀវមួយលើកៗ ភ្ញៀវតែមួយហ្នឹងក៏ដោយ ក៏គេចែក ឧបមាខ្ញុំឲ្យទៅសៀមរាប អង្គរវត្ត។ ខ្ញុំទៅដល់សៀមរាប អង្គរវត្តត្រឡប់មកវិញទៅប្រគល់ឲ្យខាងគណៈមន្ទីរគេទទួលខុសត្រូវ បានគេចែកឲ្យអ្នកណាទៅខាងណាទៀត មិនមែនខ្ញុំម្នាក់ហ្នឹងទៅគ្រប់កន្លែងទេ។ ដូច្នេះ ខ្ញុំចងចាំទៅគឺច្បាស់ គឺច្បាស់ជាងគេទៅសៀមរាប អង្គរវត្ត។ បាទ ក្រៅពីនោះ ខ្ញុំមិនចងចាំទេ ប៉ុន្តែខ្ញុំជឿថា ការចែក គឺគេចែកអ៊ីចឹង។ ហ្នឹងក្នុងភ្ញៀវតែមួយហ្នឹង នាំទៅសៀមរាបម្នាក់ទៅ ហើយត្រឡប់មកវិញមានអ្នកផ្សេងនាំទៅកន្លែងផ្សេង។

[១១:១០:១០]

**សះ** តើក្នុងចំណោមគណៈប្រតិភូផ្សេងទៀតនោះ តើលោកធ្លាប់បានជូនដំណើរគណៈប្រតិភូជប៉ុន មិត្តភាពជប៉ុននិងកម្ពុជា គឺថានៅឆ្នាំ១៩៧៨ ដដែលនេះ? តើលោកធ្លាប់ជូនគណៈប្រតិភូជប៉ុនទេ?

**ឆះ** ខ្ញុំចាំមិនអស់ទេបាទ ចាំមិនអស់ទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯលះ**

បាទលោកប្រធាន ខ្ញុំសូមអនុញ្ញាតរម្លឹកការចងចាំរបស់សាក្សី។ សូម-- ឯកសារនេះមាននៅក្នុងសំណុំរឿង គឺថាមានប្រតិចារឹកនៃការប្រកាសផ្សាយចំនួនបី គឺថារបស់វ៉ាដ្យូជប៉ុន តូក្យូ អ៊ំ! ក្យូដូដែលចុះផ្សាយនៅថ្ងៃទី១៣,១៤, ១៥ តុលា ហើយដែលមាននៅក្នុងឯកសារហ្វីប៊ីស E3/294 ហើយនិង

D262.46។ ឈ្មោះសាក្សីហ្នឹងមាននិយាយនៅក្នុងការផ្សាយវ៉ាដ្យូជប៉ុន ហើយបើសិនជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំគិតថាជាការធម្មតាទេ គឺយើងអាចអានសម្រង់នៃការប្រកាសផ្សាយតាមវិទ្យុនេះ ដើម្បីឲ្យសាក្សីបញ្ចេញប្រតិកម្មឆ្លើយតប។ ហើយអ៊ីចឹងខ្ញុំសូមការអនុញ្ញាតពីតុលាការ។

[១១:១២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ ខ្ញុំសូមធ្វើការបញ្ជាក់មួយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញៗ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបញ្ជាក់ជាមុនសិន មុននឹងផ្តល់វេទិកាជូនទៅមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទខ្ញុំចង់បញ្ជាក់ថា ឯកសារហ្វីប៊ីសនេះ ដែលមានលេខ ERN00170263 ដល់ 68។ ហើយសម្រង់នៃការប្រកាសផ្សាយវ៉ាដ្យូនេះមាននៅក្នុងហ្វីប៊ីស ហើយក៏នៅក្នុងឯកសារមួយទៀតក៏មានឯកសារហ្នឹងដែរ ដែលក្នុងឯកសារហ្នឹងហៅថា ប៊ី.ប៊ី.ស៊ី.អេស.ដាប់ប៊ែលយូ.ប៊ី ដែលចុះនៅថ្ងៃ១៥ តុលា ឆ្នាំ១៩៧៨ ដែលមានលេខកូដ D108/28.318។ ខ្ញុំអានម្តងទៀត D108/28.318 ហើយឯកសារនេះមានការបកប្រែជាភាសាបារាំង ហើយលេខERN ជាភាសាបារាំង គឺS00793498 ដល់ 99។ ហើយនិងមានវគ្គមួយទៀត គឺ S00793503 រហូតដល់ 07។ ជាភាសាអង់គ្លេស ប៊ី.ប៊ី.ស៊ី គឺ S00013184 រហូតដល់ 85 ហើយផ្នែកមួយទៀតគឺ S00013190 រហូតដល់ 92។ បាទសម្រង់ទីមួយដែលខ្ញុំចង់អាននោះ ប្រសិនបើពុំមានការជំទាស់ទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះមានការជំទាស់ពីមេធាវីការពារក្តី នួន ជា។ ស្តាប់ការជំទាស់សិន ព្រោះយើងបានសម្រេចហើយ មុននឹងសម្រេចគាត់អត់ជំទាស់ទេ។ ឥឡូវសម្រេចរួច ទើបគាត់ជំទាស់ជាក្រោយ។ យើងក៏មិនយល់អំពីការប្រព្រឹត្តរបៀបនេះដែរ។

សូមអញ្ជើញលោកមេធាវី!

[១១:១៥:០៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានការជំទាស់ទេ ប៉ុន្តែសូមស្នើថា ហើយសូមឲ្យយើងខ្ញុំបាន ទទួលនូវសេចក្ដីដកស្រង់ ពីព្រោះថា គាត់នឹងអាននូវសេចក្ដីសម្រង់នោះ។ ក៏ប៉ុន្តែគឺយើងមិនទាន់មាន ឯកសារ ប៉ុន្តែដើម្បីឲ្យយើងតាមដាននូវការដកស្រង់នោះបាន លុះត្រាណាតែយើងមានឯកសារនោះ ផងដែរ បាទ។

[១១:១៥:៤៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទលោកប្រធាន។ បើសិនជាលោកប្រធានអនុញ្ញាត យើងនឹងធ្វើយ៉ាងដូច្នេះ ពីព្រោះថា ពុំមាន ជាភាសាខ្មែរ អ៊ីចឹងយើងមិនអាច-- យើងមិនចង់បង្ហាញឯកសារនេះទៅសាក្សីទេ បើសិនជាមានសារៈ សំខាន់សម្រាប់ភាគីនោះ យើងគិតថា យើងនឹងត្រូវបង្ហាញផ្នែកហ្នឹងទៅភាគី បើសិនគាត់យល់ថា មាន សារៈសំខាន់សម្រាប់គាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ឲ្យជំនួយការរបស់លោកបង្ហាញឯកសារជាភាសាអង់គ្លេស នៅលើអេក្រង់ កុំព្យូទ័រ ត្រង់ចំណុចដែលលោកដកស្រង់ មានការប៉ុនប៉ងរំឭកការចងចាំរបស់សាក្សីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

គឺឯកសារ D108/28.318 ជាភាសាអង់គ្លេសគឺ ERN 00013184 ដល់ 85 ជាភាសាបារាំង S00-- បាទ អង់គ្លេស ជាភាសាអង់គ្លេសមាន S អង់គ្លេសក៏មាន S ដែរគឺថា S00793498 ដល់ 99។

[១១:១៧:១៥]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នេះគឺ-- វគ្គនេះចាប់ផ្ដើមដោយពាក្យថា "សួរ ហុង ឈ្មោះ សួរ ហុង។ ខ្ញុំគិតថា យើង រកឃើញវគ្គនេះហើយ។ ខ្ញុំសូមដកស្រង់ ជាជនជាតិជប៉ុនដែលគាត់ធ្វើរបាយការណ៍លើទស្សនកិច្ចរបស់ គាត់នៅកម្ពុជាប្រជាធិបតេយ្យ "សួរ ហុង ដែលជាអ្នកទទួលយើង និងតំណាងក្រសួងទទួលបន្ទុកលើក ស្ទួយទំនាក់ទំនងមិត្តភាពជាមួយបរទេស មានអាយុ៣៤ឆ្នាំ"។ ហើយក្រោយមកទៀត ឆ្ងាយបន្តិចនៅ ក្នុងអត្ថបទដដែលហ្នឹងមានសរសេរ "មេដឹកនាំជាច្រើនដែលយើងបានជជែកជាមួយនោះ មាន

មោទនភាព និងជំនឿមិនងាករេ ក្នុងបទពិសោធន៍របស់ពួកគេនៅក្នុងតំបន់រំដោះ នាសម័យសង្គ្រាម។ នី កន ជាអ្នកមគ្គុទេសក៍ យើងដែលជាអ្នក-- ជាមន្ត្រីជាន់ខ្ពស់នៅក្រសួងការបរទេស បានបញ្ជាក់ថា នៅក្នុងបណ្ដាឆ្នាំលំបាកៗដែលពួកហួបក្លួច និងសាច់ខ្លានៅតំបន់រំដោះ បានផ្ដល់កម្លាំងឲ្យពួកគេ និង-- ក្នុងការអនុវត្តគោលនយោបាយជនបទភូបនីយកម្ម ដល់ឫសគល់ ហើយបានជួយពួកគេឲ្យរក្សានយោបាយរដ្ឋាភិបាលម៉ឺងម៉ាត់។ យ៉ាងច្បាស់ណាស់យុវជនបដិវត្តន៍ទាំងនេះ ទុកចិត្តតែទៅលើអ្នកដែលបានប្រយុទ្ធជាមួយពួកគេនៅក្នុងអំឡុងសង្គ្រាមរំដោះជាតិប៉ុណ្ណោះ”។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

លោកសាក្សី អត្ថបទដែលខ្ញុំអាននេះ តើវាឆ្លុះបញ្ចាំងពិតប្រាកដទៅនឹងអ្វីដែលលោកបាននិយាយប្រាប់គណៈប្រតិភូជប៉ុនដែរឬទេ?

[១១:១៩:១០]

**លោក នី កន៖**

**ឆ៖** សូមបញ្ជាក់ជូនបាទ។ ខ្លឹមសារដែលនិយាយជាមួយភ្ញៀវ ខ្ញុំចាំមិនអស់ទេ តែខ្លឹមសារនីមួយៗតែងមានការណែនាំពីខាងលើ ហើយក្នុងការណែនាំនេះ ក៏បញ្ជាក់សំខាន់ពីមោទនភាពដែលបានច្បាំងទៅដណ្ដើមបានជ័យជម្នះ តែលម្អិតថាយ៉ាងម៉េចៗទៀត ខ្ញុំចាំមិនអស់ទេ។ បាទ ដូច្នេះ ខ្លឹមសារនេះការណែនាំនេះ ខ្ញុំអាចពាំនាំយកទៅនិយាយជាមួយភ្ញៀវ តែមិនចាំទេ មិនចាំថាលម្អិតនិយាយយ៉ាងម៉េចៗច្បាស់ គ្រាន់តែថា ជាមោទនភាពដែលភ្ញៀវមកក៏ឧទ្ទេសនាមបន្ត។ នេះសូមជម្រាបជូនបាទ។

[១១:២០:២៧]

**ស៖** តើមានមាគ៌ានយោបាយធ្វើជនបទភូបនីយកម្ម ដល់គល់របស់បក្សកុម្មុយនីស្តកម្ពុជា តើលោកអាចនិយាយអំពីនយោបាយនេះបានដែរឬទេ នយោបាយជនបទភូបនីយកម្មដល់ឫសគល់នេះ?

**ឆ៖** ជម្រាបជូន ខ្ញុំនិយាយមិនបានទេ ព្រោះអានេះវាជាការបកស្រាយនៃទ្រឹស្ដីរបស់បក្ស។ ដូច្នេះ ខ្ញុំមិនអាចនិយាយបានទេ។

**ស៖** ខ្ញុំសូមអានសម្រង់ពីរ-- មួយទៀតនៃឯកសារដដែលនេះ គឺថានៅទំព័រជាភាសាអង់គ្លេស គឺ S00013190 ហើយនិងជាភាសាបារាំងគឺ 00793503 ដល់ 04។ ខ្ញុំគិត សូមអនុញ្ញាតបញ្ចាំងជាភាសាអង់គ្លេស។ បាទ មានការលើកឡើងយ៉ាងដូច្នេះនៅក្នុងអត្ថបទដែលសរសេរដោយជនជាតិជប៉ុននៃសមាគមមិត្តភាពជប៉ុន-កម្ពុជា នេះ ដោយមាន-- ដែលដឹកនាំដោយលោក គូហ្សូ កាហ្សាគី “លោក នី កន ដែលជូនយើងនៅក្នុងដំណើរទស្សនកិច្ចរបស់យើង បានពន្យល់ប្រាប់យើងថា ប្រជាជនភាគច្រើន

ហើយយើងនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺថាមនុស្សភាគច្រើនបានចាកចេញដោយគ្មានការរឹងទទឹង ហើយបានត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញ។ គាត់ក៏បាននិយាយប្រាប់យើងផងដែរអំពីការបែងចែកឡើងវិញក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយមក ហើយដោយទំនងសំដៅទៅដល់ការលុបបំបាត់វណ្ណៈនាយទុន ដែលមិនសូវសហការជាមួយអង្គការ”។

[១១:២២:៤៦]

ហើយនៅក្នុងទំព័រដដែលនេះ នៅឆ្វាយបន្តិច “ទី កន បានប្រាប់ថា បញ្ហានានាដែលវៀតណាមបានជួបប្រទះជាមួយនឹងប្រជាជនចិន មិនប៉ះពាល់ដែលកម្ពុជាឡើយ។ ពីព្រោះប្រជាជនកម្ពុជាទាំងអស់រួមទាំងជនជាតិចិនផងដែរ គឺថាត្រូវបានគោរពស្មើៗគ្នា។ គាត់ក៏បាននិយាយផងដែរថា ប្រជា-- មនុស្សមួយចំនួនដែលមានបុព្វសិទ្ធិ ដែលនៅមុនពេលរំដោះនោះ ពិបាកនឹងសម្របសម្រួលខ្លួន។ ក៏ប៉ុន្តែគាត់គូសបញ្ជាក់ថា ក្នុងកម្ពុជាប្រជាធិបតេយ្យ ក្នុងសម័យបដិវត្តន៍នេះ គឺថាបុព្វសិទ្ធិកាលពីសម័យមុនលែងមានទៀតហើយ”។

សំណួរទីមួយលោកសាក្សី គឺមានការនិយាយថា លោកនិយាយអំពីការចែកចាយឡើងវិញដល់ប្រជាជនដែលជម្លៀសទៅក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយមក ក្រោយពីជម្លៀសគាត់ចេញពីភ្នំពេញ តើពាក្យថា “ការចែកចាយឡើងវិញ” នេះ មានន័យយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបជូនបាទ ពាក្យដែលខ្ញុំនិយាយ ជួនណាវាដូចការសរសេរ ជួនណាវាមិនដូចទេ។ តែខ្ញុំមិនចាំ។ “ចែកចាយ” ខ្ញុំបានជម្រាបពីម្សិលមិញថា អ្នកចាស់មានស្បៀងអាហារ ហើយនៅក្នុងមូលដ្ឋានស្រាប់ ចែកចាយ បាយទឹកអង្ករចំណីនេះឲ្យអ្នកដែលមកថ្មី ដែលគ្មានអី។ បាទ “ចែកចាយ” មានន័យអីចឹងបាទ។

[១១:២៥:១០]

**សៈ** លោកផ្ទាល់តែម្តង តើលោកស្ថិតនៅក្នុងតំបន់១៥ តើលោកបានឃើញមនុស្សដែលគេជម្លៀសមកដែរឬទេ? ដែលជម្លៀសមកពីទីក្រុងផ្សេងៗទៀតនោះ មកភូមិភាគៗ ពិសេសកាលសម័យនុំងគឺនៅក្នុងតំបន់១៥ របស់លោកតែម្តងនោះ?

**ឆ៖** បាទ ខ្ញុំឃើញតែអ្នកភ្នំពេញ អ្នកភ្នំពេញដែលចេញមក ចេញមកតាមផ្លូវលេខ៥ ហ្នឹងហើយចុះមកតំបន់១៥ ហើយនិងចេញតាមផ្លូវលេខ៤ ឬចេញតាមវាលស្រែហ្នឹងមក។ បាទ បានឃើញអីចឹង។

**ស៖** ដូច្នេះនៅតំបន់១៥ហ្នឹង ពុំមានអ្នកជម្លៀសណាដែលមកតាំងនៅទេ នៅក្នុងភូមិ នៅក្នុងតំបន់១៥ ដល់ក្រោយមកក្លាយជាតំបន់៣២ទេ អ៊ីចឹងអត់មានប្រជាជនថ្មីមកតាំងលំនៅដ្ឋាននៅទីហ្នឹងទេឬ?

**ឆ៖** បាទ ខ្ញុំឃើញតែអ្នកមកពីភ្នំពេញដែលមកតាំង មកហើយដែលតាមមូលដ្ឋានគេទទួលបាទ ឯមកពីណាទៀត ខ្ញុំមិនឃើញទេ។

[១១:២៧:០២]

**ស៖** ហើយលោកនិយាយថា អ្នកដែលមានបុព្វសិទ្ធិ ដែលពីមុននៅភ្នំពេញនោះមានការលំបាកក្នុងការសម្របសម្រួលខ្លួន។ ទោះបីយ៉ាងណា គឺថាមានសរសេរនៅក្នុងអត្ថបទជប៉ុននេះ។ តើហេតុអីក៏លោកនិយាយថា ពួកអ្នកមកថ្មីនេះ ពិបាកនឹងសម្របសម្រួលខ្លួនទៅនឹងជីវិតជនបទ?

**ឆ៖** បញ្ហានេះងាយទេបាទ។ ពីព្រោះអ្នកក្រុង ហើយអ្នកស្រុកស្រែ វាមិនដូចគ្នាទេ។ ទីមួយ អ្នកក្រុងធ្លាប់តែរស់នៅតាមជីវភាពរបស់អ្នកក្រុង។ ឯអ្នកស្រែរស់នៅតាមជីវភាពអ្នកស្រែ អ្នកជនបទ។ ដូច្នេះពិបាកសម្របហើយ។ តែទីពីរ ពីម្សិលមិញ ខ្ញុំបញ្ជាក់ជូនម្តងហើយ។ ធម្មតានៅក្រុង ទោះបីផ្ទះតូច ផ្ទះធំក៏ជាផ្ទះរបស់គេ។ ដូច្នេះ ដល់មកកន្លែងថ្មី វាថ្មីថែស។ អ៊ីចឹង វាមានស្រួលអី ពិបាកសម្របហើយបាទ។ សូមឆ្លើយតែប៉ុណ្ណឹង។

[១១:២៨:៣២]

**ស៖** លោកបាននិយាយអម្បាញ់មិញថា លោកបានអមដំណើរគណៈប្រតិភូជាច្រើននៅក្នុងតំបន់ផ្សេងៗនៅក្នុងប្រទេស ជាពិសេសលោកបានលើកឡើងពីខេត្តសៀមរាប ហើយនិងនៅតាមមូលដ្ឋានផ្សេងៗ។ តើលោកបានសង្កេតឃើញអ្វីមួយនៅក្នុងរយៈពេលទស្សនកិច្ចនៅក្នុងឆ្នាំ១៩៧៨ នេះដែរឬទេ ជាពិសេសទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ប្រជាជន និងអ្នកធ្វើការនៅតាមមូលដ្ឋាននោះ តើលោកបានឃើញអ្វីខ្លះ ហើយអ្វីដែលទាក់ទាញចំណាប់អារម្មណ៍របស់លោក ជាពិសេសទាក់ទងនឹងស្ថានភាពសុខភាពរបស់ប្រជាជនទាំងអស់នោះ?

[១១:២៩:១៤]

**ឆ៖** សូមបញ្ជាក់ជូនច្បាស់ម្តងទៀត ក្នុងការជូនភ្ញៀវ ភាគច្រើន គឺខ្ញុំជូនទៅសៀមរាបមើលអង្គរវត្ត។ អមដំណើរក្នុងការជូនភ្ញៀវទៅអង្គរវត្ត យើងត្រូវឆ្លងផ្លូវលេខ៦ ទៅអង្គរវត្ត។ តាមផ្លូវ នៅអមសងខាងផ្លូវទៅអង្គរវត្តហ្នឹង ប្រជាជនភាគតិចទេ មិនសូវមានផ្ទះសម្បែងច្រើនទេ។ ដូច្នេះ ការស្គាល់

សភាពការណ៍ប្រជាជនតាមហ្នឹង មិនបានល្អិតទេ។

តែជារួម អ្វីដែលខ្ញុំដឹង អ្វីដែលខ្ញុំឃើញ ខ្ញុំយល់ គឺជីវភាពក្រោយសង្គ្រាមនេះមិនគ្រប់គ្រាន់ទេ។ ហើយលំនៅដ្ឋានដែលទទួលមនុស្សមកផ្ទុចនៅអ៊ីចឹង ក៏មិនគ្រប់គ្រាន់ដែរ។ សរុបទៅ បញ្ជាក់ជូនថា ជីវភាពមិនទាន់គ្រប់គ្រាន់ទេបាទ។

**ស៖** តើលោកសង្កេតឃើញថាប្រជាជនហូបចុកមិនគ្រប់គ្រាន់ហ្នឹងតាមរបៀបណា? ខ្ញុំនិយាយអំពីទស្សនកិច្ចនៅឆ្នាំ៧៨។ តើមានសញ្ញាអីខ្លះដែលបង្ហាញឲ្យឃើញថា ប្រជាជននោះហូបចុកមិនគ្រប់គ្រាន់នោះ?

**ឆ៖** សញ្ញាដែលខ្ញុំសន្និដ្ឋានគឺផលិតផលបានតិច រួចមនុស្សដែលត្រូវការហូបចុកហ្នឹងវាច្រើន។ នេះដែលខ្ញុំសន្និដ្ឋាន។

[១១:៣១:៥៣]

**ស៖** តើពួកគាត់ហ្នឹងស្គមស្គាំងដែរឬទេ នៅពេលដែលលោកឃើញនោះ?

**ឆ៖** ខ្ញុំឃើញជាទូទៅដូចប្រហាក់ប្រហែលគ្នា តែអ្នកឈឺតម្កាត់អី គេនៅមន្ទីរពេទ្យ ខ្ញុំមិនឃើញទេ។ តែអ្នកនៅតាមភូមិជាប់ៗផ្លូវហ្នឹង ឃើញប្រហាក់ប្រហែលគ្នា។ បាទ ខ្ញុំឃើញការពិតគឺអ៊ីចឹង។

**ស៖** តើលោកតែងតែរាយការណ៍ជូនថ្នាក់លើរបស់លោកអំពី-- អំពីបេសកកម្មរបស់លោកក្នុងការជូនដំណើរគណៈប្រតិភូបរទេសនេះដែរឬទេ?

**ឆ៖** ធម្មតាតែភ្ញៀវមកដល់កន្លែងនេះហើយ គឺមានការរាយការណ៍តាមមាត់។ បាទ រាយការណ៍ថាសុខសប្បាយទេ ភ្ញៀវរីករាយដោយបានអង្គរវត្ត។ ហើយការហូបចុកមិនមានអីទេ។ តែប៉ុណ្ណឹងបាទ។

**ស៖** តើលោកធ្លាប់រាយការណ៍ជូនថ្នាក់លើរបស់លោកដោយជាលាយលក្ខណ៍អក្សរឬក៏នៅក្នុងពេលកិច្ចប្រជុំថាប្រជាជននៅមូលដ្ឋាននោះហូបចុកមិនគ្រប់គ្រាន់នោះ?

**ឆ៖** សូមបញ្ជាក់សំណួរម្តងទៀតបាទ។

[១១:៣៤:១០]

**ស៖** តើលោកធ្លាប់រាយការណ៍ជូនមេរបស់លោកថាប្រជាជននៅមូលដ្ឋានមានការហូបចុកមិនគ្រប់គ្រាន់ដែរឬទេ នៅក្នុងពេលដែលលោកបានសង្កេតឃើញបែបនេះនៅមូលដ្ឋាននោះ? ហើយខ្ញុំគិតថាប្រហែលជារបាយការណ៍នោះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬក៏ធ្វើជាដោយផ្ទាល់មាត់នៅក្នុងពេល

ប្រជុំ។

**ឆ៖** ក្នុងការប្រជុំ គឺមានលើកបញ្ហារបៀបវារៈផ្សេងៗ ហ្នឹងខ្ញុំក៏ធ្លាប់លើកដែរ ថាសង្កេតទៅឃើញហូបមិនសូវគ្រប់គ្រាន់។ តែមិនមែនញឹកញាប់អីទេ ម្ដងម្កាលនៅតាមឱកាសដែលមានពេលអាចនិយាយបាន បាទ។

[១១:៣៥:២៤]

**ស៖** ត្រឡប់មកពី-- និយាយអំពីរបាយការណ៍ ដែលលោកធ្វើនៅក្នុងពេលទស្សនកិច្ច។ តើលោកធ្វើរបាយការណ៍នៅពេលដែលត្រឡប់មកភ្នំពេញ នៅក្រសួងការបរទេសវិញ ឬក៏លោកត្រូវធ្វើរបាយការណ៍នៅក្នុងពេលដែលលោកនៅមូលដ្ឋាននោះតែម្ដង? គឺឧទាហរណ៍ដូចជា តាមទូរលេខជាដើម។

**ឆ៖** គឺពេលមកដល់ក្រសួងវិញបាទ គ្មានទូរលេខគ្មានអីទេ។

**ស៖** លោកសាក្សី តើលោកមានបានជូនដំណើរអ្នកសារព័ត៌មានយូហ្គោស្លាវី ក្នុងពេលពួកគាត់ទស្សនកិច្ចកម្ពុជានៅដើមឆ្នាំ៧៨ ដែរឬទេ? តើលោកមានចាំដែរឬទេ?

[១១:៣៦:២៦]

**ឆ៖** ខ្ញុំចាំមិនអស់ទេ តែកាលនោះវាមានគណៈ មានៗភ្ញៀវយូហ្គោស្លាវីដែរ ហើយខ្ញុំចាំមិនអស់តែអាចពេលនុ៎ងមានជូនដែរ តែខ្ញុំចាំមិនអស់ទេ ចាំមិនច្បាស់បាទ។

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេះ**

ខ្ញុំចង់បង្ហាញឯក-- លោកប្រធានជូនឯកសារមួយជូនទៅសាក្សី ហើយនិងសូមការអនុញ្ញាតបង្ហាញជូននៅលើអេក្រង់។ គឺឯកសារលេខ E3/1112 ឬក៏លេខ D252.12។ ឯកសារនេះមាន ERN ជាភាសាអង់គ្លេស និងជាភាសាខ្មែរ ហើយមានការបក-- យើងទទួលការបកប្រែជាភាសាបារាំងហើយកាលពីសប្ដាហ៍មុននេះ។ ជាភាសាបារាំង គឺ 00434861 រហូតទៅដល់ 63 ជាឯកសារបីទំព័រ។ ជាភាសាខ្មែរ 00020960 ទៅដល់ 62។ ERN ជាភាសាបារាំង 00810029 រហូតទៅដល់ 32។

លោកប្រធានតើខ្ញុំអាចទទួលបានការអនុញ្ញាតក្នុងការបង្ហាញឯកសារនេះទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជ

អាជ្ញាជូនទៅសាក្សីពិនិត្យ។ ហើយនិងអនុញ្ញាតឲ្យជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងលេះ**

ក្នុងពេលទន្ទឹងរង់ចាំនេះ ខ្ញុំចង់បញ្ជាក់ជូនថា នេះគឺជាទូរលេខពីរ គឺ៣៦៦ និង៣៦៧ ផ្ញើជូន-- ឯកសារនេះផ្ញើជូនបងវ៉ាន់ ជាទីស្នេហា។ គឺឈ្មោះ កន ជាអ្នកផ្ញើ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៨។ ហើយចំពោះទូរលេខ៣០៧ នេះគឺថាមិនដឹងផ្ញើនៅថ្ងៃណាទេ ក៏ប៉ុន្តែទទួលបាននៅថ្ងៃទី១៥ ខែមីនា ឆ្នាំ៧៨។

[១១:៣៩:៤៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងលេះ**

**ស៖** លោកសាក្សី នី កន លោកបាននិយាយថាឈ្មោះរបស់លោកនោះ គឺឈ្មោះហៅថា កន ហើយលោកធ្លាប់-- លោកថាជាប្រធានផ្នែកពិធីការ។ ខ្ញុំចង់ដឹងថា តើលោកមែនទេ ជាអ្នកផ្ញើទូរលេខទាំងពីរនេះជូន បងវ៉ាន់ នៅខែមីនា ឆ្នាំ១៩៧៨ នេះ? ខ្ញុំសូមទុកពេលឲ្យលោកអានទូរលេខទាំងពីរនេះ ហើយបន្ទាប់មកសូមលោកផ្តល់ចម្លើយជូនខ្ញុំ។

[១១:៤០:១៧]

*(សាក្សីអានឯកសារ)*

[១១:៤២:២២]

**ស៖** លោកសាក្សី តើលោកបានមើលឯកសារនេះរួចហើយឬនៅ? ហើយលោកអាចប្រាប់ខ្ញុំបានទេ ថាតើជាលោកមែនទេ ដែលជាអ្នកផ្ញើឯកសារនេះ ទូរលេខនេះជូនទៅ បងវ៉ាន់?

**ឆ៖** ក្រោយពីបាន-- ខ្ញុំបានពិនិត្យត្រួសៗ ខ្លឹមសារនេះមិនមែនខ្លឹមសារខ្ញុំទេ។ ហើយមិនមែនខ្ញុំទេ អ្នកសរសេរ។ ហើយចាំថាពេលនោះ ខ្ញុំដូចមិនមានតួនាទីអីកាន់ទូរលេខផង។ សរុបទៅ គឺខ្ញុំសូមបដិសេធមិនមែនទេ។

**ស៖** តើលោកស្គាល់ថា មានអ្នកណាផ្សេងទៀតឈ្មោះ កន នៅផ្នែកពិធីការនៅក្រសួងការបរទេសដែរឬទេ? ហើយឈ្មោះ កន នេះដែលធ្វើរបាយការណ៍ពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ ដែលអ្នកកាសែតយូហ្គោស្លាវីបានធ្វើជាមួយនឹងមនុស្សមួយចំនួននៅតាមការដ្ឋានការងារនៅពេលពួកគាត់ចុះធ្វើទស្សនកិច្ចនោះ អ៊ីចឹងតើមានឈ្មោះ កន អីផ្សេងទៀតទេ?

**ឆ៖** ស្គាល់មិនអស់ដែរ ព្រោះឈ្មោះខ្មែរវាច្រើនដែរ ប៉ុន្តែខ្ញុំគ្រាន់តែមើលខ្លឹមសារនេះ គឺមិនមែនខ្លឹមសារ វាមិនមែនឃ្លាឃ្លោងខ្ញុំអ្នកសរសេរ បាទ។ ហើយដូចដឹងរឿងជ្រៅជ្រះអីណាដល់ថៃ ដល់អីវែងឆ្ងាយទៀត បាទ។

**ស៖** តើលោកអាចប្រាប់បានទេ ថាអ្នកនៅក្នុងក្រសួងការបរទេសដែលឈ្មោះថា បងវ៉ាន់ នុ៎ង?

[១១:៤៤:៥៦]

**ឆ៖** បងវ៉ាន់ៗ ហ្នឹង គឺគេសំដៅក្នុងពេលនុ៎ង គឺទៅដល់តា អៀង សារី ហ្នឹងហើយបាទ។ តែមានឈ្មោះច្រើន មិនមែនឈ្មោះតែមួយទេ ប៉ុនពេលដែលខ្ញុំឮៗ អ៊ីចឹងបាទ។

**ស៖** ប្រសិនបើមិនមែនជាលោក ដែលសរសេរឯកសារនេះ។ តើលោកអាចប្រាប់បានទេ ថាហេតុអ្វីបានជាមានសារៈសំខាន់ សម្រាប់សមាជិកក្រសួងការបរទេសក្នុងការសរសេរទូរលេខ ក្នុងការរាយការណ៍អំពីកិច្ចសន្ទនារបស់អ្នកកាសែតយូហ្គោស្លាវីនៅតាមមូលដ្ឋាន ហើយនិងត្រូវរាយការណ៍អំពីសំណួរដែលអ្នកកាសែតទាំងអស់នេះសួរនៅតាមមូលដ្ឋាននោះ? តើវាជារឿងធម្មតាទេឬ ក្នុងការរាយការណ៍ អំពីហេតុការណ៍ ហើយនិងអំពីកាយវិការ អំពីទង្វើររបស់អ្នកកាសែតបរទេស ដែលមកទស្សនកិច្ចនៅកម្ពុជា ហើយនិងសួរសំណួរទៅកាន់មនុស្សមួយចំនួន ដែលពួកគេបានជួបនោះ តើវាជាទម្លាប់ធម្មតានៅសម័យនោះឬ?

[១១:៤៦:៣៤]

**ឆ៖** ខ្ញុំបានបញ្ជាក់ជូនហើយ គឺក្នុងភ្ញៀវមួយគណៈប្រតិភូ មិនមែនជូនតែខ្ញុំទេ គឺខ្ញុំជូនទៅអង្គរវត្តត្រឡប់ពីអង្គរវត្តមកមានអ្នកផ្សេងទៀត ក្រុមផ្សេងទៀតជូនទៅទៀត។ អ៊ីចឹងវា ការរាយការណ៍អីៗនេះវាទៅតាមប្រភេទផ្នែកមួយៗ បើខ្ញុំៗរាយការណ៍ខាងខ្ញុំ ប៉ុនដល់គេនាំទៅខាងផ្សេងទៀត ទៅតាមខេត្តតាមមូលដ្ឋានផ្សេងទៀត គេរាយការណ៍តាមផ្នែករបស់គេ។ ដូច្នេះ គេរាយការណ៍អ៊ីចឹង ខ្លឹមសាររបៀបរបប។ តែរបៀបរបបនេះក៏មិនមែនជាមូលដ្ឋាន ដែលជាក្រឹត្យ ជាក្រមអីច្បាស់លាស់ទេទៅតាមតែការយល់ដឹង សមត្ថភាពយល់ដឹងរបស់ម្នាក់ៗ យល់ត្រូវយល់ខុសក៏សរសេរតាមហ្នឹងទៅបាទ ឬក៏រាយ-ការណ៍តាមមាត់តាមហ្នឹងទៅបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណ។ ខ្ញុំមានឯកសារពីរផ្សេងទៀត ដើម្បីដាក់ជូនសាក្សីមុនពេលឈប់សម្រាកថ្ងៃត្រង់។ លោកប្រធាន ឯកសារទីមួយគឺ ឯកសារ E3/1113 ឬក៏ឯកសារ D252.13 ចុះថ្ងៃទី១៥ ខែមីនា

ឆ្នាំ១៩៧៨។ នេះគឺទូរលេខ61 ដែល កន ផ្ញើជូនបងជាទីស្នេហា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៨ ពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់អ្នកសារព័ត៌មានយូហ្គោស្លាវីនៅភូមិភាគពាយ័ព្យ។ ខ្ញុំសូមការបង្ហាញពីលោកប្រធានបង្ហាញឯកសារនេះ ជូនសាក្សី និងដាក់បញ្ចាំងនៅលើអេក្រង់។

[១១:៤៨:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមសំណើ។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាស ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលឯកសារនេះទៅ ហើយសូមឲ្យលោកពិនិត្យនៅកន្លែងមានឈ្មោះនៅចុងឯកសារ ហើយនិងប្រធានបទផ្សេងៗ ដែលត្រូវបាននិយាយនៅក្នុងឯកសារនេះ។ ហើយដើម្បីជួយលោកនោះ ខ្ញុំសូមនិយាយថា ឯកសារនេះបានរាយការណ៍អំពីសំណួរផ្សេងៗ ដែលអ្នកកាសែតយូហ្គោស្លាវី បានទស្សនកិច្ចនៅបារាយណ៍ ហើយដែលនៅទីនោះគឺមានមនុស្សពីរម៉ឺននាក់ធ្វើការនៅត្រពាំងថ្ម ដូចជាមាននៅស៊ីសុផុន នៅបាត់ដំបង។ ហើយសំណួរដែលសួរនោះគឺទាក់ទងទៅនឹងម្ហូបអាហារ ការដឹកជញ្ជូនអ្នកធ្វើការ អាពាហ៍ពិពាហ៍ និងការទៅលេងគ្រួសារជាដើម។ នេះជាការសង្ខេបនូវខ្លឹមសារនៃឯកសារនេះ។ តើលោកអាចប្រាប់បានទេថា តើលោកមែនទេជាអ្នកផ្ញើទូរលេខនេះជូនបងជាទីគោរពស្នេហានោះ?

[១១:៥០:៤៤]

**ឆ៖** សូមជម្រាបបាទ ពេលវេលាវាយូរពេក ហើយដូចលោកចាំហើយ វាសាមសិបប្លាយឆ្នាំហើយ ដូច្នេះកិច្ចការមួយចំនួនដែលខ្ញុំបានចូលរួមក៏ចាំមិនអស់ដែរ។ តែគ្រាន់តែចង់បញ្ជាក់ថា ការដែលមានការទាក់ទងរឿងថា រាយការណ៍ពីភ្ញៀវ អាហ្នឹងមានរាយការណ៍មែន។ ខ្ញុំមានរាយការណ៍មែន តែខ្លឹមសារហ្នឹងវាចាំមិនអស់ទេ។ ដែលខ្ញុំសំដៅសំខាន់ គឺសន្តិសុខ សុខ-- គឺបានសេចក្តីថាធ្វើដំណើរហ្នឹងសុខសប្បាយទេ។ ហើយមានសួរឆ្ងល់អីហ្នឹង គ្រាន់តែឆ្លើយទៅតាមការយល់ឃើញរបស់ខ្ញុំ។ ហើយនៅពេលជួប ត្រលប់មកវិញត្រូវរាយការណ៍ថាបានភ្ញៀវសួរម៉េច? អីម៉េច? ហើយខ្ញុំបានជួយដោះស្រាយយ៉ាងៗម៉េចតែប៉ុណ្ណឹងបាទ។ ហើយខ្ញុំចាំ គឺខ្ញុំភាគច្រើន មានតែមាត់ទេ។ តែដល់នេះឃើញមានទូរលេខអី ខ្ញុំមិនចាំដែរបាទ។

[១១:៥២:២៩]

**ស៖** ប្រសិនបើលោកមិនចងចាំទេ ខ្ញុំចង់ដឹងថា តើលោក ឬក៏មិនមែនលោក គឺសូមឲ្យលោកពិនិត្យមើលនូវកំណត់សម្គាល់ចុង-- នៅចុងទំព័រមុនពេលចុះហត្ថលេខា និងមុនពេលសរសេរឈ្មោះ កន ក្នុងនោះមានសរសេរកំណត់សម្គាល់មួយ ដែលមាននិយាយថា "ថ្ងៃមុន ខ្ញុំសរសេរសេចក្តីរាយការណ៍ជូនបង ដោយសរសេរនឹងខ្មៅដៃ គឺមកពីសមមិត្ត ឈាន យកមកឲ្យមូលដ្ឋានជួយវាយទូរលេខ តែបងប្អូនយកទៅដល់៨៧០តែម្តង។ សូមបងជ្រាប"។ តើជាលោកឬក៏មិនមែនជាលោក ដែលជាអ្នកសរសេរនេះ បើមិនមែនជាលោកក៏ដោយ តើលោកអាចបញ្ជាក់បានទេថា តើមន្ទីរ៨៧០ នេះជាមន្ទីរអ្វី? ហើយហេតុអីបានជាទូរលេខនេះឆ្លងតាមមន្ទីរ៨៧០ នេះ?

**ឆ៖** សូមបញ្ជាក់ជូន មន្ទីរ៨៧០ ហ្នឹង គេសំដៅមន្ទីរខាងលើហើយ ប៉ុន្តែខ្ញុំដឹងលេខច្បាស់គេហៅ "៨៧"។ បាទ ដូច្នេះជាមន្ទីរខាងលើ។

[១១:៥៤:១២]

**ស៖** ជាទូទៅ តើទូរលេខដែលផ្ញើជូនទៅមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនោះ ត្រូវតែឆ្លងតាមមន្ទីរ៨៧០ សិន មុននឹងបញ្ជូនទៅឲ្យអ្នកដែលត្រូវទទួលជាក់លាក់នោះ? តើអ៊ីចឹងមែនទេ? លោកដឹងអំពីចំណុចនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី ម៉ែខល កាណាវ៉ាស!

[១១:៥៤:៤៥]

**លោក ម៉ែខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់កាលពីអម្បាញ់មិញមុននេះ ហើយខ្ញុំមិនដឹងថា តើសហព្រះរាជអាជ្ញា គាត់ចង់ឲ្យសាក្សីធ្វើការទាយស្មាន ឬក៏យ៉ាងណា? សហព្រះរាជអាជ្ញាត្រូវតែផ្តល់មូលដ្ឋាន។ សហព្រះរាជអាជ្ញាគាត់ដឹងហើយ គឺត្រូវតែផ្តល់ព័ត៌មាន។ ដូច្នេះត្រូវតែសួរថា តើគាត់ដឹងដែរឬទេ ហើយត្រូវភ្ជាប់ទំនាក់ទំនងទៅនឹងមន្ទីរទាំងអស់នោះ។ បន្ទាប់មកត្រូវសួរថា តើសាក្សីដឹងអំពីមន្ទីរពិធីការដែរឬទេ? ទើបអាចឈានចូលទៅដល់ការសួរនៅក្នុងឯកសារ។

យើងមិនដឹងថា តើឯកសារនោះត្រូវបានបញ្ជូនទៅបុគ្គលណាផង បើទោះបីជាមានចម្លងជូនក៏

ដោយ។ យើងមិនអាចសួរឲ្យសាក្សីធ្វើការស្មាននោះឡើយ ហើយការធ្វើដូច្នេះមិនត្រឹមត្រូវឡើយ។ សហព្រះរាជអាជ្ញាគួរតែដឹងអំពីចំណុចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ! មានអីតបទេ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំនៅសល់តែប្រាំនាទីទេ។ ខ្ញុំសូមបង្ហាញឯកសារមួយទៀត ដូច្នេះខ្ញុំមិនចង់សង្កត់ធ្ងន់ទៅលើសំណួរនេះទេ។ ខ្ញុំគ្រាន់តែចង់សួរជាលក្ខណៈទូទៅថា តើជាក្រឹត្យក្រមនោះ ទូរលេខដែលផ្ញើទៅក្រសួងការបរទេសនោះ ត្រូវតែឆ្លងតាមមន្ទីរ៨៧០ សិន តើគាត់-- ខ្ញុំចង់ដឹងថា តើគាត់ដឹងអំពីព័ត៌មាននេះដែរឬទេ? ប្រសិនបើគាត់ដឹង គាត់អាចនិយាយ បើមិនដឹងទេ ក៏ប្រាប់ថាមិនដឹងទៅ មិនអីទេ។

[១១:៥៦:៣២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

ចំណុចនេះជាថ្មីម្ដងទៀតហើយ ខ្ញុំលើកជំទាស់ដោយសារបញ្ហានេះ។ សហព្រះរាជអាជ្ញាមិនបានផ្ដល់ជាមូលដ្ឋានឲ្យយើងដឹង។ វាជាការព្យាយាមចូល ទាញយកព័ត៌មានពីសាក្សី។ យើងមិនដឹងថាតើសាក្សីនេះដឹងព័ត៌មាន ឬក៏មិនដឹងព័ត៌មានផងនោះ។ គាត់មិនអាចសួរសំណួរដូច្នេះនោះឡើយ។

មុនដំបូងយើងឃើញថា គាត់សួរអំពីបញ្ហាសារទូរលេខ។ ចំណុចនេះគឺជាការព្យាយាមលួច ឬក៏ព្យាយាមយកព័ត៌មានមុនពេលដែលគាត់ផ្ដល់មូលដ្ឋាន។ សហព្រះរាជអាជ្ញាគួរតែសួរទៅថា តើសាក្សីស្គាល់មន្ទីរ៨៧០ ដែរឬទេ? ដំណើរការយ៉ាងម៉េច? ដឹងព័ត៌មានទាំងអស់នេះតាមរបៀបណា? ហើយមានប្រើប្រាស់ទូរសារដែរឬទេ? ហើយគេប្រើប្រាស់យ៉ាងម៉េច? ដូច្នេះហើយយើងមិនអាចឲ្យសហព្រះរាជអាជ្ញាអានសំណួរ--

[១១:៥៧:៣៣]

**ប្រធានអង្គជំនុំ៖**

លោកអាចនិយាយដោយសង្ខេប ហើយជាក់ច្បាស់បានទេ? ហើយលោកប្រើពាក្យពេចន៍ឲ្យបាន

សមរម្យនៅក្នុងការជំទាស់ទៅតាមនីតិវិធី។ មិនគប្បីប្រើពាក្យធ្ងន់ៗនោះឡើយ។ ឥឡូវលោកនិយាយខ្លីបានហើយ។ ការជំទាស់របស់លោកមូលហេតុអី? មិនគ្រាន់តែការជំទាស់ហ្នឹងអត្ថាធិប្បាយចង់កន្លះប្រាំមីនុត ឬដប់មីនុតអីចឹងទេ។ ព្រោះពេលវេលានៃកិច្ចដំណើរការសវនាការត្រូវការឆាប់រហ័ស។ លោកអាចសង្ខេបនូវមូលហេតុនៃការជំទាស់របស់លោកដោយខ្លីបានដែរឬទេ? មានប៉ុន្មានចំណុចនៃមូលហេតុនៃការជំទាស់លោក ដើម្បីឱ្យអង្គជំនុំជម្រះហ្នឹងមានមូលដ្ឋានក្នុងការពិភាក្សាសម្រេចលើបញ្ហាជំទាស់នេះថា ជំទាស់វាមានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាព ដើម្បីបន្តនីតិវិធីទៅមុខទៀត។

[១១:៥៨:២៣]

ហើយក៏មិនគប្បីចង្អុលបង្ហាញទៅភាគីម្ខាងទៀត អំពីវិធីក្នុងការតាំងសំណួរនោះដែរ។ នេះជាវិធីសាស្ត្រ បច្ចេកទេសក្នុងការតាំងសំណួរដេញដោល ភាគីនីមួយៗដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ។

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំមិនមែនផ្តល់ជាប្រឹក្សា ចំណុចប្រឹក្សាទៅដល់សហព្រះរាជអាជ្ញានោះទេ។ នៅពេលដែលយើងសួរសំណួរ យើងត្រូវតែសួរអំពីបទពិសោធន៍របស់សាក្សី ឬបុគ្គលដែលគាត់ផ្តល់សក្ខីកម្ម។ សហព្រះរាជអាជ្ញាមិនបានផ្តល់ជាមូលដ្ឋានណាមួយឱ្យយើងបានឃើញនោះឡើយ។

[១១:៥៩:១៦]

**ប្រធានអង្គជំនុំ៖**

យើងបានប្រាប់លោកហើយ ហើយលោកជំទាស់ហ្នឹងជំទាស់ស្អី? មូលហេតុអី? ឥឡូវនេះជំទាស់ តើដើម្បីយើងសម្រេចអំពីបញ្ហានេះ។ ព្រោះពេលវេលាព្រះរាជអាជ្ញានៅសល់តែពីរមីនុតទៀតទេ ហើយគាត់នឹងអស់ពេលវេលាសម្រាប់សួរតាំងសំណួរហើយ។ មូលហេតុអីច្បាស់លាស់នេះ? បញ្ហារឿងៗសំអាងហេតុនៃមូលហេតុនៃការជំទាស់នេះ?

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនបើសហព្រះរាជអាជ្ញាសួរសាក្សីឱ្យស្មាននោះ គាត់ត្រូវតែបង្ហាញព័ត៌មានមូលដ្ឋានជាមុន។ ហើយការដែលគាត់សួរនេះគឺមិនសមរម្យនោះទេ។ នេះគឺជាការជំទាស់របស់ខ្ញុំ។

ខ្ញុំសូមឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចទៅលើចំណុចនេះ។ បើមិនសម្រេចទេ គឺយើងខ្ញុំអាចយកព័ត៌មានណាក៏ដោយយកមកឱ្យសាក្សីនេះផ្តល់សុពលភាពតែម្តង។ ចំណុចដែលធ្វើដូច្នេះ គឺមិន

សមរម្យនោះទេ។

[១២:០០:១៥]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ដូរសំណួរ មានសំណួរអីផ្សេងទៀតទេ តាំងសំណួរបញ្ចប់នូវពេលវេលាសម្រាប់លោក ដែលត្រូវលោកធ្វើនៅពេលនេះ។ ហើយសំណួរអំមិញនេះចង់-- សាក្សីមិនបាច់ឆ្លើយទេ។ ហើយលើកក្រោយសូមមេធាវី រំឭកមេធាវីថា សុំជំទាស់ខ្លី ហើយជាក់ច្បាស់ ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានសម្រេចភ្លាមៗតែម្តង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំមិនចង់សួរសំណួរដដែលនេះទៀតទេ លោកប្រធាន ខ្ញុំគិតថា ខ្ញុំបានផ្តល់មូលដ្ឋានរួចហើយព្រោះថានៅក្នុងតួលេខនេះមានហត្ថលេខា។ ខ្ញុំសូមបង្ហាញឯកសារចុងក្រោយ និងជាសំណួរចុងក្រោយពីព្រោះថាពេលនេះ គឺពេលថ្ងៃត្រង់ហើយ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅខែធ្នូ ឆ្នាំ៧៨ គឺមួយខែមុនពេលវៃផ្តាច់ព្រាត់របស់វៀតណាម។ តើលោកធ្លាប់ជួបអ្នកកាសែតអាមេរិកពីរនាក់ និងអ្នក-- និងសាស្ត្រាចារ្យអង់គ្លេសម្នាក់? ខ្ញុំសូមផ្តល់ឈ្មោះតែម្តង គឺមានសាស្ត្រាចារ្យ ខាតវែល ហើយនិងលោកស្រី បេកឃ័រ ក្នុងចំណោមអ្នកទាំងបីនេះ។ ហើយមុននឹងអ្នកទីបី គឺលោក ឌឹក ម៉ាន់។ តើនៅខែធ្នូ ឆ្នាំ១៩៧៨ មុនពេលវៀតណាមចូលស្រុកនោះ លោកមានធ្លាប់ជួបអ្នកទាំងបីរូបនេះទេ?

[១២:០២:០៤]

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ខ្ញុំមិនចាំទេ។ បាទ អត់ចាំ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំសូមបង្ហាញឯកសារចុងក្រោយ ដែលមានមួយទំព័រកន្លះជូនទៅសាក្សី ដើម្បីរំឭកការចងចាំរបស់គាត់។ ឯកសារនេះ គឺ “ផ្ញើជូនបងជាទីស្នេហា នៅថ្ងៃទី៨ ធ្នូ ឆ្នាំ១៩៧៨ ដែលអ្នកសរសេរឯកសារនេះឈ្មោះ កន និង មុត ដែលនិយាយអំពីសំណួមពររបស់សាស្ត្រាចារ្យ ខាត់វែល លោក ឌឹក ម៉ាន់ និងអ្នកស្រី បេកឃ័រ នៅពេលទស្សនកិច្ច។ ឯកសារនេះ គឺលេខE3/1156 ឬ

D366/7.1.214។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ!

[១២:០៣:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសូមផ្តល់ពេលវេលាពីរបីវិនាទីឲ្យលោកសាក្សីពិនិត្យមើលឯកសារនេះ ហើយបន្ទាប់មកសូមឲ្យលោកប្រាប់យើងថា តើលោកបានធ្លាប់ជួបអ្នកទាំងបីរូបនេះទេ។ ហើយលោកជាមួយនឹង មុត នោះបានរាយការណ៍ទៅក្រសួងការបរទេស?

*(សាក្សីពិនិត្យឯកសារ)*

[១២:០៥:០៨]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី តើលោកបានពិនិត្យមើលឯកសារនេះហើយឬនៅ? លោកអាចជម្រាបយើងបានទេ ថាតើអ្នកណាជាអ្នកសរសេរឯកសារនេះ? ហើយអ្នកណាដែលឈ្មោះ កន ហើយនិង មុត ដែលបានសរសេរឯកសារនេះនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ នោះ?

[១២:០៧:០២]

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន ឈ្មោះ មុត ខ្ញុំដឹងតែម្នាក់ទេ។ ក្នុងក្រសួងនោះគេហៅ មុតៗ។ ហើយ មុត ហ្នឹងគឺបើឋានៈតឡូវនេះតាមមើលឯកឧត្តម គាត ឈន់ ហ្នឹងហើយ បាទ។ តែនេះការយល់ៗរបស់ខ្ញុំ។ តែការខុសត្រូវ ខ្ញុំមិនច្បាស់ដែរ ពីព្រោះបើខ្ញុំស្គាល់ឈ្មោះ មុតៗ ហ្នឹង មានប៉ុណ្ណឹង។ មានឈ្មោះហ្នឹង។ ហើយការចងចាំជម្រាបជូនបន្តបន្ទាប់ហើយ គឺចងចាំមិនអស់ទេ ពីព្រោះពេលវេលាវាវែង ហើយក៏មិនបានការកត់ត្រាគិតគូរចងក្រងអីក៏អត់មាន។ ហៅថាធ្វើតាមតែការណែនាំអ៊ីចឹងទៅ រួចហើយគ្មានកត់ត្រាគ្មានអីទុកដាក់អីទេ។ តែបើ តាមុត ហ្នឹង គឺគាត់ជាអ្នកកត់ត្រា។ គាត់យល់អំពីភាសា គាត់យល់អំពីការចោទឆ្លើយ។ ដូច្នេះ អាចអមដំណើរជាមួយគ្នា គាត់អ្នកកត់ត្រាហ្នឹងបាន តែខ្ញុំមិនចងចាំទេគ្រាន់ថា លោកបង្ហាញខ្លឹមសារហ្នឹងមកហើយ បង្ហាញនូវឈ្មោះគណៈប្រតិភូមិរួចមកហើយ ខ្ញុំឃើញ

ថាពេលហ្នឹងអាចមានអ៊ីចឹងមែន អាចមានជូនភ្ញៀវហ្នឹងពីរនាក់ បាទ។ គាត់អ្នកបកប្រែ។ សូមអស់បាទ។

[១២:០៩:00]

**ស៖** តើលោកមែនទេ ដែលជាអ្នកសរសេរឯកសារនេះជាមួយនឹង មុត នេះ? ខ្ញុំមិនយល់ទេ ចម្លើយលោកអម្បាញ់មិញនេះថា គឺលោកមែនទេ ដែលជាអ្នកជួយគណៈប្រតិភូ អ្នកកាសែត ហើយនិងសាស្ត្រាចារ្យមកនេះ?

**ឆ៖** តាមខ្ញុំចាំឡើងវិញហ្នឹង គឺឃើញឯកសារលោកនេះ ហើយនិងរឿងរ៉ាវចាស់នេះ តាមមើលគឺមានខ្ញុំ ហើយនិង បងមុត ហ្នឹង តាមុត ហ្នឹង ដែលរួមគ្នាសរុបរាយការណ៍។ ពីរនាក់ មិនមែនម្នាក់ទេ ប៉ុន្តែចងចាំវាមិនច្បាស់បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានសូមការអនុញ្ញាតសួរសំណួរចុងក្រោយ។

[១២:០៩:៥៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ចំពោះខ្លឹមសារនៃឯកសារនេះ លោកនិយាយថាលោកជាអ្នកសរសេររួមជាមួយ មុត។ សាស្ត្រាចារ្យ ហើយនិងអ្នកកាសែតនេះបានសួរ-- បានសំណូមពរជាច្រើន សុំទៅជិតព្រំដែន សុំទៅមើលជនបទ ចង់ឃើញជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ចង់ជួបកម្មាភិបាលជាច្រើននៅគ្រប់ក្រុង ចង់ទៅមើលសហករណ៍ ចង់ទៅមុខមើលគុកនយោបាយ ចង់ជួបផ្ទាល់មនុស្សដាច់ដោយឡែកពីគ្នា ចង់ដឹងអំពីប្រជាជនចាម ចង់ដឹងអំពីការសម្លាប់មនុស្ស ហើយនិងជួបមេដឹកនាំដែលមានដូចជា លោកនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី អៀង សារី និង សុន សេន, បង អៀង ធីរិទ្ធ, ខៀវ ប៉ុណ្ណារី, នួន ជា, សម្តេច សីហនុ, ហ៊ូ យន់ និង ហ៊ូ នឹម។ តើលោកអាចនិយាយបានទេថា អ្នកណាដែលលោកផ្ញើឯកសារនេះជូន? ហើយតើមានប្រតិកម្មយ៉ាងណាចំពោះសំណូមពរទាំងអស់នេះ? តើលោកដឹងទេថា ថាតើសំណូមពរនេះត្រូវបានអនុញ្ញាតទេ? ហើយពួកគាត់ទាំងបីនាក់ហ្នឹងទទួលបានតាមអ្វីដែលពួកគាត់ចង់បានទេ?

**លោក នី កន៖**

**ឆ៖** តាមខ្ញុំចាំដោយត្រួសៗ អន្លើៗនេះ គឺសំណូមពរនេះដូចមិនបានសម្រេចអីប៉ុន្មានទេ។ ខ្ញុំដឹង

តែប៉ុណ្ណឹង ប៉ុន្តែពីព្រោះពេលនុ៎ងការងារទាំងអស់នេះ បានតែពាំនាំមកទេ តែអ្នកសម្រេចនៅខាងលើ។ បាទ សូមជូនយោបល់-- បញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំមើលឃើញថាដល់ម៉ោងហើយ ដូច្នេះខ្ញុំសូមបញ្ឈប់ត្រឹមនេះ។ ខ្ញុំសូមអរគុណលោកសាក្សីចំពោះភាពអត់ធ្មត់ក្នុងការឆ្លើយសំណួរ។ សូមអរគុណ។

[១២:១២:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះដល់ពេលពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីនបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:១៣:១១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមស្នើដូចធម្មតា ដោយមូលហេតុធម្មតាដើម្បីឲ្យកូនក្តីរបស់ខ្ញុំទៅតាមដានសវនាការនៅក្នុងបន្ទប់ខាងក្រោម ហើយយើងខ្ញុំនឹងបំពេញបែបបទតាមនីតិវិធីតម្រូវបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការនៅរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។ ដោយក្រុមមេធាវីការពារក្តីបានសន្យាថា ខ្លួននឹងប្រគល់មកលិខិតលះបង់សិទ្ធិ

ចូលរួមសវនាការរបស់ជនជាប់ចោទមកឱ្យអង្គជំនុំជម្រះ។

[១២:១៤:០០]

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សុំលះបង់-- សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមបន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឱ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដែលមានចុះហត្ថលេខា ឬក៏ផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលថ្ងៃនេះ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ ដោយទុកឱ្យ នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់រូបគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅរសៀលនេះ។ដោយឡែកលោក ខៀវ សំផន បង្គាប់ឱ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៤:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តនេះ ដល់ពេលក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិអាចតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[១៣:៣៥:០៤]

**លោក ឡៅ ជុនធី៖**

បាទ ខ្ញុំបាទ ឡៅ ជុនធី ជាមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីនៅពេលនេះ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះនៅពេលនេះ។ ខ្ញុំបាទ មានកិត្តិយសនឹងសាកសួរទៅដល់លោកអ៊ំដែលជាសាក្សីឈ្មោះ នី កន នៅពេលនេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** ជាដំបូងខ្ញុំ សូមជម្រាបសួរទៅលើអ៊ំ ដែលពាក់ព័ន្ធទៅនឹងសាវតាររបស់អ៊ំពីមុនមកខ្លះ ថាតើអ៊ំបានកើតនៅៗស្រុក នៅខេត្តណាដែរ? ហើយអ៊ំបានចេញពីស្រុកហ្នឹងមកនៅកន្លែងណា? រៀនសូត្រនៅកន្លែងណា?

[១៣:៣៦:០៥]

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន ស្រុកកំណើតដែលខ្ញុំកើត គឺនៅកម្ពុជាក្រោម។ ស្រុកហ្នឹង គេហៅស្រុក គេហៅ ត្រាយីង ខ្មែរយើងគេហៅ ព្រះត្រពាំង ហើយខ្ញុំចេញពីស្រុកមកវាតាំងពីអាយុប្រាំដណ្តប់។ ដូច្នេះខ្ញុំមកនៅភ្នំពេញ ហើយខ្ញុំក៏រៀនសូត្រនៅកម្ពុជាយើងនេះរហូតមកទល់ថ្ងៃដែលបានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិ ហើយក៏បានប្រឡងចេញទៅ អឺ! បានប្រឡងជាប់ ជំនាន់នោះ គេហៅថ្នាក់ ឌីប្លូម បាទ។ នេះជាប្រវត្តិដើមរបស់ខ្ញុំ គឺប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ នៅតាមប្រវត្តិការងារ និងការតស៊ូរបស់អ៊ំគឺថា នៅក្នុងឆ្នាំ១៩៦៦ គឺអ៊ំបានធ្វើគ្រូបង្រៀននៅសៀមរាប ហើយឆ្នាំ១៩៧០ អ៊ំបានចូលព្រៃ ហើយបន្ទាប់មកគឺថា នៅឆ្នាំ១៩៧៥ ដល់ ៧៧ ហ្នឹងអ៊ំធ្វើការឃោសនាអប់រំនៅភូមិភាគពិសេស ហើយនិងឆ្នាំ១៩៧៨ គឺអ៊ំបានផ្លាស់មកក្រសួង

ការបរទេស។ ចំណុចសំណួរ ថាតើនៅឆ្នាំ១៩៧០ នោះ គឺមានការអំពាវនាវមួយដើម្បីឲ្យចូលទៅក្នុងព្រៃតស៊ូ តើចំណុចនេះអ៊ំយល់ថាម៉េចបានជាអ៊ំចូលធ្វើការតស៊ូនោះ?

[១៣:៣៨:២៣]

**ឆ៖** សូមជម្រាបជូន មូលហេតុដែលខ្ញុំសម្រេចចិត្តចូលរួមការតស៊ូមកពីឃើញទិដ្ឋភាពរួមក្នុងប្រទេសយើង គឺប្រជាជនក្មេងចាស់ ប្រុសស្រី ទាំងអស់ ហើយដូចបានជម្រាបបន្តបន្ទាប់មករហូតដល់មានការអំពាវនាវរបស់ព្រះមហាក្សត្រ ដោយលើកហេតុផលគឺរំដោះជាតិ ហើយលើកស្ទួយជីវភាពប្រជាជនខាងជីវភាពសេដ្ឋកិច្ចឲ្យបានល្អប្រសើរ។ អ៊ីចឹងទៅខ្ញុំក៏ស្ម័គ្រចិត្តចូលរួមទៅ។

**ស៖** បាទ ចំណុចនេះ វាជាចំណុចសំខាន់ដែលតាមខ្ញុំយល់ គឺថាវាជាសម្បជញ្ញៈរបស់អ៊ំថា គឺជាការតស៊ូមួយសម្រាប់រំដោះជាតិឲ្យមានឯករាជ្យ ហើយនិងសេរីភាព។ ថាតើអ្វីដែលអ៊ំបានចូលតស៊ូតាំងពីនុ៎ងមក ហើយរហូតទៅដល់បញ្ចប់នៃរបបនេះ តើអ៊ំបានមាន បានន័យថា យល់ឃើញយ៉ាងដូចម្ដេចដែរ?

**ឆ៖** សូមឆ្លើយ។ ការចូលរួមរបស់ខ្ញុំនេះ គឺឈរនៅលើមូលដ្ឋាន ដូចបានជម្រាបខាងដើម។ ឯការគិតគូរថា សភាពការណ៍ប្រែប្រួលបន្តបន្ទាប់មកក្រោយទៀត មិនបានគិតទេ។ នេះជាសភាពជាក់ស្ដែងនៃខ្លួនខ្ញុំបាទ។

**ស៖** បាទ អរគុណ។ តាមប្រវត្តិសាវតាររបស់អ៊ំ គឺអ៊ំមានបងប្អូនបីនាក់ បងរបស់អ៊ំ សុន សេន ហើយបងមួយទៀត នី ឈុំ។ តើមូលហេតុអី ដែលប្រើបង សុន សេន គាត់ប្រើត្រកូលផ្សេង?

**ឆ៖** ជម្រាបជូន។ ត្រកូលនេះ គឺបងដែលមកមុន ដាក់តាមត្រកូលគាត់អ៊ីចឹងទៅ តាមគាត់យល់អ៊ីចឹងទៅ។ ឯពួកខ្ញុំមកក្រោយ ពិសេសខ្ញុំៗមិនដឹងថា ច្បាស់លាស់ជាត្រកូលយ៉ាងម៉េច ខ្ញុំយកឈ្មោះឪពុកខ្ញុំឈ្មោះនី ដាក់បណ្ដោយទៅបាទ។

[១៣:៤១:៥៦]

**ស៖** អរគុណ។ នៅមុនឆ្នាំ១៩៧៥ ពេលនោះអ៊ំបាន បានន័យថា បានចូលតស៊ូហើយ តើមុនឆ្នាំ៧៥ហ្នឹង អ៊ំស្ថិតនៅកន្លែងណាខ្លះ? ខ្ញុំចង់ដឹងថាអ៊ីចឹង។ ទីមួយគឺថា អ៊ំនៅសៀមរាបធ្វើគ្រូបង្រៀនក្រោយមកគឺចូលមានការតស៊ូនោះ ថាតើចល័តនៅកន្លែងណាខ្លះ មុន៧៥?

**ឆ៖** សូមបញ្ជាក់ជូនបាទ។ ចល័តពីសៀមរាបមក ដល់ពេលសង្គ្រាមផ្ទុះកាន់តែខ្លាំង រំកៀកក្រុងភ្នំពេញ។ គេហៅថា ចលនាប្រមូលកម្លាំងសម្រុករំចូលក្រុងភ្នំពេញ ខ្ញុំក៏បានមកតាំងនៅម្ដុំអង្គរស្ស

នេះ។ ហើយកាលនោះក៏មិនបានបញ្ជាក់ថាស្រុកអីៗទេ គ្រាន់ថាមកកន្លែងអង្គរស្សហ្នឹងក៏នៅជាមួយ កងទ័ពនៅខាងមុខ ហើយខ្ញុំមានភារកិច្ចនៅខាងក្រោយ ខាងផ្នែកឃោសនា មួយផ្នែកបាទ។

**ស៖** ទាក់ទងនឹងអ៊ំបានរៀនសូត្របាន គេហៅថា ជំនាន់នោះរៀនដល់ឌីប្លូម បានន័យថា ចេះដឹងច្រើន។ ដូច្នេះ អ្វីដែលខ្ញុំទទួលការខុសត្រូវ ទៅលើការឃោសនាអប់រំ ខ្ញុំចង់ដឹងថា តើអ្វីដែលការឃោសនាអប់រំឲ្យប្រជាជនបានចូលរួម ទៅនឹងថាកងទ័ពតស៊ូជំនាន់នោះ តើយកគោលនយោបាយពីខាងណាមក ដើម្បីឃោសនាឲ្យប្រជាជនចូលរួមហ្នឹង?

[១៣:៤៤:២០]

**ឆ៖** ខ្លឹមសារ និងគោលនយោបាយយកមកអប់រំនោះ គឺខ្លឹមសារសំខាន់ហ្នឹងគឺថា ដោយព្រះមហាក្សត្រជាសំខាន់។ ពេលរដ្ឋប្រហារទៅ ហើយមានព្រះមហាក្សត្រចលនាឲ្យចូលព្រៃម៉ាគី ដើម្បីបុព្វហេតុ ហៅថា វ៉ែចក្រពត្តិ។ ចក្រពត្តិហ្នឹង គឺមានន័យទូលំទូលាយទៀតគឺ លន់ នល់។ អ៊ីចឹងយកខ្លឹមសារនេះ។ ប្រជាជនទូទៅក្នុងប្រទេសកម្ពុជា គ្រប់ជាន់ថ្នាក់ ជាមូលដ្ឋាន គឺគោរពព្រះមហាក្សត្រស្រឡាញ់ព្រះមហាក្សត្រ។ ដូច្នេះយកពាក្យស្លោកនេះមកឃោសនា គឺប្រជាជនទទួលបានច្រើន។ នេះសូមជម្រាបលោក។

**ស៖** ខ្ញុំសូមភ្ជាប់ចំណុចហ្នឹងបន្តិចគឺថា ខ្ញុំដឹងថាយកជាគោលគឺ ព្រះមហាក្សត្រអ៊ីចឹង ដើម្បីយកឃោសនា។ ថាតើអ្វីដែលជាប្រភពដែលចេញមកហ្នឹង ប្រភពហ្នឹងចេញពីណា? ប្រភពហ្នឹងចេញពីមេបក្សមួយណា? ឬមួយពីអ្នកដឹកនាំមួយណា? ឬមួយចេញពីបក្សយ៉ាងម៉េច?

**ឆ៖** សូមជម្រាបជូន ប្រភពហ្នឹងគេមានក្រុម ដែលខ្ញុំបានជម្រាបបន្តបន្ទាប់ថា គ្រូបង្រៀននេះក៏មានក្រុមរបស់គ្រូបង្រៀន។ ហើយអង្កាល់ណោះ គេកំណត់ថាក្រុមទទួលខុសត្រូវតាមស្រុក តាមខេត្តតាមអីអ៊ីចឹងទៅ គេយកខ្លឹមហ្នឹងមកផ្សព្វផ្សាយទៅ ហើយចេះតែទទួលបន្តគ្នាមក។ ដល់ក្រោយមកទៀត ដល់សង្គ្រាមផ្ទុះខ្លាំង-- វ៉ៃកាន់តែខ្លាំងមកទៀត ក៏នៅតែយកខ្លឹមសារមូលដ្ឋានហ្នឹងដដែល។ ឃោសនា។ ប៉ុន្តែវាមានអ្នកណែនាំបន្តបន្ទាប់មក។ ឯអ្នកណែនាំនោះទទួលពីណាមកអត់ដឹងទេ ពីព្រោះគេហៅថា "សម្ងាត់" ឬ ខ្ញុំចាំមិនអស់ដែរ យូរហើយ ដូចជាគេហៅថា "ខ្សែៗរបស់គេ ខ្សែស្រឡាយរបស់គេមក"។ ហើយយើងបានទទួលការហ្នឹង យើងក៏យល់តាមហ្នឹង ហើយក៏ចូលរួមទៅបាទ។

[១៣:៤៧:២១]

**ស៖** អរគុណ។ នៅពេលដែលអ៊ំបានធ្វើបដិវត្តន៍ហើយ ហើយពេលនោះគឺនៅក្នុងឆ្នាំ១៩៧៥

ហ្នឹង គឺបានលើកឡើងថា គឺយើងបានបញ្ចុះបញ្ចូល បានឃោសនាអប់រំប្រជាជនមុននឹងវាយបែកភ្នំពេញនេះ។ ខ្ញុំចង់ដឹងថា តើយើងឃោសនាអប់រំប្រជាជនយ៉ាងម៉េច ពេលដែលវាយបែកត្រូវជម្លៀសប្រជាជនចេញ តើយើងយកមូលដ្ឋានអី ដែលធ្វើឱ្យប្រជាជនយល់ថា ពេលដែលចេញពីភ្នំពេញ ចេញដោយសុខស្រួល ឬមួយយ៉ាងម៉េច?

**ឆ៖** មូលដ្ឋាននៃការឃោសនា អំពាវនាវឱ្យប្រជាជនចេញពីក្រុងនោះ ដូចដែលខ្ញុំជម្រាបពីម្សិលមិញដែរ គឺគេចការគ្រោះថ្នាក់ដោយកប៉ាល់ហោះទម្លាក់ និងគេចក្នុងករណីដែលមានការវាយដណ្ដើមយកវិញនូវក្រុងភ្នំពេញ។ ដូច្នេះ ហៅថា "ចេញជាបណ្ដោះអាសន្ន"។ នេះដែលខ្ញុំបានទទួល។ ឯរឿងតៗមកទៀតយ៉ាងម៉េច ខ្ញុំមិនដឹងទេបាទ។

[១៣:៤៩:១២]

**ស៖** អរគុណ។ តើរវាងនៅក្នុងឆ្នាំ១៩៧៥ ទៅ ឆ្នាំ១៩៧៦ និងចុងឆ្នាំ១៩៧៧ គឺពេលនោះ គឺភូមិភាគបស្ចិម បានន័យថាភូមិភាគបស្ចិមហ្នឹង គឺមានៗអ្វីប្លែកទេនៅពេលដែល-- បានន័យថា ពេលនោះអ៊ំបានធ្វើការនៅតំបន់៣២ ហើយចូលក្នុងភូមិភាគបស្ចិម។ ដល់ពេលអ៊ំត្រឡប់ចេញពីនុ៎ងមក មកនៅខាងក្រសួងការបរទេស សួរថាតើនៅខាងភូមិភាគហ្នឹង វាមានអីប្លែកដែរអត់?

[១៣:៥០:១២]

**ឆ៖** ចន្លោះពេលដែលខ្ញុំត្រូវដកមកដាក់ក្រសួងការបរទេស ខ្ញុំមកផុតហើយ ក៏មានដំណឹងនិយាយតៗគ្នា ថានៅភូមិភាគបស្ចិមនេះ មានការដកកម្មាភិបាលទៅនេះទៅនោះ តែគ្មានបានដឹងដំណឹងពិតប្រាកដថាតើទៅណា មកណាទេ តែមានការដកហូត។ ហើយចុងក្រោយ ក៏ឮមានពាក្យថា ដកហូតមេភូមិភាគ។ នេះដែលខ្ញុំដឹងបាទ។ តែមិនមែនជាផ្លូវការទេ ជាការខ្សឹបខ្សៀវទេ។ បញ្ជាក់ជូនអង្គសវនាការថាជាពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ។ រឿងខ្លះ ខ្ញុំមិនដឹងដូចព្រឹកមិញអ៊ីចឹង តែពេលដែលខ្ញុំត្រូវដកមក ហៅថាមកជួយការងារក្រសួង តែអ្នកមូលដ្ឋានក៏សន្និដ្ឋានថា ខ្ញុំក៏ត្រូវដកហូតដែរ។ នេះជាការដែលខ្ញុំដឹងបាទ។

**ស៖** បាទ អរគុណ។ ដូចចំណុចនេះ អ៊ំបានឮថា ឮរហិចរហៀង មានការដកហូតអ៊ីចឹង តើក្រោយមកទៀត មានដឹងថាព័ត៌មានថាចំពោះអ្នកដែលត្រូវដកហូតហ្នឹង ត្រូវទៅណា? ឬមួយយ៉ាងម៉េចតទៅទៀត មានដឹងដែរអត់ទេ?

[១៣:៥២:១១]

**ឆ៖** បញ្ហានេះ ដឹងត្រឹមហ្នឹង។ ហួសពីហ្នឹងទៀត អត់បានដឹងទេបាទ។

**ស៖** អរគុណ។ គឺពាក់ព័ន្ធនឹងអ្វីដែលអ៊ំបានធ្វើការនៅក្នុងក្រសួងការបរទេស ខ្ញុំចង់ដឹងថា តើនៅក្រសួងការបរទេសហ្នឹង មានមន្ទីរ បានន័យថា មានមន្ទីរនៅផ្នែកនៃការងារហ្នឹង មានប៉ុន្មានដែរ?

**ឆ៖** សូមជម្រាបជូន ការបែងចែកមន្ទីរនៅក្រសួងនេះ ខ្ញុំអត់បានដឹងទេ។ ខ្ញុំដឹងតែការងារដែលខាងមន្ទីរប្រគល់ឲ្យខ្ញុំខាងផ្នែកតូចមួយ នៃពិធីការ។ បាទ អ៊ីចឹងហើយបានឆ្លៀតឱកាសនេះដែរ ចង់បញ្ជាក់ថា ពាក្យដែលសួរខ្ញុំថា "ជាចាងហ្វាងពិធីការ" នេះ មានអត្ថន័យយ៉ាងណា? ពីព្រោះមានលក្ខណៈដែលតាមយល់ ដោយមានការពិគ្រោះជាមួយមេធាវីថា វាមានន័យធំណាស់។ ចាងហ្វាងហ្នឹងគឺវាគ្រប់គ្រងទាំងអស់ តែន័យប្រតិបត្តិជាក់ស្ដែងរបស់ខ្ញុំមិនបានទូលំទូលាយអ៊ីចឹងទេ។ ខ្ញុំជាអ្នកនៅកូនហៅថាកូនផ្នែកមួយ ទទួលបញ្ជាឲ្យធ្វើប៉ុណ្ណេះប៉ុណ្ណោះ បានតែត្រឹមប៉ុណ្ណឹង។ អ៊ីចឹង បានជាឱកាសមួយដែរ ដែលសូមបញ្ជាក់ឲ្យអង្គសវនាការច្បាស់ថា ចាងហ្វាង បើមានន័យដែលថា បានពិគ្រោះនេះ វាទូលំទូលាយ ខ្ញុំមិនមែនស្ថិតក្នុងសភាពហ្នឹងទេបាទ។

[១៣:៥៤:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណ សាក្សី ហើយអ្វីដែលលោកបានលើកឡើងនេះ អង្គជំនុំជម្រះបានស្ដាប់ពីព្រឹកហើយលោកបាននិយាយម្ដងហើយ។ អ៊ីចឹង បញ្ហាមួយ គប្បីនិយាយតែម្ដងទៅបានហើយ ពីព្រោះមានការកត់ត្រានៅក្នុងប្រតិចារឹកនៃដំណើរការសវនាការរួចហើយ។ ចៀសវាងការនិយាយច្រំដែល ហើយនិងអាចមានការផ្ទុយគ្នា ឬក៏ខុសគ្នា ឬក៏វានាំឲ្យចំណាយពេលវេលាឥតប្រយោជន៍។ សូមបន្តតាំងសំណួរ។

[១៣:៥៤:៤០]

ហើយសូមរំឭកដល់មេធាវីតំណាងមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ សំណួរគប្បីចៀសវាងនូវសំណួរណាដែលហាមឃាត់ ដូចជាសំណួរឲ្យបង្ហាញពីការយល់ដឹងផ្ទាល់ខ្លួនរបស់សាក្សីជាដើម។ នេះមិនមែនជាសំណួរដែលច្បាប់តម្រូវ ឬអនុញ្ញាតឲ្យធ្វើដូច្នេះទេ។

[១៣:៥៥:០៥]

**លោក ឡោ ជុនធី៖**

អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ពាក់ព័ន្ធនឹងក្រសួងការបរទេសនេះឯង គឺបរិបទមួយ គឺលោក លោកពូនៅផ្នែកការជូនភ្ញៀវ ព្រឹកមិញលោកខាងសហព្រះរាជអាជ្ញាបានហើយថា តើពាក់ព័ន្ធនឹងការជូនភ្ញៀវនេះ។ ប៉ុន្តែខ្ញុំចង់ដឹងមួយថា តើអ៊ំបានៗជូនភ្ញៀវដែលជាជនជាតិចិនដែរឬទេ?

**លោក នី កន:**

**ឆ៖** សូមជម្រាបជូន បានជូនតែមិនចាំ ជាភ្ញៀវណាៗមិនចាំអស់ទេបាទ។

**ស៖** ចំណុចពាក្យមួយទៀត គឺថាភ្ញៀវដទៃក៏បានជូនទៅដែរ។ ប៉ុន្តែខ្ញុំចង់ដឹងថាតើ ពេលដែលយើងជូនទៅហ្នឹង ទៅតាមផ្លូវ មុនដែលយើងជូនទៅ តើយើងមានទំនាក់ទំនងទៅតាមមូលដ្ឋានហ្នឹងថានេះថ្ងៃនេះ ពេលនេះយើងនឹងជូនភ្ញៀវទៅអង្គរវត្តហើយ។ តើយើងមានការជូនដំណឹងអីចឹងដែរឬអត់?

**ឆ៖** សូមឆ្លើយ ពេលនោះការជូនភ្ញៀវទៅអង្គរវត្ត អត់មានឆ្លងថា ត្រូវជម្រាបអ្នកមូលដ្ឋាននៅកន្លែងនោះទេ។ ពេលនោះគេមានផ្នែកទទួលភ្ញៀវមួយនៅប្រចាំសៀមរាប។ ដូច្នេះការជូនដំណឹងអីៗនុ៎ងគេជូនដំណឹងទៅតាមនីរសារ ប្រើពាក្យថា អ្នកនាំសំបុត្រទៅប្រាប់ថា ថ្ងៃប៉ុណ្ណេះ ថ្ងៃប៉ុណ្ណោះ មានភ្ញៀវទៅដល់សៀមរាបហើយ រង់ចាំទទួលផងបាទ។

[១៣:៥៧:២៨]

**ស៖** អរគុណ។ ចំណុចមួយទៀត នៅពេលដែលជូនភ្ញៀវទៅហ្នឹង គឺថាតាមផ្លូវមានការជួបនឹងប្រជាជនដែលធ្វើការនៅតាមដងផ្លូវហ្នឹងដែរឬទេ? ហើយប្រសិនបើឃើញជួប ថាតើឃើញទិដ្ឋភាពហ្នឹងយ៉ាងដូចម្តេចដែរ?

**ឆ៖** ដូចខ្ញុំជម្រាបពីព្រឹកមិញថា ប្រជាជននៅអមផ្លូវលេខ៦ ពីភ្នំពេញទៅដល់អង្គរវត្តមានតិចតួច ឯប្រជាជនដែលទៅប្រមូលផ្តុំនៅតាមការដ្ឋាននៅឆ្ងាយ ហើយសភាពការណ៍ដែលខ្ញុំឃើញ ឃើញបានតិច ពីព្រោះខ្ញុំចូលទៅដល់កំពង់ធំហូបបាយ ហូបបាយហើយធ្វើដំណើរបន្ត ១ទម្រាំដល់ហ្នឹងទៅក៏ឃើញគ្រួសៗទេ។ ហើយបានជម្រាបពីព្រឹកមិញថា ឃើញការហូបចុកក៏មិនសូវគ្រប់គ្រាន់បាទ។

[១៣:៥៨:៥៤]

**ស៖** ម៉េចបានអ៊ំថា គ្រាន់តែឃើញមួយគ្រួស ហើយថាឃើញការហូបចុកមិនគ្រប់គ្រាន់ បានន័យថាឃើញគាត់ស្គម ឬមួយឃើញគាត់យ៉ាងម៉េច?

**ឆ៖** ខ្ញុំឃើញដោយពិនិត្យតាមដែលការសន្និដ្ឋាន ហើយនិងតាមការឃើញដែលអ្នកមកពីក្រុង

ភ្នំពេញចេញទៅច្រើន ហើយអ្នកតាមជនបទ ដែលនៅតាមបណ្ដោយផ្លូវនេះ ក៏មិនមែនជាអ្នកសម្បូរធូរធារអីដែរ គឺមួយគ្រប់មួយគ្រាន់ ហើយខ្វះកន្លះខ្វះ។ ដល់អ៊ីចឹងទៅ ខ្ញុំសន្និដ្ឋានថា មិនគ្រប់គ្រាន់ទេ។ ឯរូបរាងមិនបានឃើញតែកន្លែងប្រមូលផ្ដុំខាងផ្នែកខុសភាពទេ។ គ្រាន់តែឃើញរាងរូវវាត្រដំត្រសងគ្នា វាពិនិត្យទៅឃើញថា មិនសូវគ្រប់គ្រាន់បាទ។

**ស៖** ត្រឡប់មកវិញ ថានៅក្នុងក្រសួងការបរទេស មានអ្នកដែលក្រុមដែលជូនភ្ញៀវដូចអ៊ំអ៊ីចឹង មានប៉ុន្មានក្រុមដែរ?

**ឆ៖** បាទ ក្រុមជូនភ្ញៀវហ្នឹងមានច្រើន ប៉ុន្តែឲ្យច្បាស់លាស់ប៉ុន្មាន អីប៉ុន្មានមិនច្បាស់ មិនចាំទេ តែដឹងតែថា មានខាងជំនាញហ្នឹង ភ្ញៀវណាដែលសំខាន់ៗហ្នឹង មានក្រុមមួយទៅ ណាល្មម ឬកម្រិតទាប គឺខ្ញុំទៅ មានប៉ុណ្ណឹង។ ហើយក្រុមទាំងអស់នោះ គេទទួលការណែនាំពីមន្ទីរដដែលបាទ។

[១៤:០១:១៣]

**ស៖** នៅក្នុងក្រសួងការបរទេសហ្នឹង ពេលដែលអ៊ំធ្វើការនៅទីនោះ សួរថាតើមានការប្រជុំញឹកញាប់ទេ ហើយប្រជុំហ្នឹងគឺយើងបានប្រជុំជាលក្ខណៈយ៉ាងម៉េច? លក្ខណៈក្រុមតូច ឬមួយលក្ខណៈក្រុមធំ? អាចជួបជុំគ្នាទាំងអស់គ្នា ឬមួយយ៉ាងម៉េច?

**ឆ៖** ប្រជុំ គេបែងចែកតាមកម្រិត តាមសំណូមពរ។ ប្រជុំមួយ គេហៅថាប្រជុំរួម អាហ្នឹងគេប្រជុំធំហើយ មានអ្នកណាដែលជាបុគ្គលិក ជាអីទាំងអស់នៅក្នុងហ្នឹងចូលរួម។ ឯប្រជុំតូចហ្នឹង គេប្រជុំការងារ។ ឧបមាថា ការងារថ្ងៃស្អែកនេះត្រូវធ្វើអី អ្នកណាត្រូវទៅណា? អាហ្នឹងគេប្រជុំអ៊ីចឹង។ អាហ្នឹងហៅថាប្រជុំតូចបាទ។

**ស៖** អ៊ីចឹងបានសេចក្ដីថា នៅទីនោះមានការប្រជុំធំ ថាតើពេលដែលប្រជុំធំហ្នឹង អ៊ំប៉ាន់ប្រមាណមើលថា តើបុគ្គលិកនៅក្នុងក្រសួងការបរទេសមានប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំស្មានមិនត្រូវដែរ ពីព្រោះខ្ញុំប៉ាន់ប្រមាណទៅ វាមានមកពីគ្រប់ផ្នែក មកពីណា ពីណី អីដែលតាមរចនាសម្ព័ន្ធរបស់ក្រសួង។ តែដូចជាឃើញថា រួមហ្នឹងមិនហួសពី ហាហុកសិបនាក់ទេបាទ។

**ស៖** ចុះក្នុងអំឡុងដែលអ៊ំធ្វើការងារនៅទីនោះ គឺថា ឧទាហរណ៍ថា ថ្ងៃហ្នឹងប្រជុំ ដល់លើកក្រោយ មួយខែក្រោយទៀតប្រជុំទៀត។ ពេលដែលប្រជុំហ្នឹងមានបាត់មនុស្សដែរអត់ទេ?

**ឆ៖** បាទ រឿងបាត់មនុស្ស ពេលដែលខ្ញុំមកមិនឃើញទេ អាចមានពេលដែលខ្ញុំមកមិនទាន់ដល់បាទ។

**ស៖** អរគុណ។ នៅឆ្នាំ១៩៧៨ តើលោកធ្លាប់បានលើកនិយាយថា ក្នុងនោះខ្ញុំសូមលើកនៅក្នុងពាក្យមួយថា “មួយចំនួននៃកម្មាភិបាលបក្ស បំផ្លាញមាគ៌ាបក្ស ហើយបានបន្តមាគ៌ាឆ្វេងនិយមជ្រុលនិងបានធ្វើឱ្យបក្សចុះខ្សោយខាងក្រោម-- ពីខាងក្រោម។ សូម្បីតែពួកស្តាំនិយម ក៏បានប្រើឧបាយកលបន្តមាគ៌ាឆ្វេងនិយមជ្រុលនេះដែរ ដើម្បីបំផ្លាញបក្ស”។ តើចំណុចនេះ មានន័យយ៉ាងម៉េចដែរ ដែលបានលើកឡើង ហើយ--

[១៤:០៥:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[១៤:០៥:០០]

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន ជម្រាបសួរលោកស្រីចៅក្រម។ ខ្ញុំសោកស្តាយដែលបានកាត់ការសួរសំណួរនេះ គាត់បានលើកនូវសម្រង់នៅក្នុងឯកសារ ហើយយើងមិនដឹងថាគាត់កំពុងតែសំដៅទៅដល់ឯកសារណាមួយទេ ព្រោះថាសាក្សីក៏មិនដឹង ហើយយើងជាភាគីហ្នឹងក៏មិនដឹងដែរ។ ដូច្នេះសូមឱ្យគាត់ផ្តល់លេខឯកសារឱ្យបានច្បាស់លាស់លោកប្រធាន។

[១៤:០៥:៤១]

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឱ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូម-- ពេលដែលលោកយោងទៅឯកសារពាក់ព័ន្ធនឹងការតាំងសំណួរ សូមលោកបង្ហាញនូវអត្តសញ្ញាណឯកសារ ព្រមទាំងលេខ ERN គឺសម្គាល់ទំព័រផង ប្រសិនបើចាំបាច់ត្រូវការឈានដល់ការសួរដេញដោលដោយផ្អែកលើខ្លឹមសារនៃទំព័រនៅក្នុងឯកសារនីមួយៗ នៅក្នុងឯកសារនីមួយៗនោះ។

**លោក ឡោ ជុនធី៖**

តាមពិតអម្បាញ់មិញ ខ្ញុំរកបន្ថែមឯកសារទៅហើយ។

**ប្រធានអង្គជំនុំ៖**

វាមិនអីចឹងទេ លោកត្រូវរៀបចំនូវការរបៀបតាំងសំណួរដោយយោងឯកសារ ដោយសារសូមភ្ជាប់បង្ហាញនូវអត្តសញ្ញាណឯកសារជាមុន មុននឹងដកស្រង់នូវខ្លឹមសារនៃឯកសារមកសួរ មិនមែន

ដកស្រង់រួចបានប្រាប់អំពីអត្តសញ្ញាណឯកសារនោះទេ។ វាដូច្នេះហើយបានជាមានការជំទាស់។

**លោក ឡៅ ជុនធី៖**

អរគុណ។ អត្តសញ្ញាណឯកសារគឺ IS19172-- IS19.172 លេខ ERN ខ្មែរ 00700069, ERN បារាំង 00703455, ភាសាអង់គ្លេស ERN 00078077។ គឺឯកសារដែលសម្ភាស អ៊ុង ចុងហឿង បាទ។

[១៤:០៨:០៨]

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** សូមអ្វីដែលខ្ញុំបានលើកអម្បាញ់មិញ តើលោកពូយល់ថាម៉េចដែរ?

**លោក នី កន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់សំណួរអម្បាញ់មិញ ខ្ញុំយល់មិនទាន់បានច្បាស់ទេ។ តើចង់សួរយ៉ាងម៉េច គឺសូមឲ្យលោកបញ្ជាក់ខ្ញុំម្តងទៀតបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឆ្នាំ១៩៧៨ តើលោកធ្លាប់បាននិយាយថា ហ្នឹងឃ្លាខ្ញុំសូមដក គឺថា៖ "មួយចំនួននៃកម្មាភិបាលបក្សបានបំផ្លាញមាគ៌ាបក្ស ហើយបានបន្តមាគ៌ាឆ្វេងនិយមជ្រុល និងបានធ្វើឲ្យបក្សចុះខ្សោយពីខាងក្រោម។ សូម្បីតែពួកស្តាំនិយម ក៏បានប្រើឧបាយកលបន្តមាគ៌ាឆ្វេងនិយមជ្រុលនេះដែរ ដើម្បីបំផ្លាញបក្ស"។ តើចំណុចនេះវាមានន័យយ៉ាងដូចម្តេច? សូមលោកពូអាចពន្យល់បានដែរឬទេ?

[១៤:០៩:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប មានការជំទាស់ពីមេធាវីការពារក្តីលោក អៀង សារី។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន មានពីរចំណុច។ ទីមួយ លោកមេធាវីបានបង្ហាញអត្តសញ្ញាណឯកសារហើយ ក៏ប៉ុន្តែអត់បានបញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ ដើម្បីឲ្យយើងខ្ញុំបានតាមដានទេ។ ទីពីរ លោកមេធាវីបានអះអាងថា ឯកសារនេះគឺជាឯកសារសម្ភាសរបស់លោក អ៊ុង ចុងហឿង ដែលលោក អ៊ុង ចុងហឿង អាចជាសាក្សីសក្តានុពលម្នាក់ដែរ ដែលខ្ញុំគិតថាតុលាការនឹងកោះអញ្ជើញហៅឡើងមក

ធ្វើសវនាការ ហើយលោកបានបញ្ចេញឈ្មោះគាត់ពេញជាផ្លូវការ ដែលតាមការពិតយើងគួរតែប្រើរបាស្សនាមទៅវិញទេ។ តើបទសម្ភាសរបស់សាក្សីរូបនេះ ត្រូវលើកយកមកឱ្យសាក្សីលោក នី កន អត្ថាធិប្បាយ ឬឆ្លើយឬទេ បើផ្អែកតាមវិធានដែលលោកប្រធានបានចេញមុនៗមក? ខ្ញុំគិតថា បើអនុញ្ញាតបែបនេះ គឺមិនសមរម្យ និងមិនត្រឹមត្រូវទេតាមវិធាន។ សូមអរគុណ។

[១៤:១១:០០]

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបង្ហាញជំហរ និងមូលហេតុនៃការជំទាស់របស់លោកឱ្យបានច្បាស់លាស់។ មិនមែនគ្រាន់តែលើកត្រួសៗអ៊ីចឹង ឱ្យទៅអង្គជំនុំជម្រះសម្រេចទេ។ លោកត្រូវលើកពីមូលហេតុនៃការជំទាស់របស់លោកឱ្យបានជាក់ច្បាស់ ដើម្បីឈានដល់ការសម្រេច។ ហើយមេធាវីគេបានលើកឡើងហើយអត្តសញ្ញាណឯកសារ ហើយអង្គជំនុំជម្រះបង្អង់បន្តិចរង់ចាំមើលការតវ៉ា និងជំទាស់ពីភាគីដែលពាក់ព័ន្ធ មុននឹងអង្គជំនុំជម្រះឈានដល់ការសម្រេច។ ពីព្រោះមិនមែនមានតែអង្គជំនុំជម្រះទេដែលត្រូវសម្រេចអំពីបញ្ហាថាត្រូវឱ្យសួរ ឬក៏មិនឱ្យសួរ ឬក៏ឱ្យសាក្សីឆ្លើយ ឬក៏មិនឆ្លើយនោះ។ ភាគីមានសិទ្ធិជំទាស់តវ៉ាទៅនឹងការតាំងសំណួរឯណា ដែលវាមិនត្រឹមត្រូវតាមច្បាប់។

[១៤:១១:៤៨]

**លោក អាង ឧត្តម៖**

សូមអរគុណ ហើយសូមៗអភ័យទោសផង។

ខ្ញុំលើកបែបនេះក្នុងគោលបំណងដើម្បីសូមជំទាស់នឹងការលើកឯកសារនេះ មកសួរសាក្សី។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាសម្រេច សម្រេចតាមការជំទាស់របស់ខ្ញុំបាទ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ ដើម្បីភាគីដែលពាក់ព័ន្ធគេអាចលើកឡើង ឬក៏គេធ្វើការតបវិញ។

[១៤:១២:២០]

**លោក អាង ឧត្តម៖**

សូមៗលើកសាថ្មី។ ទីៗមួយ គឺសម្ដីដែលលោកមេធាវីលើកមកថ្លែងនេះ គឺជាកិច្ចសម្ភាសរបស់

សាក្សីម្នាក់ ដោយសារតែគាត់បាននិយាយឈ្មោះហើយ ខ្ញុំសូមនិយាយតាមតតាមក្រោយ គឺលោក អ៊ុង ចុងហឿង។ ខ្ញុំមិនដឹងថា កិច្ចសម្ភាសរបស់លោកសាក្សី អ៊ុង ចុងហឿង អីមាននៅក្នុងសំណុំរឿងហើយ ហើយមាននៅក្នុងបញ្ជីដែលតុលាការ ប្រហែលអាចជាគ្រោងយកមកសួរដេញដោលផង។ ថាតើកិច្ចសម្ភាសបែបនេះ បើផ្អែកតាមវិធានដែលលោកប្រធានបានចេញលើកមុននោះ គឺថាចំពោះកិច្ចសម្ភាសទាំងឡាយណា របស់សាក្សីណាដែលនឹងឡើងមកឆ្លើយនៅពេលអនាគត នឹងមិនត្រូវឲ្យសាក្សីបច្ចុប្បន្នធ្វើសេចក្តីថ្លែង ពន្យល់ ឬអត្ថាធិប្បាយទៅលើទេ។ គឺធ្វើបែបនេះ គឺមិនត្រឹមត្រូវ ហើយខុស។

អាស្រ័យហេតុនេះ បានជាយើងខ្ញុំសូមជំទាស់មិនឲ្យលើកឯកសារនេះមកសួរសាក្សីរូបនេះ។ សូមអរគុណ។

[១៤:១៣:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ដើម្បីបំពេញបន្ថែមទៅនឹងការជំទាស់របស់សហភាតារបស់ខ្ញុំ ខ្ញុំចង់ត្រឡប់មកនិយាយអំពីការធ្វើ ការជំទាស់នេះ ខ្ញុំនិយាយអំពីការរៀបចំសំណួររបស់សហមេធាវីនាំមុខ គឺគាត់បានលើកឯកសារ ហើយគាត់បាននិយាយថា វាជាសម្រង់របស់-- ជាសម្រង់នៃឯកសារ។ ហើយនៅពេល-- ហើយបន្ទាប់មកបានបង្ហាញឯកសារ។ ដូច្នេះខ្ញុំគិតថា ជាសំខាន់ត្រូវតែបញ្ជាំងឯកសារនេះមុន។ តាមពិតទៅវាមិនមែនជាកិច្ចសម្ភាសលោក នី កន ទេ ប៉ុន្តែគឺជាកិច្ចសម្ភាសលោក អ៊ុង ចុងហឿង។ ដូច្នេះនៅក្នុងលក្ខខណ្ឌនេះ ដើម្បីជាយុត្តិធម៌ចំពោះសាក្សីនោះ សូមឲ្យផ្តល់ឯកសារឲ្យគាត់ ហើយសូមឲ្យគាត់ពិនិត្យមើល ដើម្បីឲ្យគាត់ដឹង។ ថានេះជាសម្តីរបស់គាត់ ឬក៏មិនមែន ហើយដែលជាសម្តីរបស់គាត់ ប៉ុន្តែនិយាយដោយអ្នកផ្សេងទៀតនោះ។ នេះជាការបំពេញបន្ថែមទៅលើការជំទាស់របស់សហភាតារបស់ខ្ញុំ។

[១៤:១៤:៥៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:១៥:០១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ពាក់ព័ន្ធទៅនឹងឯកសារដែលបានលើកនេះ ខាងមេធាវីនាំមុខ ក៏ដូចជាមេធាវីដែលបានលើកនេះ ចាប់អារម្មណ៍ថា ឯកសារនេះគឺជាឯកសាររបស់បុគ្គលផ្សេង ជាកិច្ចសម្ភាសទៅលើបុគ្គលផ្សេង ដូច្នេះហើយជាករណីមួយ ដែលវិធានមិនអនុញ្ញាតឲ្យខាងយើងខ្ញុំធ្វើយ៉ាងដូច្នោះ នៅក្នុងការបង្ហាញឯកសារនោះទៅដល់សាក្សីផ្សេងនោះទេ។ យើងបានចាប់អារម្មណ៍ពីចំណុចនេះ ដូច្នេះហើយបានជាយើងមិនធ្វើដូចជាករណីដែលលោក លោកស្រីមេធាវីខាងការពារក្តីទាំងពីរបានលើកនោះ។ ក៏ប៉ុន្តែអ្វីដែលយើងស្នើសុំហើយ ដែលនៅក្នុងវិធានមិនហាមឃាត់នោះ គឺជាការដកស្រង់ខ្លឹមសារតែប៉ុណ្ណោះនូវឯកសារ ដើម្បីលើក ដើម្បីឲ្យសាក្សីដែលមានវត្តមានទីនេះមានការចាប់អារម្មណ៍ និងធ្វើការអធិប្បាយតែប៉ុណ្ណោះ។ គឺមិនដកស្រង់ឃ្លាទេ ក៏ប៉ុន្តែគ្រាន់ជាការដកស្រង់ខ្លឹមសារតែប៉ុណ្ណោះ ដូច្នេះករណីនេះ តាមវិធានដែលកន្លងមក ដែលសម្រេចដោយលោក លោកស្រីចៅក្រម មិនចោទជាបញ្ហាឡើយ។

[១៤:១៦:១៩]

ហើយ បាទ ដូច្នេះ-- ហើយចំពោះបញ្ហាដែលនិយាយអំពីឈ្មោះរបស់សាក្សីនេះទៀតសោតតាមការពិតដោយសារឯកសារ ឈ្មោះនេះគឺជាឈ្មោះរបស់ឯកសារ ដូច្នេះហើយលោក ជុនធី មិនបាន-- ត្រូវតែលើកពីឈ្មោះនេះ ក៏ប៉ុន្តែអ្នកដែលនិយាយថា ឈ្មោះនេះគឺជាសាក្សី គឺជាខាងមេធាវីរបស់ជនជាប់ចោទទេ ដែលលើកថាជាឈ្មោះរបស់សាក្សីដែល-- ជា នេះជាការដែលថាបញ្ជាក់ឲ្យឃើញថា បុគ្គលនោះ គឺជាសាក្សីដែលធ្វើឲ្យមានការប៉ះពាល់ទៅដល់ឈ្មោះ អឺ! ភាពជាសម្ងាត់ទៅលើ-- នៃឈ្មោះរបស់សាក្សីទៅវិញ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមឆ្លើយតបទៅនឹងការបកស្រាយរបស់តំណាងមេធាវីនាំមុខរដ្ឋប្បវេណី។ ខ្ញុំយល់ថា លោកប្រហែលជាមានការភ័ន្តច្រឡំ ទៅលើការប្រើប្រាស់ខ្លឹមសារ និងការបង្ហាញឯកសារ។ ការប្រើប្រាស់ខ្លឹមសារ គឺអាចធ្វើទៅបាន ក៏ប៉ុន្តែនៅពេលដែលភាគីលើកយក

ឯកសារជាក់លាក់យកមកប្រើប្រាស់ ដើម្បីតទល់ទៅនឹងសាក្សីមួយផ្សេងទៀត អាហ្នឹងមិនអាចធ្វើទៅបានទេ បើតាមបទប្បញ្ញត្តិដែលយើងបានទទួលកន្លងមកនេះ។ បាទ សូមអរគុណ។

[១៤:១៧:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២២:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ បន្ទាប់ពីស្តាប់នូវការជំទាស់តវ៉ារបស់មេធាវីការពារក្តី លើការតាំងសំណួរចុងក្រោយរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសម្រេចថា ទីមួយគឺ នឹងរំឭកផងថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងភាគីដទៃទៀត ឲ្យមានការប្រុងប្រយ័ត្នខ្ពស់នៅក្នុងការប្រើនូវនាម គោត្តនាម និងនាមផ្ទាល់របស់សាក្សីសក្តានុពលនានា ដែលអង្គជំនុំជម្រះមានបំណងនៅក្នុងការកោះអញ្ជើញគាត់មកផ្តល់សក្ខីកម្មនាពេលអនាគត ឲ្យមានការត្រៀមសិក្សា ត្រៀមលក្ខណៈសម្បត្តិលើបញ្ហាអនុវត្តបែបនេះជាមុន មុននឹងការលើកយកមកឯកសារដែលពាក់ព័ន្ធក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនៅក្នុងសវនាការសាធារណៈនេះ។ ហើយបញ្ហាទីពីរ គឺសូមឲ្យមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី បន្តការតាំងសំណួរថ្មីទៀតចំពោះសាក្សីរូបនេះ។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សំណួររបស់ខ្ញុំ ដែលពាក់ព័ន្ធនឹងក្រសួងការបរទេសបន្ថែមបន្តិចទៀត អ្វីដែលខ្ញុំចង់ដឹងនោះគឺថា នៅពេលដែលអ៊ំធ្វើការឃោសនាអប់រំនៅក្នុងក្រសួងការបរទេស ហើយនៅពេលនោះគឺមានក្មេងៗប្រហែលជា៥០នាក់ ដែលត្រូវអ៊ំធ្វើការបណ្តុះបណ្តាលដែរ។ ខ្ញុំចង់ដឹងថាតើបណ្តុះបណ្តាលក្មេងហ្នឹងទៅលើអ្វីខ្លះដែរ?

[១៤:២៤:៥៤]

**លោក នី កន៖**

**ស៖** បាទ ខ្ញុំជម្រាបថា ក្មេងប្រហែល៥០នាក់។ ហើយដែលខ្ញុំចូលរួមបណ្តុះបណ្តាលនោះ គឺបណ្តុះបណ្តាលខាងអក្សរខ្មែរ និងលេខ។ ឯផ្នែកទទួលខុសត្រូវខាងបណ្តុះបណ្តាលខាងអប់រំសតិ

អារម្មណ៍អីៗនោះ គឺមានផ្នែកគេដោយឡែកទៀត។ ខ្ញុំមានតែប៉ុណ្ណឹងទេបាទ។

**ស៖** តើនៅក្នុងពេលដែលអ៊ំធ្វើការនៅក្រសួងការបរទេសហ្នឹងថា តើអ៊ំបានជួបលោក អៀង សារី ជាញឹកញាប់ដែរអត់ទេ?

**ឆ៖** បាទ ដូចបានជម្រាបបន្តបន្ទាប់ គឺមិនបានជួបញឹកញាប់ទេ។ ជួបភាគច្រើន តាមពេលដែលទទួលគណៈប្រតិភូ ហើយចូលរួមអមដំណើរជាក្បួនទ្បាន ក្បួនអីប៉ុណ្ណឹងបាទ។

**ស៖** បាទ អរគុណ។ ចំណុចមួយដែលខ្ញុំបានឮដែរ គឺថាមានការអនុវត្តនូវគោលនយោបាយឯករាជ្យ។ ខ្ញុំចង់ដឹងថា តើអាគោលនយោបាយឯករាជ្យហ្នឹង វាយ៉ាងម៉េច? វាជាគោលនយោបាយអនុវត្តយ៉ាងម៉េច? ហើយដែលថាឯករាជ្យនោះបាទ?

[១៤:២៦:៥១]

**ឆ៖** សូមឆ្លើយបាទ។ បកស្រាយនូវគោលនយោបាយឯករាជ្យ នេះជាការបកស្រាយបន្តគ្នា ហើយទៅតាមលទ្ធភាពនៃការយល់ដឹង។ ន័យរបស់វាគឺថាដូចជា ដាំបន្លែហូបខ្លួនឯង កុំបាច់ទិញពីគេ។ ដូចជា ដាំអំពៅ រម្ងាស់ស្ករ ហូបខ្លួនឯងដើម្បីកុំទិញពីគេ។ បាទ អាហ្នឹងនយោបាយដែលខ្ញុំយល់គឺប៉ុណ្ណឹង ឯករាជ្យ។

**ស៖** ចុះថា តើអ្វីដែលរចនាសម្ព័ន្ធទំនាក់ទំនងការងារនៅក្នុងក្រសួងការបរទេសហ្នឹង តើអ៊ំមានការទំនាក់ទំនងហ្នឹងតាមរយៈយ៉ាងម៉េច? ដូចថាអ៊ំត្រូវចុះទៅធ្វើការហើយ ត្រូវរាយការណ៍ទៅនរណា? ត្រូវរាយការណ៍ទៅមេបន្ទាប់ មេបន្ទាប់នោះ ឬមួយយ៉ាងម៉េច ប្រព័ន្ធនៃការរាយការណ៍?

**ឆ៖** បាទ បានជម្រាបបន្តបន្ទាប់ ហើយលើកនេះក៏សូមជម្រាបបន្ថែម។ គឺខ្ញុំរាយការណ៍តាមប្រធានមន្ទីរ គឺលោក ជាម បាទ។

**ស៖** ដោយសារអ៊ំបានចូលធ្វើបដិវត្តន៍យូរ ហើយខ្ញុំចង់ដឹងថា តើការបង្កើតនូវសហករណ៍ឃុំស្រុក ឬតំបន់ ឬភូមិភាគហ្នឹង វាជាការគ្រប់គ្រងនៅរដ្ឋបាលមួយ។ សួរថា តើការគ្រប់គ្រងដោយរដ្ឋបាលហ្នឹង វាជាបែបយ៉ាងម៉េច? បែបជាប្រធានមួយ ឬមួយជាគណៈមួយ? តាំងពីសហករណ៍រហូតទៅដល់តំបន់ ដល់ភូមិភាគបាទ?

[១៤:២៨:១៦]

**ឆ៖** សូមឆ្លើយ ក្នុងពេលដែលខ្ញុំនៅខាងមូលដ្ឋាន។ សហករណ៍ហ្នឹងគឺឃើញថានៅក្រោមការគ្រប់គ្រងរបស់សាខាឃុំ ហើយសហករណ៍មួយៗនោះ គេមានគណៈសហករណ៍របស់គេ។ ដូច្នេះ

សហករណ៍នៅក្រោមឃុំ ឃុំនៅក្រោមស្រុក ហើយបន្តទៅ ទៅលើបាទ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមសួរពាក់ព័ន្ធនឹង-- កាលពីព្រឹកមិញ ខាងលោកសហព្រះរាជអាជ្ញា បានបង្ហាញឯកសារដែលពាក់ព័ន្ធនឹងអ្នកកាសែត។ ហើយចង់ដឹងថា តើអ្នកកាសែតទាំងបីនាក់ហ្នឹង គាត់ ពេលដែលគាត់អញ្ជើញមកជួបហើយ គាត់ចង់ចុះទៅខេត្ត ចុះអីនេះ សួរថាពេលដែលគាត់ចង់ចុះ ទៅ តើគាត់បានទៅដែរអត់? ទីមួយ។ ទីពីរ អ្វីដែលគាត់បានទៅហើយ តើគាត់បានវិលត្រឡប់ទៅស្រុក ទេសគាត់វិញ ឬមួយយ៉ាងម៉េច? តើលោក-- លោកអ៊ំបានដឹងដែរអត់ទេ?

**ឆ៖** សូមបញ្ជាក់ជូន សំណូមពររបស់អ្នកកាសែតពេលនោះ ខ្ញុំចាំមិនអស់ទេ តែតាមខ្ញុំមើល ដូចមិនបានតាមសំណូមពរអីទាំងអស់ទេ។ ហើយទីពីរ ធម្មតាក្នុងគណៈប្រតិភូមួយៗ តែគេចប់បេសក-- ចប់ការទស្សនកិច្ចរបស់គេហើយ គេត្រូវទៅស្រុកវិញហើយបាទ។

**ស៖** បាទ អរគុណ។ ខ្ញុំសូមចូលទៅថា ពាក់ព័ន្ធនឹងរឿងជម្លៀស។ លោកអ៊ំបានលើកឡើងថា នៅថ្ងៃ១៧ មេសា លោកអ៊ំបានចូលមកក្នុងក្រុងភ្នំពេញវិញ ហើយត្រឡប់ទៅវិញទាំងយប់។ ខ្ញុំចង់ដឹង ថា តើម៉េចបាន គ្រាន់តែចូលមកអើតហើយ ទៅវិញហ្នឹង មានបេសកកម្មយ៉ាងម៉េច?

[១៤:៣២:១០]

**ឆ៖** បេសកកម្មពេលហ្នឹង មិនច្បាស់លាស់ទេ។ គឺខ្ញុំអ្នកនៅក្រោយកងទ័ព ហើយជាអ្នក ឃោសនា អប់រំ។ ដល់ឮថា បានជ័យជម្នះហើយ ទាំងអស់គ្នាចេះ តែចុះសម្រុកចូលទៅមើលទៅ។ ចូល ទៅមើលហើយ ខ្ញុំមិនមែនតួនាទីអ្នកគ្រប់គ្រងសមរភូមិដែលបានឈ្នះនោះទេ។ ដូច្នេះ ខ្ញុំគ្មានតួនាទីអី នៅនុ៎ងទេ ត្រូវតែមកមូលដ្ឋានវិញ។ ឯអ្នកមានតួនាទីនៅកន្លែងនោះ គឺកងទ័ពដែលគ្រប់គ្រង ហើយគេ គ្រប់គ្រងក្នុងសភាពដែលប្រុងជើងការ មិនទាន់ប្រាកដថា តើឈរជើងបាន ឬមិនបានទេបាទ?

**ស៖** សូមភ្ជាប់បន្តិច តើលោកឃើញ ពេលដែលចូលមកហ្នឹង ឃើញព្រឹត្តិការណ៍អីខ្លះ ដែល កើតឡើង?

**ឆ៖** សូមបញ្ជាក់សំណួរ តើលោកចង់សួរថា ខ្ញុំចូលទៅឃើញបញ្ហាអីខ្លះនៅក្នុងក្រុងបាទ? ខ្ញុំចូលទៅឃើញកងទ័ពដែល របស់លន់ នល់ ដែលចាញ់សង្គ្រាមហើយនុ៎ង ដឹកកាំភ្លើងទៅ ដឹងកាំភ្លើង មក តាមស៊ីក្លូ យកមកប្រគល់ឲ្យកងទ័ពដែលវ៉ៃចូល។ ហើយក្រៅពីនុ៎ង ឃើញតែប្រជាជនដើរទៅ ដើរមក មិនទាន់មានការប្រកាសថាចេញ មិនចេញទេបាទ។

[១៤:៣៤:១០]

**ស៖** អរគុណ។ សំណួរខ្ញុំ សំណួរចុងក្រោយ គឺថាប្រព័ន្ធនៃការគ្រប់គ្រងលំដាប់ថ្នាក់លើ និងថ្នាក់ក្រោម។ ខ្ញុំចង់ដឹងថា តើរាល់ការងាររបស់អ៊ំដែលថ្នាក់លើ ថ្នាក់ក្រោម និងទំនាក់ទំនងជាមួយថ្នាក់លើ។ រាល់ការងាររបស់អ៊ំថ្នាក់ក្រោម តើថ្នាក់លើគេដឹងទាំងអស់ ឬមួយយ៉ាងម៉េច?

**ឆ៖** នេះចូលក្នុងការសន្និដ្ឋានរបស់ខ្ញុំ។ ធម្មតាខ្ញុំថ្នាក់ក្រោមត្រូវគោរពថ្នាក់បន្តពីខ្ញុំ ឯថ្នាក់បន្តពីខ្ញុំគេយកបន្តទៅខាងថ្នាក់លើ។ ឯខ្លឹមសារដែលគេយកទៅបន្តនោះ តើគ្រប់គ្រាន់ ឬមិនគ្រប់គ្រាន់ ខ្ញុំមិនដឹងដែរ។ ពីព្រោះវាទាក់ទងនឹងសមត្ថភាពរបស់ថ្នាក់ពីលើខ្ញុំបាទ។

[១៤:១៥:២១]

**លោក ឡោ ជុនធី៖**

លោកប្រធាន បាទ អស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកដែរហើយ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៥ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់ជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋ-- ដែលទទួលសិទ្ធិ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិពីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក បាណាបេ ណេគ្វី៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រមទាំងអស់ ជម្រាបសួរសហភាតា ជម្រាបសួរសាធារណជននៅសាលសាធារណៈ។

ជម្រាបសួរលោកសាក្សី! លោកស្តាប់ខ្ញុំឮទេ លោកសាក្សី?

**លោក នី កន៖**

ស្តាប់ឮបាទ។

**សួរដោយលោក បាណាបេ ណេគ្រី៖**

សូមអរគុណ។ ខ្ញុំមិនទទួលបានការបកប្រែទេ ក៏ប៉ុន្តែខ្ញុំគិតថាលោកបានឆ្លើយថាលោកស្តាប់ឮហើយ។

**ស៖** លោកសាក្សី ខ្ញុំនឹង-- ខ្ញុំសូមណែនាំខ្លួនសិន ខ្ញុំឈ្មោះ បាណាបេ ណេគ្រី ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់ផ្តោតទៅលើផ្នែកដំបូង ពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់គណៈប្រតិភូជប៉ុនដែលលោកបាននាំទៅសៀមរាបនៅឆ្នាំ៧៨។ លោកបានលើកឡើងរួចមកហើយកាលពីព្រឹកមិញជាមួយនឹងលោកសហព្រះរាជអាជ្ញា។ តើលោកមានចាំពីចំណុចនេះទេ?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន ខ្ញុំចាំនូវខ្លឹមសារខ្លះៗទេ ចាំមិនបានអស់ទេ។

**ស៖** សូមអរគុណ។ តើលោកដឹងទេថា ទស្សនកិច្ចនេះគឺប្រព្រឹត្តទៅនៅខែធ្នូ ឆ្នាំ១៩៧៨ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំមិនចាំច្បាស់ទេ។

[១៥:០១:៤១]

**ស៖** ខ្ញុំយល់លោកហើយ ប៉ុន្តែបើយោងទៅលើឯកសារដែលខាងសហព្រះរាជអាជ្ញាបានបង្ហាញជូននោះគឺនៅពេលនុ៎ងហើយ។ សំណួររបស់ខ្ញុំនោះ គឺចង់ដឹងថាតើលោកចាំទេនៅពេលនុ៎ង មានសង្គ្រាមគឺថាសង្គ្រាមប្រឆាំងនឹងវៀតណាម? តើលោកចាំទេអំពីសង្គ្រាមវៀតណាមកំពុងតែវ៉ៃចូលនោះ?

**ឆ៖** សូមឆ្លើយ សង្គ្រាមដែលវៀតណាមវ៉ៃចូលនោះ គឺខ្ញុំចាំមិនច្បាស់ទេ តែការទទួលព័ត៌មានពីថ្នាក់លើថាមានការចាប់ផ្តើមវ៉ៃលុកចូលហើយ ហើយចំណុចណាអីណាច្បាស់លាស់អត់មានបញ្ជាក់ច្បាស់លាស់ទេ។ ដូច្នេះខ្ញុំចាំបានប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណលោកសាក្សី។ ក្នុងក្របខ័ណ្ឌនៃសង្គ្រាមជាមួយវៀតណាមនេះ ខ្ញុំសូមឲ្យលោករម្លឹកឲ្យចងចាំពីអ្វីដែលបានកើតឡើង។ តើលោកបានដឹងទេថា ក្នុងពេលដែលវៀតណាមវ៉ៃចូលនោះគឺថាមានៗយុទ្ធនាការជាអន្តរជាតិក្នុងការបង្កាច់បង្ខូចឈ្មោះកម្ពុជាប្រជាធិបតេយ្យនៅលើឆាកអន្តរជាតិ

ថាជារបបប្រល័យពូជសាសន៍។ តើលោកមានបានដឹងពីចំណុចនេះទេ?

[១៥:០៣:៣១]

**ឆ៖** ក្របខ័ណ្ឌខ្ញុំអ្នកទទួលតួនាទីខាងពិធីការ ខ្ញុំមិនបានដឹងទេ តែបើក្របខ័ណ្ឌអ្នកខាងទទួលតួនាទីខាងព័ត៌មាន ខាងឃោសនាការអីផ្សេងៗនៅក្នុងក្រសួង គេដឹង តែខ្ញុំអត់ដឹងទេ។

**ស៖** សូមអរគុណ។

**លោក បាណាបេ ណេគ្វី៖**

ដើម្បីរម្លឹកការចងចាំរបស់លោកសាក្សី ខ្ញុំចង់ដាក់សម្រង់ឯកសារមួយដែលសហព្រះរាជអាជ្ញាបានបង្ហាញជូនលោករួចហើយកាលពីព្រឹកមិញនេះ គឺឯកសារលេខ D108/28.318 ERN ពាក់ព័ន្ធគឺ 00-- សូមទោស គឺ S0013189 ជាភាសាអង់គ្លេស ហើយជាភាសាខ្មែរ S00870127 ជាភាសាបារាំង ERN S00793502។

នេះគឺជាសម្រង់មួយដែលដកចេញមកពីអត្ថបទសារព័ត៌មានភ្នំពេញ។ ហើយដែលក្នុងនោះ គឺមានការចុះផ្សាយកិច្ចសម្ភាសន៍របស់ប្រធានគណៈប្រតិភូជប៉ុននៅពេលចុងបញ្ចប់ទស្សនកិច្ច។

ខ្ញុំសូមអាននូវសម្រង់នេះ។ សូមដកស្រង់នូវសំណួរមួយដែលបានសួរទៅកាន់គណៈប្រតិភូ។

[១៥:០៥:៤៤]

លោកប្រធាន តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបញ្ចាំងឯកសារនេះនៅលើអេក្រង់ដែរឬទេ? ហើយខ្ញុំអាចផ្ដល់ជូនឯកសារជាភាសាខ្មែរទៅឲ្យសាក្សី ដើម្បីឲ្យគាត់អាចអានឯកសារនេះបាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

[១៥:០៦:២១]

**សួរដោយលោក បាណាបេ ណេគ្វី៖**

សូមអរគុណលោកប្រធាន។ លោកសាក្សី លោកមានឯកសារហើយ ខ្ញុំសូមអាននូវសម្រង់នៃសំណួរដែលបានចោទសួរទៅកាន់ឯកឧត្តម កូហ្សូ ហ្សាសាគី (Kozo Sasaki) គឺនៅកថាខណ្ឌទី៣នៃអត្ថបទជាភាសាបារាំង៖ “អ្នកឈ្លានពានវៀតណាម វាទទីនិយម និងចក្រពត្តិនិយមអន្តរជាតិកំពុងផ្សព្វផ្សាយឃោសនាបង្កាច់បង្ខូច ដោយនិយាយថារដ្ឋាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យកំពុងនៅឯកោ

ព្រោះប្រជាជនប្រឆាំងនឹងខ្លួន។ ហើយមានការរំដើបរំជួលពាសពេញប្រទេសកម្ពុជា ហើយនិងថាគ្មានការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ព្រមទាំងថាប្រជាជនក្នុងប្រទេសកម្ពុជាកំពុងត្រូវគេសម្លាប់រង្គាល។ ដោយឥឡូវនេះ អ្នកបានមកដល់កម្ពុជាប្រជាធិបតេយ្យអស់រយៈពេលពីរសប្តាហ៍មកហើយ។ តើលោកគិតយ៉ាងណាចំពោះការឃោសនានេះ?"។ នេះគឺជាសំណួរសួរទៅកាន់ប្រធានគណៈប្រតិភូ ខ្ញុំនឹងអានចម្លើយទេ ប៉ុន្តែខ្ញុំសួរចង់បានចម្លើយពីលោក។

**ស៖** បើតាមលោកចាំ លោកសាក្សី តើនេះគឺជាព័ត៌មានផ្លូវការដែលត្រូវបានគេស្គាល់នៅក្នុងក្រសួងការបរទេសនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលលោកធ្វើការនៅទីនោះ? គឺមានន័យថា ពីការឃោសនារបស់វៀតណាម។

[១៥:០៨:២១]

**លោក នី កន៖**

**ឆ៖** សូមឆ្លើយបញ្ជាក់ជូន។ ខ្លឹមសារនេះ ខ្ញុំមិនចាំទេ តែតាមមើលខ្លឹមសារនេះ ជ្រាលជ្រៅដែរ។ អាចជាអ្នកពាំនាំខ្លឹមសារនេះ គឺជាអ្នកនៅខាងផ្នែកឃោសនាការ។ ដូច្នេះ ខ្ញុំបញ្ជាក់ជូនបានប៉ុណ្ណឹង ហើយទីពីរ ផ្នែកកាសែត ធម្មតាផ្នែកកាសែត តាមខ្ញុំមានពិសោធខ្លះៗ ច្រើនតែមិនសុក្រឹត្យទេ ការសរសេរ ការនិយាយ ទាំងអ្នកដែលធ្វើសម្ភាសន៍មានសមត្ថភាពមិនគ្រប់គ្រាន់ យល់ដឹងមិនគ្រប់គ្រាន់ ឬក៏ប្រហែស គឺច្បាស់ជាសរសេរលើស ឬបំផ្លើសហើយ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់សរុបថា ខ្ញុំចាំមិនអស់ ហើយតាមមើលខ្លឹមសារនេះ មិនអាចក្របខ័ណ្ឌខ្ញុំទេបាទ។

**ស៖** សូមអរគុណ។ លោកសាក្សី ដោយសារតែអ្នកជាអ្នកជូនដំណើរគណៈប្រតិភូនេះ ខ្ញុំសូមអានទូវចម្លើយរបស់ប្រធានគណៈប្រតិភូនៅពេលនោះ ដែលគាត់បាននិយាយថា បន្ទាប់ពីចម្លើយនោះមក-- បន្ទាប់ពីសំណួរ គាត់បានឆ្លើយថា៖ "យើងមិនឃើញមានការសម្លាប់រង្គាលណាទេ ប្រជាជនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគនៅជនបទ។ យើងបានឃើញសត្វពាហនៈរាប់ពាន់ក្នុងសហករណ៍ជាច្រើន។ ប្រសិនបើប្រជាជនកម្ពុជាខ្វះស្បៀង ពួកគេនឹងសម្លាប់សត្វពាហនៈទាំងអស់នោះ ដើម្បីយកសត្វ។ ដូច្នេះព័ត៌មានអំពីប្រជាជនកម្ពុជា ដែលឆ្លងកាត់ការខ្វះខាតស្បៀងនោះ គឺជាការបោកប្រាស់ថ្មីមួយរបស់ជនជាតិវៀតណាម។ យើងត្រូវតែកម្ទេចការឃោសនាបោកប្រាស់នេះ។ អ្នកមិនបានលាក់បាំងអ្វីពីយើងទេ អំឡុងទស្សនកិច្ចរបស់យើង។ យើងបានឃើញស្ថានភាពពិតក្នុងប្រទេសកម្ពុជាប្រជាធិប-តេយ្យ"។ សំណួររបស់ខ្ញុំគឺថា បើតាមលោកចាំ តើរបាយការណ៍ដែលធ្វើឡើងដោយប្រធានគណៈប្រតិភូ

នេះត្រូវគ្នានឹងអ្វីដែលលោកបានឃើញនៅក្នុងអំឡុងពេលទស្សនកិច្ចរបស់ពួកគាត់នៅកម្ពុជាដែរឬទេ?

[១៥:១១:២៨]

**ឆ៖** សូមជម្រាបជូន ខ្លឹមសាររបស់ប្រធានគណៈប្រតិភូជប៉ុនដែលបានលើកឡើងនៅពេលនេះ ខ្ញុំចាំមិនអស់ទេ ពីព្រោះកិច្ចសន្ទនាតាមឡាន តាមពាក្យសម្ដី។ ដូច្នោះខ្ញុំចាំមិនអស់ទេ តែថ្ងៃនេះបានឃើញខ្លឹមសារនេះជាលាយលក្ខណ៍អក្សរ ខ្ញុំមានការនឹកឃើញខ្លះៗក្នុងក្របខ័ណ្ឌជាគណៈប្រតិភូ-- គណៈប្រតិភូគេតែងសរសើរអ៊ីចឹងហើយ ទីមួយ។ តែទីពីរ ការពិតជាក់ស្ដែងដែលគណៈប្រតិភូនោះទៅជាមួយខ្ញុំនោះតាមឡាននោះ គាត់មិនបានឃើញអីដែល ដែលគាត់និយាយនេះទេ គឺគាត់ឃើញកម្រិតប៉ុណ្ណឹង។ ឃើញគោ ឃើញក្របីអីតាមផ្លូវ ឃើញប្រជាជន ដឹកគោ ដឹកក្របីអីអ៊ីចឹងទៅ។ ហ្នឹងបញ្ហានេះពិត បាទ។

[១៥:១៣:០១]

**ស៖** សូមអរគុណចំពោះចម្លើយនេះលោកសាក្សី។ កាលពីព្រឹកមិញនេះរូបលោកបានប្រាប់អង្គជំនុំជម្រះថា អ្វីដែលលោកត្រូវធ្វើនោះ គឺថានិយាយអំពីជ័យជម្នះដែលទទួលបាន លោកនិយាយថាលោកមានមោទនភាពចំពោះជ័យជម្នះ។ តើនេះជាការសង្ខេបនូវចម្លើយរបស់លោកដែលបានឆ្លើយទៅកាន់សហព្រះរាជអាជ្ញានៅពេលព្រឹកមិញនេះដែរទេ?

**ឆ៖** សូមឆ្លើយ ជាធម្មតាក្នុងកិច្ចដំណើរការអ្វីមួយ ឬក្នុងការចូលរួមចលនាអ្វីមួយ បើកាលណាឃើញថាបានជ័យជម្នះហើយ ក៏អរហើយបាទ។ ដូច្នេះខ្ញុំបញ្ជាក់នេះ ក្នុងទស្សនៈគោលជំហរខ្ញុំពេលនុ៎ង ខ្ញុំអរ ខ្ញុំរីករាយដូចបងប្អូនមហាជនទូទៅដែលនៅជិតគ្នា ទាំងកងទ័ព ប្រជាជនអីហ្នឹងក៏អបអរសាទរបាទ។

[១៥:១៤:២៦]

**ស៖** សូមអរគុណលោកសាក្សី។ កាលពីម្សិលមិញនេះ លោកឆ្លើយថា លោកបានទទួលស្គាល់ហើយព្រឹកមិញក៏លោកទទួលស្គាល់ដែរ ថាលោកខ្លួនឯងផ្ទាល់ លោកកត់សម្គាល់ឃើញថាប្រជាជនហូបចុកមិនគ្រប់គ្រាន់។ នៅរសៀលនេះក៏លោកនិយាយអ៊ីចឹងម្ដងទៀតដែរ ថាប្រជាជនហូបចុកមិនគ្រប់គ្រាន់ តើលោកនៅរក្សាចម្លើយនេះទេ?

[១៥:១៤:៥៨]

**ឆ៖** បាទ ខ្ញុំឃើញយ៉ាងម៉េច ខ្ញុំថាអ៊ីចឹង។ ការយល់របស់ខ្ញុំយ៉ាងម៉េច ខ្ញុំថាអ៊ីចឹង។ ពីព្រោះអីពីព្រោះខ្ញុំយល់ ដូចបានខ្ញុំជម្រាប ឬអធិប្បាយខ្លះៗជូនថា យ៉ាងណាក៏មិនគ្រប់គ្រាន់ដែរ ពីព្រោះអ្នកចាស់

ខ្វះខាតទៅហើយ ហើយអ្នកថ្មីមកទាំងអាចថាលាន មកផ្ទុកចូលទៀត ដូច្នេះមិនគ្រប់ទេ។ ដូច្នោះ ការចាប់អារម្មណ៍ កត់សម្គាល់របស់ខ្ញុំ ខ្ញុំនៅតែរក្សាទុកអ៊ីចឹងដដែលបាទ។

**ស៖** សូមអរគុណលោកសាក្សី។ តើជាការត្រឹមត្រូវដែរឬទេ លោកសាក្សីក្នុងការសន្និដ្ឋានថា ព័ត៌មានដែលក្រសួងការបរទេសផ្តល់ជូនឱ្យអ្នកផ្សេង ស្តីអំពីស្ថានភាពរបស់ប្រជាជននោះ គឺវាមិនស្របទៅនឹងការពិតទេ ហើយក្រសួងខ្លួនឯងនេះក៏ដឹងដែរថា ព័ត៌មានហ្នឹងមិនត្រឹមត្រូវ។ តើនេះជាការសន្និដ្ឋាននូវអ្វីដែលលោកឆ្លើយដែរឬទេ?

[១៥:១៦:៤៥]

**ឆ៖** ការឆ្លើយបញ្ជាក់របស់ខ្ញុំអម្បាញ់មិញ វាជាមតិរបស់ខ្ញុំផ្ទាល់ ដូច្នេះសភាពការណ៍រួម ខ្ញុំមិនដឹងដែរ តែខ្ញុំសង្កេតដោយអត្តនោម័តិរបស់ខ្ញុំ បាទ។

**ស៖** លោកសាក្សីលោកត្រូវតែពន្យល់ឱ្យបានច្បាស់ថា តើការយល់ឃើញរបស់លោកនេះចង់បានន័យថាម៉េច?

**ឆ៖** ការយល់របស់ខ្ញុំ ដូចខ្ញុំបញ្ជាក់ដដែល គឺថាខ្ញុំឃើញថា ហូបមិនគ្រប់គ្រាន់ទេ។ ទោះយ៉ាងណាក៏មិនគ្រប់គ្រាន់ដែរ បាទ។

**ស៖** លោកសាក្សីដើម្បីបញ្ជាក់បញ្ហាឱ្យច្បាស់អំពីចំណុចនេះ ខ្ញុំសូមផ្តល់ឯកសារមួយជូនលោក គឺកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោកចុះថ្ងៃទី១៣ ធ្នូ ឆ្នាំ២០០៧ គឺជាការស្តាប់ចម្លើយរបស់អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត។ ឯកសារនេះ មានលេខ D91/22 ជាភាសាបារាំង ERN 00529341។

**លោក បាណាបេ ណេគ្រី៖**

ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញឯកសារនេះជូនសាក្សី ដើម្បីឱ្យគាត់រំឭកការចងចាំរបស់គាត់ឡើងវិញ។ ខ្ញុំសូមអាននូវសំណួរទីមួយ ដែលគេបានសួរទៅកាន់លោក នី កន។ ខ្ញុំមិនដឹងថា តើមានឯកសារជាភាសាខ្មែរដែរឬទេ? សូមផ្តល់ឯកសារជាភាសាខ្មែរជូនគាត់ ដើម្បីឱ្យគាត់បានពិនិត្យមើលឯកសារនេះ។

[១៥:១៩:១៨]

**ប្រធានអង្គជំនុំ៖**

អ្នកណាផ្តល់? លោកអ្នកផ្តល់ ឬក៏ឱ្យអ្នកណាអ្នកផ្តល់? បើលោកមកសួរថា លោកជាអ្នកសួរ

ហើយមកសួរថារកឯកសារជាភាសាខ្មែរនេះ សួរអ្នកណាគេ? លោកបានត្រៀមទេ? ត្រៀមឯកសារជាភាសាខ្មែរសម្រាប់ជូនសាក្សីពិនិត្យទេ?

**លោក បាណាបេ ណេគ្រី៖**

លោកប្រធាន ខ្ញុំបាននិយាយថា ឥឡូវនេះមានឯកសារជាភាសាខ្មែរហើយ ខ្ញុំសូមផ្តល់ជូនឯកសារនេះជូនសាក្សី។ ខ្ញុំមាននៅក្នុងដៃហើយ អ៊ីចឹងសូមផ្តល់ជូនឯកសារនេះទៅកាន់សាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីយកជូនសាក្សីពិនិត្យ។

[១៥:២០:១៨]

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី គឺខ្ញុំចង់អាននូវចម្លើយទីមួយ ដែលលោកបានឆ្លើយទៅនឹងសំណួររបស់អ្នកស៊ើបអង្កេត។ សំណួរគឺថាមានដូចតទៅនេះ៖ "ពេលដែលលោកធ្វើការនៅក្រសួងការបរទេស លោកធ្លាប់បានជូនភ្ញៀវទៅទស្សនកិច្ចនៅខេត្តសៀមរាប និងនៅតាមមូលដ្ឋាននានា តើលោកកត់សម្គាល់បានទេថាតើជីវភាពប្រជាជនយ៉ាងណាដែរ?"។ លោកបានឆ្លើយថា៖ "ខ្ញុំបានឃើញប្រជាជន មានការហូបចុកមិនគ្រប់គ្រាន់-- សូវគ្រប់គ្រាន់ទេ ប៉ុន្តែការហូបចុកដូចៗគ្នានៅតាមកន្លែងនីមួយៗ មានតិចហូបតិច មានច្រើនហូបច្រើន។ មូលហេតុនៃការខ្វះខាតការហូបចុកនោះ គឺមកពីការទទួលបន្ទុកអ្នកដែលជម្លៀសចេញពីទីក្រុង។ ការងាររបស់ប្រជាជនភាគច្រើន គេធ្វើលើកទំនប់ ជីកប្រឡាយ គឺអនុវត្តនយោបាយឯករាជ្យ។ ខ្ញុំមិនដែលបាននាំភ្ញៀវទៅទស្សនាផ្ទាល់នៅការដ្ឋានទេ"។ លោកសាក្សីបន្ទាប់ពីខ្ញុំអាននេះហើយ ខ្ញុំចង់សួរលោកថា នៅពេលដែលលោកនិយាយថា នេះជាការយល់ឃើញរបស់លោក តើវាត្រឹមត្រូវនឹងការពិតទេ អ្វីដែលលោកបានឃើញនៅពេលនោះ ថាអ៊ីចឹងមែនទេ ជាការពិតទេ?

**លោក នី កន៖**

**ឆ៖** សូមបញ្ជាក់ជូន តាមខ្ញុំគឺ ខ្ញុំកំណត់ថា ជាការពិតបាទ។

[១៥:២២:២៦]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ លោកសាក្សី។ ខ្ញុំត្រឡប់មកនិយាយអំពីឯកសារដែលបានចោទសួរដោយសហព្រះរាជអាជ្ញា ហើយខ្ញុំសូមអានឲ្យលោកស្តាប់នូវសម្រង់មួយ ពាក់ព័ន្ធទៅនឹងលោក អៀង សារី គឺឯកសារលេខ D108/28.318 ដែលលោកសាក្សីមាននៅក្នុងដៃហើយ។

ពេលនេះខ្ញុំសូមអាននូវសម្រង់មួយ ដែលមានលេខ ERN ជាភាសាអង់គ្លេស S00013185 ជាភាសាខ្មែរ S00810122 ជាភាសាបារាំង S00793499។

លោកសាក្សី ខ្ញុំសូមអានកថាខណ្ឌទីពីរនៃឯកសារជាភាសាបារាំង៖ "មេដឹកនាំជាច្រើនដែលយើងបានជជែក-- មេដឹកនាំរដ្ឋាភិបាលជាច្រើន និងជនមានឥទ្ធិពលក្មេងៗរបស់យើងបង្ហាញពីការជឿជាក់ មោះមុត និងការបើកចំហពីជ័យជម្នះ លោក អៀង សារី បានស្វាគមន៍យើងនៅក្នុងលៀងសាយភោជន៍ ជាមួយនឹងស្រាប៊ីកដូដែលគាត់បានសំដៅ ដោយសើចក្អាកក្អាយថា ការខូចខាតនៃសង្គ្រាមមន្ត្រីកំពូលផ្សេងៗទៀតតែងពាក់នាឡិកាស្វីសថ្លៃៗជានិច្ច ហើយជួនកាលគេឃើញថា ប្រើប្រាស់ស្ពាប៉ាកកា មកពីអាល្លឺម៉ង់ខាងលិច ឬអាមេរិក"។

[១៥:២៤:៥១]

លោកសាក្សី តើលោកឃើញឃ្លានេះទេ? ខ្ញុំសូមសួរសំណួរ នៅពេលដែលលោកកំពុងតែមើលនេះ។ តើរបាយការណ៍នេះត្រូវគ្នាទៅនឹងហេតុការណ៍ ដែលលោកបានជួបប្រទះនៅពេលដែលមានទស្សនកិច្ចរបស់គណៈប្រតិភូជប៉ុននៅខេត្តសៀមរាប ដោយអមដំណើរដោយលោក អៀង សារី ហើយនៅពេលនោះ មានពិធីជប់លៀងជូនគណៈប្រតិភូជប៉ុនផងដែរ។

**ឆ៖** សូមជម្រាបជូន ខ្លឹមសារដែលលោកលើកមកសួរខ្ញុំនេះ ខ្ញុំមិនចាំទេ។ ហើយការពិតជាមួយនឹងខ្លឹមសារនេះ វាមិនត្រូវទាំងអស់ទេបាទ។ មិនមែនចេះតែអ្នកណាមានរបស់ប្រើប្រាស់អីអ៊ីចឹងទេ។ នេះសូមជម្រាបជូនបាទ។

**ស៖** លោកសាក្សី តើលោកនឹកឃើញអំពីជប់លៀងដែលថា លោកជាអ្នករៀបចំនេះដែរទេ? តើលោកមានចាំទេ ថាមានការរៀបចំពិធីជប់លៀងទៅដល់គណៈប្រតិភូជប៉ុននៅខេត្តសៀមរាបនេះដែលថាគាត់បានស្នាក់អស់រយៈពេលពីរសប្តាហ៍នៅកម្ពុជា? លោកចាំទេ ថាមានការរៀបចំពិធីជប់លៀងអីទេ?

**ឆ៖** បាទ ខ្ញុំមិនចាំទេបាទ។

[១៥:២៦:៥៥]

**ស៖** សូមអរគុណ។ លោកសាក្សី ខ្ញុំគិតថាវាកើតឡើងតាំងពីយូរហើយ ប៉ុន្តែខ្ញុំសូមឲ្យលោកព្យាយាមរំឭកការចងចាំឡើងវិញ។ តើលោកចងចាំអំពីកន្លែងដែលគណៈប្រតិភូស្នាក់ខេត្តសៀមរាបទេនៅពេលដែលគណៈប្រតិភូទៅទស្សនកិច្ចនៅខេត្តសៀមរាប តើពួកគាត់ស្នាក់នៅឯណា?

**ឆ៖** សូមបញ្ជាក់ជូន គឺកាលណោះ ក្រោយសង្គ្រាមចប់ភ្លាមៗ ការរៀបចំគ្មានអូតែលអីច្រើនទេ។ ខ្ញុំចាំថា មានតែអូតែលមួយ គេហៅ បង់ហ្កាឡូៗ។ បង់ហ្កាឡូ ហ្នឹង ឥឡូវមិនដឹងជា ទៅជាអីខ្ញុំមិនដឹងដែរ។ តែអូតែលហ្នឹង វាជាប់នឹងស្ពានថ្មទៅ ហួសបន្តិចទៅ ឃើញអូតែលហ្នឹងធំជាងគេ ពេលនុំង ហើយសម្រាកនៅកន្លែងហ្នឹងបាទ។

**ស៖** សូមអរគុណ។ ក្រៅពីការស្នាក់របស់ប្រធានគណៈប្រតិភូ ខ្ញុំសូមឲ្យលោករំឭកការចងចាំឡើងវិញ ដោយអានន្ទូវសម្រង់មួយនៃឯកសារដដែលនេះ ដែលលោកមាននឹងមុខលោកហើយ។ គឺនៅទំព័រ ERN ជាភាសាអង់គ្លេស S0013184 ជាភាសាខ្មែរ S008101-- 012 (*សូមទោស*) ជាភាសាបារាំង S00793498។

**លោក បាណាបេ ណេគ្វី៖**

ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ សូមឲ្យជួយ ឲ្យលោកក្រឡាបញ្ជីជួយសាក្សីរកផ្នែកពាក់ព័ន្ធដែលខ្ញុំចង់បង្ហាញនេះ។

[១៥:២៩:៣០]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីឲ្យលេខទំព័រ ERN ជាភាសាខ្មែរ ម្តងទៀត។ ពីព្រោះម្តង 0122 ម្តង 012 អីចឹងមិនដឹងថាលេខ ERN ជាភាសាខ្មែរហ្នឹង ជាក់ច្បាស់ប៉ុន្មានទេ ហើយមន្ត្រីរដ្ឋបាលតុលាការក៏មិនអាចចង្អុលបង្ហាញសាក្សីបានដែរ ព្រោះគាត់ស្តាប់មិនបានដែរ។

[១៥:៣០:០៣]

**លោក បាណាបេ ណេគ្វី៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំនឹងផ្តល់ម្តងទៀត លេខ ERN ហ្នឹងគឺ S0081012ៗ។ លោកប្រធានគឺឯកសារដដែល។ គឺនៅទំព័រខាងមុខមួយទៀត គឺថានៅក្នុងភាសាបារាំង គឺមានលេខកូដ S00810388 សូមទោស! 98។

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីនេះ គាត់អានលេខERN ឡើងវិញ ព្រោះថាលឿនពេក អ្នកបកប្រែស្តាប់អត់ទាន់ទេ។

**លោក បាណាបេ ណេគ្រី៖**

ជាភាសាខ្មែរ គឺ S001012-- លោកប្រធាន ខ្ញុំច្រឡំទេ គឺលេខ 00810112។

**ប្រធានអង្គជំនុំ៖**

មន្ត្រី អ៎!បុគ្គលិកជំនួយការមេធាវីអាចដាក់បង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍បានទេ ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់។

[១៥:៣២:៥៣]

**លោក បាណាបេ ណេគ្រី៖**

លោកប្រធាន ដោយសារយើងពុំមានពេលនោះទេ ខ្ញុំសូមនិយាយអំពីប្រធានបទផ្សេងទៀតជាមួយគាត់ ហើយនិងត្រឡប់មកនិយាយលើកអំពីចំណុចនេះវិញនៅពេលក្រោយ។ ព្រោះថាខ្ញុំឃើញថាពេលវេលាកាន់តែទៅមុខទៅហើយ។ ហើយខ្ញុំមានប្រធានបទមួយចំនួនទៀតដើម្បីនិយាយជាមួយសាក្សីនេះ។ បើលើកលែងដែរថា--

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី លោកឃើញច្បាស់ពីយោងដែលខ្ញុំបានបង្ហាញអម្បាញ់មិញហើយដែរឬទេ?

លោកសាក្សី តើលោក ឯកសារជាមួយនឹងយោងជាក់លាក់ហើយឬនៅ? លោកអាចឆ្លើយនឹងសំណួរខ្ញុំបានដែរឬទេ លោកសាក្សី?

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ដូចជារកមិនឃើញទេ ហើយនៅក្នុងអេក្រង់កំព្យូទ័រ ក៏ដូចជាអត់មានទំព័រ ERN S00810112 ទេ។ មានតែ 0121។ លោកអាចច្រឡំ 0121 ឬក៏ 0112? ឯកសារនេះមានដើមដំបូងមក គឺ S00810113 ទេ អត់មាន 0112 ទេ។

[១៥:៣៤:៣៧]

**លោក បាណាបេ ណេគ្រី៖**

ប្រហែលជាលោកប្រធាន យល់ត្រឹមត្រូវហើយ ព្រោះថាខ្ញុំមើលទៅឃើញតែយោងដែលខ្ញុំឲ្យនេះមិនត្រូវទេ។ ឥឡូវនេះ យោងល្អហ្នឹង គឺថា S00810121។ គឺថាខ្ញុំកត់សម្គាល់មិនត្រឹមត្រូវ។ វាមិនមែនជាទំព័រដែលពាក់ព័ន្ធ។

**សួរដោយលោក បាណាបេ ណោគ្វី៖**

**ស៖** លោកសាក្សី ដោយកុំឲ្យខាតពេលវេលា ខ្ញុំចង់អានវគ្គនេះ នៅកថាខណ្ឌទី១ នៃឯកសារនេះ ដែលមានចំណងជើងថា "ចំណាប់អារម្មណ៍របស់អ្នកទស្សនកិច្ចជប៉ុននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"។ នៅក្នុងកថាខណ្ឌនេះ មាននិយាយយ៉ាងដូច្នេះ "លោក កូហ្សូ សាសាគី មេគណៈប្រតិភូសមាគមមិត្តភាពកម្ពុជា-ជប៉ុន មានការអៀនខ្មាសខ្លះៗនៅក្នុងអំឡុងពេលទស្សនកិច្ចរបស់យើងនៅអង្គរវត្ត។ គាត់ត្រូវគេឲ្យស្នាក់នៅក្នុងបន្ទប់គេងសំខាន់ដែលមានការតុបតែងស្អាតប្រចាំព្រះរាជវាំង ឯកជនរបស់ព្រះអង្គម្ចាស់នរោត្តម សីហនុ នៅក្នុងខេត្តសៀមរាប"។ ខ្ញុំសូមបញ្ចប់ការដកស្រង់ត្រឹមនេះ។

ខ្ញុំសូមសួរសំណួរមួយ តើសម្រង់នេះធ្វើឲ្យនឹកឃើញដល់កន្លែងដែលគណៈប្រតិភូជប៉ុន ដែលលោក កូហ្សូ សាសាគី (Kozo Sasaki) ដែលពេលដែលគាត់ធ្វើទស្សនកិច្ចនៅខេត្តសៀមរាបនុ៎ងដែរឬទេ?

[១៥:៣៦:២៦]

**លោក នី កន៖**

**ឆ៖** សូមជម្រាប ខ្ញុំបានបញ្ជាក់ជូនអម្បាញ់មិញថា ខ្ញុំចាំគឺមានតែបង់ហ្កាឡូ។ បង់ហ្កាឡូ ហ្នឹងគេទុកជាអូតែលមួយស្អាតនៅខាងសៀមរាបហើយ។ ឯដំណាក់របស់ព្រះមហាក្សត្រអីនេះ ខ្ញុំដូចមិនឮទេ មិនឮថាបានទៅស្នាក់នៅកន្លែងហ្នឹងទេបាទ។ សូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ បាទ ខ្ញុំនឹងបន្តទៅប្រធានបទផ្សេងទៀត ក៏ប៉ុន្តែ-- ទាក់ទងនឹងការ-- កិច្ចទស្សនកិច្ចដដែល ខ្ញុំចង់និយាយជាមួយលោកអំពីការពន្យល់របស់លោក អៀង សារី ដែលលោក អៀង សារី គាត់បានធ្វើការពន្យល់ដល់គណៈប្រតិភូនេះទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងចោទសំណួរឯកសារដដែល គឺ D108/28.318។ បាទឥឡូវនេះ គឺថាលេខERN មានដូចតទៅនេះ គឺ S00-- ជាភាសាអង់គ្លេស 013190 ជាភាសាខ្មែរ 00810129 ដល់ 0-- អ៎ទៅដល់លេខ 30។ ជាភាសាបារាំង S00793503។ គឺកថាខណ្ឌចុងបញ្ចប់នៃឯកសារនេះ នៅក្នុងសំណៅជាភាសាបារាំង ហើយខ្ញុំនឹងអានមួយផ្នែកសម្រាប់លោក។

[១៥:៣៩:១៣]

មានការលើកឡើងយ៉ាងដូច្នេះ៖ "អ្នកដឹកនាំកម្ពុជាដែល-- ថាមានប្រតិកម្មលើការទិតៀនរបស់ខាងបរទេសលើការជម្លៀសប្រជាជន ហើយក៏ខំពន្យល់ថា ត្រូវតែមានការចាំបាច់ក្នុងការជម្លៀស

ប្រជាជនចេញទៅជនបទ ដើម្បីសម្រេចដល់គោលបំណងបដិវត្តន៍។ ឧបនាយករដ្ឋមន្ត្រី អៀង សារី បានប្រាប់យើងថា នៅពេលរំដោះពីបីទៅបួនលាននាក់នៃប្រជាជនខ្មែររស់នៅក្នុងទីក្រុង ហើយភាគច្រើនគាត់បានលើកឡើងដូចយ៉ាងដូច្នេះ គឺថាសុទ្ធតែជាអតីតប្រជាជនដែលគេចចេញពីបោកគ្រាប់បែកអាមេរិកាំង និងអតីតទាហាននៃរបបកម្ពុជា ហើយគាត់ក៏បានពន្យល់ទៀតផងដែរថា ផលិតផលអាហារទាបធ្វើឲ្យមានកង្វះខាតផ្នែកស្បៀងអាហារ ហើយដោយសារតែត្រូវតែសម្រេចនូវគោលនយោបាយខ្លួនទីពឹងខ្លួន អ៊ីចឹងត្រូវតែជំរុញឲ្យប្រជាជនទាំងអស់ចេញទៅនៅតំបន់ជនបទ”។

សំណួររបស់ខ្ញុំដូចតទៅនេះលោកសាក្សី ពាក្យសម្ដីរបស់លោក អៀង សារី តើពាក្យពេចន៍ទាំងអស់នេះ បើតាមលោកចាំនោះវាត្រឹម-- តើវាឆ្លុះបញ្ចាំងទៅនឹងព័ត៌មានដែលលោកទទួលបន្ទុកក្នុងការបញ្ជូនទៅៗគណៈប្រតិភូបរទេសដែលគាត់មកទស្សនកិច្ចនៅប្រទេសកម្ពុជា ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែរឬទេ?

[១៥:៤១:១១]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវាស៖**

សូមអភ័យទោសលោកប្រធាន ដែលខ្ញុំកាត់ ហើយយើងមានពេលខ្លីនៅពេលល្ងាចនេះ ប៉ុន្តែយើងមើលឯកសារនេះ។ នេះជាអ្វីដែលអ្នករាយការណ៍គេអះអាងថា អៀង សារី បាននិយាយ ដើម្បីឲ្យសមស្របលោក អៀង សារី នោះ ប្រហែលជាសំណួរត្រូវតែសួរឡើងវិញ ដើម្បីឆ្លុះបញ្ចាំងថា តើពិតជាអ៊ីចឹងដែរឬអត់? គឺមិនត្រូវសួរថា សាក្សីបញ្ជាក់រឿងហ្នឹងទេ ឲ្យសាក្សីបញ្ជាក់ទេ។ អ៊ីចឹងដើម្បី-- បើសិនជាទទួលយកការទទួលស្គាល់ពីសាក្សីដែលគាត់អវត្តមាននោះ គឺត្រូវសួរគាត់ថា តើគាត់វត្តមានគាត់ឮអ៊ីចឹងត្រូវ គឺអយុត្តិធម៌សម្រាប់លោក អៀង សារី។ ប៉ុន្តែ-- ហើយមេធាវីការពារបាននិយាយថា ថាតើតាមពិតលោក អៀង សារី និយាយបែបនេះ តើវាឆ្លុះបញ្ចាំងពីស្ថានភាពនៅពេលនោះទេ? គឺថានេះជាបញ្ហាដែលខ្ញុំមិនជំទាស់ទេ។ ប៉ុន្តែបើសិនជាដកស្រង់ហើយយកមកឲ្យសាក្សីបញ្ជាក់ថា លោក អៀង សារី និយាយអ៊ីចឹងវាបញ្ជាក់ពីការពិត អាហ្នឹងខ្ញុំជំទាស់ចំពោះសំណួរនេះលោកប្រធាន។

[១៥:៤២:២៧]

**លោក បាណាបេ ណេគ្រី៖**

លោកប្រធាន ខ្ញុំមិននិយាយ មិនឆ្លើយតបទៅនឹងការជំទាស់នេះទេ។ ខ្ញុំនឹងចោទសំណួរផ្សេង របៀបផ្សេងវិញ។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី តើនៅពេលធ្វើទស្សនកិច្ចរបស់គណៈប្រតិភូជប៉ុននេះ លោកបានឮលោក អៀង សារី ធ្វើការពន្យល់ទៅភ្ញៀវទាំងអស់នេះ អំពីការជម្លៀសប្រជាជនចេញពីទីក្រុង ជាពិសេស ទីក្រុងភ្នំពេញ ព្រោះថា លោកជាមគ្គុទ្ទេសក៍នៃគណៈប្រតិភូនេះ។ តើលោកបានឮទេ?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន យូរឆ្នាំពេកហើយ ហើយជាពាក្យសម្ដីសន្ទនារវាងគណៈប្រតិភូជប៉ុន និង តា អៀង សារី ខ្ញុំមិនចាំទេ។ ដូច្នោះ យកខ្ញុំជាអ្នកបញ្ជាក់ថា ពិត ឬមិនពិត ខ្ញុំឆ្លើយមិនបានទេ បាទ។

[១៥:៤៤:១១]

**ស៖** លោកសាក្សី ខ្ញុំសូមរំឭកទៅដល់លោកនូវវគ្គបន្ទាប់ទៀត ដែលសហព្រះរាជអាជ្ញាបាន បង្ហាញលោកហើយ នៅក្នុងនេះមានសរសេរថា "លោក នី កន លោកផ្ទាល់តែម្ដងជាអ្នកតំណាងឲ្យ ក្រសួងការបរទេសដែលបានអមដំណើរយើងនៅពេលធ្វើដំណើរ ហើយលោកបាននិយាយថា មនុស្ស ភាគច្រើនបានចាកចេញដោយពុំមានការរឹងទទឹង ហើយបានត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញ"។ ហើយសម្រង់នេះត្រូវបានអានជូនលោកហើយព្រឹកមិញ។ អ៊ីចឹងសំណួរខ្ញុំគឺថា តើលោកបាននិយាយជា មួយគណៈប្រតិភូជប៉ុនអំពីបញ្ហាជម្លៀសប្រជាជនចេញពីទីក្រុងដែរឬទេ នៅពេលដែលគាត់មកស្នាក់នៅ ពេលដែលគាត់មកធ្វើទស្សនកិច្ចនៅស្រុកខ្មែរនោះ?

[១៥:៤៥:០៤]

**ឆ៖** សូមបញ្ជាក់ជូន ខ្ញុំចាំមិនបានច្បាស់លាស់ទេ តែបើខ្ញុំនិយាយ ឬអធិប្បាយជូនភ្ញៀវ ក៏នៅតែ ក្នុងខ្លឹមសារ ដូចខ្ញុំបញ្ជាក់បន្តបន្ទាប់ គឺថាទីមួយ ហេតុផលដែលចេញ គឺចេញមកខ្លាចគ្រាប់បែក ខ្លាច មានការប្រយុទ្ធគ្នា ដណ្ដើមទីក្រុង។ ហើយទីពីរ មិនឃើញថា បង្ខិតបង្ខំយ៉ាងនេះយ៉ាងនោះទេ គ្រាន់តែ មានសេចក្ដីអំពាវនាវថា នៅខេត្តណា ស្រុកណា ទៅខេត្តនោះស្រុកនោះវិញ។ នេះខ្ញុំតែងនិយាយគឺអ៊ីចឹង បាទៗ។

**ស៖** បាទ សូមអរគុណលោកសាក្សី។ ទាក់ទងនឹងប្រធានបទនេះដដែល គឺថាលោកបានពន្យល់

ពេលដែលលោកផ្តល់សក្ខីកម្មថា នៅថ្ងៃទី១៧ មេសា នៅពេលល្ងាច នៅពេលដែលលោកបាន-- ពេលយប់នៅពេលដែលលោកទៅតំបន់របស់លោកដោយជិះម៉ូតូនោះ តើលោកចាំថា លោកបាននិយាយយ៉ាងដូច្នេះទេ?

[១៥:៤៦:៤៩]

**ឆ៖** បាទ ខ្ញុំបាននិយាយយ៉ាងនេះបាទ។

**ស៖** តើលោកមានឌុបអ្នកណាដែរឬទេ ពេលដែលលោកធ្វើដំណើរពីភ្នំពេញទៅកន្លែងមូលដ្ឋានរបស់លោកនោះ? លោកជិះម៉ូតម្នាក់ឯង ឬក៏មានឌុបអ្នកណាដែរ?

**ឆ៖** ធម្មតាក្នុងសង្គ្រាម មិនអាចដើរម្នាក់ឯងបានទេ គឺមានយុវជនម្នាក់អ្នកឌុប អ្នកបើកបរឌុបខ្ញុំគឺបានន័យថា ទៅពីរនាក់ មកក៏ពីរនាក់ ទៅក៏ពីរនាក់បាទ។

**ស៖** តើគាត់ជាយុវជនខ្មែរក្រហម តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់ជាយុវជនក្នុងកងទ័ព នៅសមរភូមិហ្នឹងបាទ។

[១៥:៤៨:១១]

**ស៖** បាទដូច្នេះ គឺបានន័យថា ហ្វូងមនុស្សដែលលោកបានឃើញ-- ហ្វូងមនុស្សដ៏ធំសម្បើមដែលលោកឃើញតាមផ្លូវនោះ ដូចដែលលោកបានពិពណ៌នានៅពេលដែលលោកផ្តល់សក្ខីកម្ម ថាពួកគាត់ដើរតាមផ្លូវរហូត។ អ៊ីចឹងលោកមិនមែនថា មិនអាច មិនដឹងថាពួកមនុស្សទាំងអស់នោះទៅណានោះទេ តើពិតជាអ៊ីចឹងទេ ថាគាត់ទៅភូមិកំណើតរបស់គាត់វិញ ឬយ៉ាងម៉េច?

**ឆ៖** បាទ ការធ្វើដំណើររបស់ប្រជាជនក្រុងភ្នំពេញ គឺជាមូលដ្ឋានគេទៅតាមពាក្យអំពាវនាវថា នៅស្រុកណាទៅស្រុកហ្នឹង ដល់អ៊ីចឹងបើអ្នកណាគេនៅមួយជួរកំពង់ស្ពឺទៅលិច គេទៅតាមផ្លូវលេខ៤ បើអ្នកណាគេនៅម្តុំកំពង់ចាម គេទៅតាម ឬក៏ទៅកំពង់ឆ្នាំងអី គេទៅតាមផ្លូវលេខ៥។ ដូច្នេះ ខ្ញុំឃើញតាមហ្នឹង ឃើញដំណើរគេទៅតាមហ្នឹង។ ហើយមនុស្សច្រើនបែបនេះ សូមបញ្ជាក់បន្ថែមដើម្បីអង្គសវនាការយល់ថែម គឺមិនអាចធ្វើដំណើរមួយថ្ងៃបានសិបគីឡូទេ ទៅគ្រៀនៗតាមគ្នាហ្នឹងទៅបាទ។ បាទសូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

[១៥:៤៩:៥៦]

**ស៖** លោកក៏បាន-- លោកក៏ត្រូវបានថតជាច្រើនដែរ ហើយក៏លោកបានសង្កេតថា ដោយសារតែមានការជម្លៀស ហើយនិងអ៊ីចឹង គឺថាមានការខ្វះខាតចំណីអាហារ នៅក្នុងទូទាំងប្រទេសតែម្តង។

ហើយមូលហេតុដែលបន្ថែមលើហ្នឹងទៀតហ្នឹងគឺថាដោយសារការដាំដុះនោះវាទិន្នផលមិនល្អ។ តើខ្ញុំសង្ខេបត្រឹមត្រូវដែរឬទេ លើអ្វីដែលលោកនិយាយទាក់ទងទៅនឹងកង្វះខាងចំណីអាហារ? ព្រោះថាទាំងអស់នេះសុទ្ធតែលោកបានសង្កេតផ្ទាល់ដោយខ្លួនឯងតែម្តង។

**ផ៖** បាទ ត្រឹមត្រូវ។

**ស៖** ដូច្នេះជាការត្រឹមត្រូវក្នុងការសន្និដ្ឋានថា វាមិនមែនជាការត្រឹមត្រូវទេដែលចាត់ទុកថាចំពោះប្រជាជនភ្នំពេញត្រូវត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញ បញ្ជូនគាត់ទៅ ជម្លៀសទៅប្រទេស-- អំទៅស្រុកកំណើតរបស់ខ្លួនហ្នឹង មិនមែនជាមធ្យោបាយមួយដើម្បីដោះស្រាយបញ្ហាកង្វះខាតចំណីអាហារនោះទេ តើពិតជាអ៊ីចឹងមែនទេ ត្រឹមត្រូវទេ អ្វីដែលខ្ញុំនិយាយនេះ?

**ផ៖** ខ្ញុំមិនយល់សំណួរនេះទេបាទ។ សូមលោកបញ្ជាក់ម្តងទៀត។

[១៥:៥១:៣៥]

**ស៖** បាទលោកសាក្សី ខ្ញុំនឹងនិយាយចោទសំណួរឲ្យសាមញ្ញជាងនេះបន្តិច ទោះបីតែជាមានទោះបីជាថាសម្រង់របស់លោក អៀង សារី នោះ ត្រូវមានការបដិសេធក៏ដោយ គឺថាមានការស្តែងចេញថាមានមូលហេតុមួយ ដែលថាមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺថាទីមួយគឺថាឲ្យហេតុផលថាដោយសារគាត់មានស្រុកកំណើតនៅស្រុកស្រែ ហើយមួយទៀតបង្ហាញថា ដោយសារមានកង្វះខាតចំណីអាហារនៅទីក្រុងភ្នំពេញ។ អាស្រ័យហេតុដូច្នេះហើយបានត្រូវបញ្ជូនគាត់ទៅជនបទវិញដើម្បីឲ្យគាត់ហ្នឹងមានចំណីអាហារគ្រប់គ្រាន់។ តើនេះ-- តើលោកគិតថា តើទាក់ទងនឹងការជម្លៀសនេះ ហេតុផលនេះវាត្រឹមត្រូវដែរឬទេ ដែលលោកលើកឡើងនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តី!

[១៥:៥២:៣៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមអភ័យទោសដែលខ្ញុំកាត់នេះ។ ខ្ញុំមិនប្រាកដថាតើមេធាវីចង់បញ្ជាក់ឲ្យសាក្សីថាលោក អៀង សារី និយាយ ឬក៏ចង់ឲ្យសាក្សីនិយាយថា គាត់បានឮ ឬក៏មានសេចក្តីសម្រេចពីរឿងហ្នឹង ឬក៏ចង់ឲ្យគាត់បញ្ជាក់ថាពីមូលហេតុពីជម្លៀស? ខ្ញុំមិនច្បាស់ថា តើមេធាវីគាត់មានគោលបំណងដូចម្តេច? បើសិនជាលោក មេធាវីគប្បីតែបញ្ជាក់ជាជំហានៗ តើលោកបានដឹងរឿងហ្នឹង

ទេ? ដឹងដោយវិធីណា? ដូចម្ដេច? ដូច្នេះគាត់អាចឆ្លើយថាគាត់ដឹង គាត់មិនដឹង។ ប៉ុន្តែបើយកចម្លើយពីអ្នកផ្សេងសរសេរ ហើយយកមកនិយាយថានេះលោក អៀង សារី និយាយបែបនេះ ហើយចង់ដកស្រង់នូវខ្លឹមសារខ្លះៗ ហើយឲ្យសាក្សីបញ្ជាក់ថាពិត ឬមិនពិតនោះ គឺមិនត្រឹមត្រូវទេ។ ដូច្នេះហើយគឺសូមឲ្យសួរសំណួរឡើងវិញ កុំឲ្យមានការបញ្ជាក់ដោយមិនត្រឹមត្រូវបែបនេះ។ សូមអនុញ្ញាតតុលាការជ្រាប។

[១៥:៥៣:៤១]

**លោក បាណាបេ ណេគ្រី៖**

លោកប្រធាន ខ្ញុំមិនបាច់ឲ្យអង្គជំនុំជម្រះធ្វើសម្រេចអីទេ ខ្ញុំនិយាយពីរឿងផ្សេងទៀតតែម្ដង។

**សួរដោយលោក បាណាបេ ណេគ្រី៖**

**ស៖** លោកសាក្សី ខ្ញុំចង់ត្រឡប់មកនិយាយអំពីពីការពន្យល់របស់លោកទាក់ទងទៅនឹងសកម្មភាពឃោសនាអប់រំនៅពេលដែលលោកស្ថិតនៅតំបន់៣២។ លោកបានពន្យល់ថា ទៅដល់អង្គជំនុំជម្រះថាលោកជំរុញឲ្យមហាជន ផលិត បង្កបង្កើនផល ហើយនិងលោកបង្ហាត់ពីបច្ចេកទេសបង្កបង្កើនផល លោកក៏បានលើកឡើងពីបញ្ហាមួយចំនួនទាក់ទងទៅនឹងការបង្កបង្កើនផលនេះ។ សំណួរខ្ញុំគឺថា តើបច្ចេកទេសជាក់លាក់នោះ បង្កបង្កើនផល ដែលលោកមានទម្លាប់បង្រៀនទៅមហាជននោះ វាយ៉ាងម៉េចដែរ? តើលោកអាចពន្យល់ខ្លះៗបានដែរឬទេ ទាក់ទងនឹងបច្ចេកទេសបង្កបង្កើនផលនេះ?

[១៥:៥៤:៥៣]

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ការជំរុញឲ្យប្រជាជនបង្កើនផល នៅពេលនោះគ្មានអីធំដុំទេ មានតែធ្វើស្រែ ហើយបន្ទាប់ពីហ្នឹង មានតែដាំដំឡូងជ្វា ដំឡូងមី។ បាទ ហ្នឹងដែលការជំរុញ។ ឯបច្ចេកទេសនោះ ក៏គ្មានអីដែរ គឺមានតាមខ្ញុំមើល ដែលការមានភាពអភិវឌ្ឍន៍បន្តិចទុំង គឺឈរមើលមូលដ្ឋានមាត់ទន្លេដែលមានស្រែប្រាំង ហើយឲ្យទប់ទំនប់ហ្នឹងទៅ ហើយបាចបូម-- បាចទឹកចូលទៅ ហើយធ្វើស្រែប្រាំង។ នេះមានតែប៉ុណ្ណឹងទេ។ សូមជម្រាបជូនបាទ។

**ស៖** លោកបានពន្យល់ផងដែរ ទាក់ទងនឹងប្រធានបទនេះ ថាគឺជាការជំរុញសំដៅយ៉ាងណាដើម្បីឲ្យយើងទទួលបានទិន្នផលពីពីរទៅបី-- ពីរបីដងក្នុងមួយឆ្នាំ។ តើនេះជាការសង្ខេបត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំគិតថា មិនត្រឹមត្រូវទេ ពីព្រោះសភាពការណ៍កន្លែងនុ៎ង គ្មានលទ្ធភាពពីរបីដងទេបាទ។ សុទ្ធតែដីល្បាយខ្សាច់ ហើយពឹងលើទឹកភ្លៀង បាទ។ សូមជម្រាបប៉ុណ្ណឹងបាទ។

[១៥:៥៧:១៩]

**ស៖** តើនៅពេលដែលលោកធ្វើការឃោសនាលើផ្នែកកសិកម្មនេះ លោកនិយាយពីពាក្យស្លោកថាធ្វើម៉េចបង្កបង្កើនផលឲ្យបានពីបីតោនក្នុងមួយហិកតា។ តើនេះជាអ្វីដែលលោកនិយាយទៅកាន់មហាជនមែនទេ?

**ឆ៖** នេះជាសេចក្តីណែនាំ ឲ្យថ្នាក់ក្រោមគោរពថ្នាក់លើ។ ដូច្នេះ ចេះតែឃោសនាបន្តគ្នាទៅ ហើយជំរុញបន្តគ្នាអ៊ីចឹងទៅ។ តែការធ្វើបាន ធ្វើមិនបាន វានៅលើជាក់ស្តែង ហើយភាគច្រើន គឺធ្វើមិនបាន បាទ។

**ស៖** តើនៅក្នុងក្របខ័ណ្ឌនៃការឃោសនានេះ តើលោកមានធ្លាប់និយាយអំពីសុខភាពមហាជនដែរឬទេ? ដែលមហាជនដែលទទួលបន្ទុកក្នុងការធ្វើការបង្កបង្កើនផលនេះ?

[១៥:៥៨:៤៦]

**ឆ៖** ខ្ញុំចាំមិនអស់ទេ តែធម្មតាខ្ញុំត្រូវតែនិយាយ ពីព្រោះកាលណោះ វាចោទបញ្ហា ក្រោយសង្គ្រាម វាខ្វះសព្វខ្វះគ្រប់។ អ៊ីចឹង ការនិយាយ ហើយការប្រតិបត្តិមានតែគេយកបណ្តូលពេជមកស្ងោរនឹងខ្ទះត្នោត ដើម្បីហូបទៅការពារជំងឺគ្រុនចាញ់។ ហើយក្រៅពីហ្នឹង ក៏មានពេទ្យប្រចាំកន្លែង ចេះតែថែទាំតាមហ្នឹងទៅ តែហៅថាការគិតគូរ គិតគូរជាប់ដែរបាទ។

**ស៖** តើចំពោះលោកនោះ នៅក្នុងតំបន់លោក ជាពិសេសហ្នឹង តើមធ្យោបាយ-- ឧទាហរណ៍ដូចជាការផ្តល់ឲ្យជាឫសឈើ ឬក៏ក្លួចអីអ៊ីចឹង។ អាចឲ្យមហាជនហ្នឹងញ៉ាំទៅ ហើយមានសុខភាពគ្រប់គ្រាន់អាចធ្វើការបានដែរឬទេ?

**ឆ៖** បាទ តាមធម្មតានេះ គឺយករបស់ធម្មជាតិ ក្រៅពីអង្ករមកហូបនេះ វាយ៉ាងណាក៏ វាមិនដូចគ្នាដែរបាទ។ តែជាការដោះស្រាយ រយៈឆ្លងកាត់ធ្វើម៉េចឲ្យវាបានអាហារចែកគ្នាហូប។ នេះដែលជាបទពិសោធន៍ដែលខ្ញុំឃើញ។ ឲ្យហៅថាមក ទៅផ្លាស់ប្តូររវាងអង្ករ និងក្លួច ឬអីៗផ្សេង ដំឡូងអីផ្សេង ឲ្យវាដូចគ្នា វាមិនដូចទេបាទ។

**លោក បាណាបេ ណេគ្វី៖**

លោកប្រធាន ខ្ញុំគិតថាឥឡូវម៉ោង វាហ្នឹង-- ខ្ញុំលើសពីរបីនាទីហើយ ហើយខ្ញុំមានឯកសារមួយ

ទៀត ដែលខ្ញុំចង់បង្ហាញដល់សាក្សី ហើយខ្ញុំត្រូវការពេលប្រហែលជាប្រាំនាទីលោកប្រធាន។ ខ្ញុំចង់ដឹងថា តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបង្ហាញឯកសារនេះដល់សាក្សី ឬក៏អត់?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ! ប៉ុន្តែសូមរំឭកលោកមេធាវីថា គួរតែត្រូវបានត្រៀមនូវសំណួរទាំងឡាយដែលមានជាសំណួរសក្តានុពលក្នុងការសួរដេញដោលសាក្សី វាចៀសវាងចំណាយពេលវេលាសួរសំណួរបន្ទាប់បន្សំ ដែលវាតម្លៃតិចតួចនៅក្នុងការពិចារណាឈានទៅរកការស្វែងរកការពិត នៃរឿងក្តីនេះ។

**លោក បាណាបេ ណេគ្វី៖**

បាទ សូមអរគុណលោកប្រធាន។

[១៦:០២:២៩]

**សួរដោយលោក បាណាបេ ណេគ្វី៖**

**ស៖** លោកសាក្សី ខ្ញុំចង់បង្ហាញសម្រង់នៃឯកសារមួយ ដែលបានបក-- ត្រូវបានបង្ហាញឲ្យលោករួចហើយ ពីសំណាក់សហព្រះរាជអាជ្ញាកាលពីព្រឹកមិញ គឺជាទង់បដិវត្ត ទស្សនាវដ្តីទង់បដិវត្តដែលនៅក្នុងនោះមានសុន្ទរកថារបស់លោក នួន ជា នៅក្នុងឱកាសសន្និបាតភូមិភាគ នៅខែកក្កដា ឆ្នាំ១៩៧៧។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំង គឺ 00611840, ជាភាសាខ្មែរ 00062964, ជាភាសាអង់គ្លេស 00399235 ទៅដល់ 36។

បាទ ខ្ញុំគ្រាន់តែសុំអានសម្រង់នៃសុន្ទរកថានេះទេ មួយផ្នែកទេ នៅពេលដែលលោក នួន ជា និយាយដូចតទៅនេះ៖ “ក៏ប៉ុន្តែ នៅក្នុងសហករណ៍ជាច្រើនគួរសមដែរ អំណាចមិនមែននៅក្នុងកណ្តាប់ដៃកម្មករ កសិករ នៅឡើយទេ គឺនៅក្នុងកណ្តាប់ដៃវណ្ណៈផ្សេងទៀត។ គឺថាបើសិនជាអំណាចនេះស្ថិតនៅក្នុងវណ្ណៈផ្សេងទៀតនោះ តើវណ្ណៈនោះនៅគាំទ្របដិវត្ត ឬក៏អត់? ទេ! មិនគាំទ្រទេ គឺប្រឆាំងនឹងបដិវត្តន៍។ យើងត្រូវតែរៀបចំកសិករក្រ កសិករកណ្តាលថ្នាក់ក្រោម ដើម្បីឲ្យទៅកាន់កាប់សហករណ៍ទៅវ៉ៃកម្ទេចរដ្ឋអំណាចវណ្ណៈផ្សេងៗ ដែលមកលួចកាន់កាប់សហករណ៍របស់យើង។ បញ្ហាទាំងអស់នេះវាមិនមែនទាក់ទងតែតំបន់នៅក្នុងភូមិភាគបស្ចិមទេ ក៏ប៉ុន្តែភូមិភាគផ្សេងទៀតផងដែរទូទាំងប្រទេស”។

[១៦:០៤:៥៥]

សំណួររបស់ខ្ញុំ តើលោកធ្លាប់បានឮអំពីសម្រង់នេះទេ គឺថាឮលោក នួន ជា និយាយអំពីបញ្ហា

វណ្ណៈ នៅខែកក្កដា ឆ្នាំ១៩៧៧ នៅក្នុងភូមិភាគរបស់លោកដែរឬទេ?

**ឆ៖** សូមឆ្លើយ ខ្លឹមសារហ្នឹងខ្ញុំមិនចាំទេ ហើយក៏តាមធ្លាប់ឮ ដូចមិនសូវមានខ្លឹមសារនិយាយអីអ៊ីចឹងដែរ។ ពីព្រោះការជ្រើសរើសក្រុមសហករណ៍នេះ គឺជាការជ្រើសរើសរបស់សាខាឃុំអ្នករើស ហើយបានឆ្លងតៗទៅលើ។ ដូច្នោះខ្ញុំមិនអាចបញ្ជាក់បានថា តើត្រឹមត្រូវ មិនត្រឹមត្រូវ ទីមួយ។ ទីពីរ ខ្ញុំសូមជម្រាបជូនដដែល ខ្ញុំមិនចាំទេបាទ។

**ស៖** លោកសាក្សី តើលោកស្គាល់លោក ហំ ដែរឬទេនៅក្នុងតំបន់៣១ សរសេរ H-A-M ជាភាសាបារាំង?

**ឆ៖** បាទ ចំពោះលោក ហំ ខ្ញុំមិនស្គាល់។ ហើយតំបន់៣១ ដែលលោកសួរ ខ្ញុំបានបញ្ជាក់បន្តបន្ទាប់ គឺខ្ញុំដឹង ខ្ញុំឮ ខ្ញុំស្គាល់ មានតែលោកហៅថា តាសារុន ម្នាក់គត់។

[១៦:០៧:១៨]

**ស៖** ខ្ញុំអត់-- លោកសាក្សី ខ្ញុំនិយាយអំពីតំបន់៣២ តើឈ្មោះ ហំ នេះមានទេនៅក្នុងតំបន់៣២?

**ឆ៖** បាទ ឈ្មោះ ហំ ក្នុងតំបន់៣២ គ្មានទេបាទ។

**លោក បាណាបេ ណោគ្វី៖**

លោកប្រធាន បាទខ្ញុំសូមបញ្ចប់ការចោទសំណួរទៅសាក្សីខ្ញុំនៅត្រឹមណោះ ហើយខ្ញុំ-- ហើយនិងសុំគិតអំពីការកត់សម្គាល់អំពីរបស់លោកប្រធាន ដល់ពីសារសំខាន់នៃការចោទសំណួរ ហើយខ្ញុំសូមថ្លែងអំណរគុណដល់លោកសាក្សីដែលបានព្យាយាមឆ្លើយតបនឹងសំណួររបស់ខ្ញុំ។ សូមអរគុណ។

[១៦:០៨:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណសាក្សី។

ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះឃើញថា ដល់ពេលសមល្មមត្រូវសម្រាកហើយ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី៣០ ឧសភា ឆ្នាំ២០០២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មឈ្មោះ នី កន ដែលនឹងតាំងសួរដេញដោលដោយក្រុមមេធាវីការពារក្តី ដែលក្នុងនោះនឹងចាប់ផ្តើមដំបូងគេដោយក្រុមមេធាវីការពារក្តី នួន ជា។

លោក នី កន ដោយការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ ដែលត្រូវបន្តធ្វើ

នៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែក។ ដូចគ្នានេះដែរ អង្គជំនុំជម្រះសូមអញ្ជើញលោកមេធាវីប្រឹក្សាសាក្សីចូលរួម ដើម្បីបន្តប្រឹក្សារសាក្សីនៅថ្ងៃ និងថ្ងៃបន្តបន្ទាប់នៃការស្តាប់សាក្សីរូបនេះ។

[១៦:០៩:១៦]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនទៅទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញឲ្យបាន នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី ប្រសិនបើគាត់បង្ហាញជំហរជាក់លាក់ក្នុងការលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងបន្ទប់សវនាការ ដោយសុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈពាក្យសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការជាលាយលក្ខណ៍អក្សរ បានមុនអង្គសវនាការចាប់ផ្តើមដំណើរការសវនាការ គឺម៉ោងប្រាំបួនព្រឹកនោះ អង្គជំនុំជម្រះឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់មកកាន់បន្ទប់ឃុំខ្លួនមួយ ដែលរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*